ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

របាយការណ៍អង្កេត

# ទស្សនវិស័យការងារកម្ពុជា



ឆមាសទី១ ឆ្នាំ២០២៥

សម្រាប់ការដាក់ឯកសារយោង៖ គី សេរីវុធ, អ៊ុំ ច័ន្ទមនោ, ទ្រី សុផល, ប៊ុន បូពិត, ជ្រា សៃសុគន្ធីដេត(២០២៥)។
របាយការណ៍អង្កេតទស្សនវិស័យការងារឆមាសទី១ ឆ្នាំ២០២៥។
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

*សម្គាល់៖ ទស្សនៈដែលបានបង្ហាញនៅក្នុងការបោះពុម្ពផ្សាយនេះ គឺគ្រាន់តែជាទស្សនៈរបស់អ្នកស្រាវជ្រាវប៉ុណ្ណោះ ហើយមិនតំណាងឱ្យទស្សនៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនោះទេ។*

# អារម្ភកថា

របាយការណ៍អង្កេត «ទស្សនវិស័យការងារកម្ពុជា ឆមាសទី១ ឆ្នាំ២០២៥» គឺជាឯកសារដ៏សំខាន់សម្រាប់ស្វែងយល់ពីបម្រែបម្រួលទីផ្សារការងារក្នុងប្រទេសកម្ពុជា។ របាយការណ៍អង្កេតនេះ សិក្សាអំពីទស្សនវិស័យ និន្នាការ និងបញ្ហាប្រឈមក្នុងវិស័យការងារ ខណៈដែលសេដ្ឋកិច្ចប្រទេសកម្ពុជាកំពុងបន្តងើបឡើងវិញក្នុងបរិការណ៍ដែលប្រទេសលើសកលលោកកំពុងត្រូវបានហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់។

ដោយមើលឃើញពីបម្រែបម្រួលនៃតម្រូវការកម្លាំងពលកម្មជំនាញ នៅក្នុងយុគសម័យទំនាក់ទំនងអន្តរសកល មានល្បឿនលឿន និងធំជាងអ្វីដែលធ្លាប់មានពីមុនមក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) បានរៀបចំរបាយការណ៍អង្កេតនេះឡើង ដោយតំណាងឱ្យមតិ និងគំនិតយោបល់របស់អ្នកពាក់ព័ន្ធជាច្រើនរួមមាន និយោជក អ្នកជំនាញផ្នែកធនធានមនុស្ស និងមជ្ឈមណ្ឌលការងាររបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារនៅទូទាំងប្រទេស។ លទ្ធផលរបាយការណ៍អង្កេតនេះ ត្រូវបានធ្វើឡើងជាទៀងទាត់ ចំនួនពីរដង ក្នុងមួយឆ្នាំ ដោយបានបង្កើតជាសន្ទស្សន៍ដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីទស្សន និងគោលដៅនៃទីផ្សារការងារ។

របាយការណ៍អង្កេតនេះ ធ្វើការវិភាគលើកត្តាសេដ្ឋកិច្ចសំខាន់ៗដូចជា កំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ការវិនិយោគផ្ទាល់ពីបរទេស (FDI) និងនិន្នាការប្រជាសាស្ត្រ ដែលមានឥទ្ធិពលលើទីផ្សារការងាររបស់ប្រទេសកម្ពុជា។ ដូចគ្នានេះដែរ របាយការណ៍អង្កេតនេះ ក៏បានធ្វើការវិភាគលម្អិតទៅលើទស្សនវិស័យការងារសម្រាប់២៥៦មុខរបរ រួមទាំងតម្រូវការការងារ, ការកំណត់អត្តសញ្ញាណឱកាសការងារថ្មីៗ និងសមត្ថភាពចាំបាច់, ប្រាក់ឈ្នួល និងបញ្ហាប្រឈម ព្រមទាំងទាញចេញជាសេចក្តីសន្និដ្ឋាន ដែលអាចជាជំនួយក្នុងការបង្កើនឱកាសដល់អ្នកស្វែងរកការងារ ជាមគ្គុទេសក៍សម្រាប់អ្នកផ្តល់សេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីពការងារនិងវិជ្ជាជីវៈ ដើម្បីផ្តល់សេវាការងារប្រកបដោយប្រសិទ្ធភាព ក៏ដូចជាអ្នកផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជាជីវៈ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលឱ្យស្របនឹងស្ថានភាពនៃតម្រូវការឧស្សាហកម្ម។

យើងខ្ញុំបន្តបង្ហាញឆន្ទៈវិជ្ជមានក្នុងការផ្តល់ព័ត៌មានទីផ្សារការងារគ្រប់គ្រាន់សម្រាប់យុវជន ក្នុងបរិការណ៍នៃការវិវត្តយ៉ាងឆាប់រហ័សនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច ទីផ្សារការងារ បច្ចេកទេស និងបច្ចេកវិទ្យាបច្ចុប្បន្ន ហើយក៏សូមលើកទឹកចិត្តដល់អ្នកអានឱ្យធ្វើអន្តរកម្មជាមួយរបាយការណ៍អង្កេតនេះ និងប្រើប្រាស់ការសន្និដ្ឋានដ៏មានតម្លៃដើម្បីទាញយកប្រយោជន៍ជាអតិបរមា។

ថ្ងៃ ចន្ទ ៥កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍អង្កេត «ទស្សនវិស័យការងារកម្ពុជា ធមាសទី១ ឆ្នាំ២០២៥» គឺជាផលិតផលស្រាវជ្រាវដ៏សំខាន់មួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ដែលបានផ្តល់ការព្យាករការងារ និងទីផ្សារការងារកម្ពុជា។ របាយការណ៍នេះ បានបង្ហាញពីទិដ្ឋភាពទូទៅនៃនិន្នាការការងារ និងឱកាសការងារសម្រាប់មុខរបរផ្សេងៗនៅប្រទេសកម្ពុជាក្នុងធមាសទី១ នៃឆ្នាំ២០២៥។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះការណែនាំ ការគាំទ្រដល់សកម្មភាពអង្កេត និងការរៀបចំរបាយការណ៍នេះប្រកបដោយភាពជោគជ័យ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះគំនិតផ្តួចផ្តើម និងការណែនាំបច្ចេកទេសដ៏មានតម្លៃរបស់ **ឯកឧត្តម គួច សុមាន** រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានផ្តល់នូវការណែនាំក្នុងដំណើរការអង្កេត។ យើងខ្ញុំក៏សូមសម្តែងនូវអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះ **ឯកឧត្តម ប្រុញ សុភាណា** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា (អ.ក.ជ.ប.អ.) ចំពោះមតិ និងយោបល់កែលម្អដ៏មានតម្លៃ។ ទន្ទឹមនឹងនេះ យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះមន្ត្រីនៃ អ.ក.ជ.ប.អ. ក៏ដូចជាប្រធានមជ្ឈមណ្ឌលការងារទាំងអស់របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ លើការគាំទ្រយ៉ាងសកម្មក្នុងអំឡុងពេលធ្វើការអង្កេត ជាពិសេសនៅពេលចុះសម្ភាសន៍ និងកិច្ចការរដ្ឋបាលផងដែរ។

ការងារស្រាវជ្រាវនេះនឹងមិនអាចសម្រេចបានទេ បើគ្មានការប្តេជ្ញាចិត្តពីក្រុមការងារស្រាវជ្រាវរបស់យើង ដែលមានលោកបណ្ឌិត គី សេរីវុធ ជាអ្នកដឹកនាំស្រាវជ្រាវ និងមានការរួមចំណែកលើការស្រាវជ្រាវ និងវិភាគពីសំណាក់ឯកឧត្តមបណ្ឌិត អ៊ុំ ច័ន្ទមនោ, ឯកឧត្តមបណ្ឌិត ទ្រី សុផល, ឯកឧត្តម ប៊ុន បូពិត, និងលោកស្រី ជ្រា សែសុគន្ធីដេត និងលើការសរសេររបាយការណ៍ដែលរួមមាន ឯកឧត្តម ថា ចាន់ថន លោក ម៉ុម នួច លោកស្រី ភី សុគន្ធយ៉ានុជ លោកស្រី យ៉ង់ ចាន់រ័ត្នថា និងលោកស្រី ធន ដារីត។ ភាពជោគជ័យនៃការងារស្រាវជ្រាវនេះ គឺសម្រេចបានដោយសារជំនាញបច្ចេកទេសរបស់អ្នកស្រាវជ្រាវនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លើការសម្អាតទិន្នន័យ ការសរសេរកូដ ការធ្វើតារាង ការវិភាគ និងការសរសេររបាយការណ៍។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកចូលរួមទាំងអស់ដែលបានចូលរួមក្នុងការអង្កេតនេះ សម្រាប់កិច្ចសហការយ៉ាងសកម្មក្នុងការសម្ភាស និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការឆ្លើយសំណួររបស់យើងខ្ញុំ។ លើសពីនេះ យើងខ្ញុំក៏សូមអរគុណដល់មន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានចំណាយពេលវេលាក្នុងការគាំទ្រ និងចូលរួមចំណែកក្នុងរបាយការណ៍អង្កេតនេះ។

# តារាងមាតិកា


សេចក្តីថ្លែងអំណរគុណ ..... ii
តារាងមាតិកា..... iii
បញ្ជីតារាង v
បញ្ជីរូបភាព viii
អក្សរកាត់ ix
សេចក្តីសង្ខេប..... x
វិធីសាស្ត្រស្រាវជ្រាវ..... xii
ការបង្កើតកម្រងសំណួរ..... xiv
ពេលវេលាចុះអង្កេត ..... xv
រចនាសម្ព័ន្ធក្រុមស្រាវជ្រាវ..... xv
ការប្រមូលទិន្នន័យ..... xvi
ការគ្រប់គ្រងទិន្នន័យ និងនីតិវិធីត្រួតពិនិត្យគុណភាព ..... xvi
ការវិភាគទិន្នន័យ ..... xvii
ការវាយតម្លៃ ការបកស្រាយសន្ទស្សន៍មុខរបរ និងលក្ខណវិនិច្ឆ័យ..... xix
ភាពខ្វះខាតនៃការអង្កេត ..... xxi
គោលបំណងនៃអង្កេត..... xxi
រចនាសម្ព័ន្ធនៃរបាយការណ៍ ..... xxi
ជំពូកទី ១ សេដ្ឋកិច្ចសកលក្នុងឆ្នាំ២០២៥ និងផលប៉ះពាល់នៃសេដ្ឋកិច្ចសកលមកលើកម្ពុជា ..... ១
១.១ ទស្សនវិស័យសេដ្ឋកិច្ចសកលឆ្នាំ២០២៥ ..... ១
១.២ ស្ថានភាពសេដ្ឋកិច្ច និងសក្តានុពលនៃកំណើនសេដ្ឋកិច្ចកម្ពុជា ..... ២
១.៣ ស្ថានភាពវិនិយោគកម្ពុជា ..... ២
១.៣.១ ការវិនិយោគផ្ទាល់ពីបរទេស (FDI)..... ២
១.៣.២ គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs) តាមវិស័យ..... ៤
១.៤ ឥទ្ធិពលនៃនិន្នាការសេដ្ឋកិច្ចពិភពលោកមកលើកម្ពុជា..... ៥
១.៤.១ កត្តាប្រឈម ..... ៥
១.៤.២ សក្តានុពល និងឱកាស ..... ៧
១.៥ ស្ថានភាពបច្ចុប្បន្ននៃទីផ្សារការងារកម្ពុជា..... ៨
១.៦ ការផ្លាស់ប្តូររចនាសម្ព័ន្ធនៅក្នុងសេដ្ឋកិច្ចកម្ពុជា..... ៩

ជំពូកទី ២ លទ្ធផលអង្កេត ..... ១១
២.១ ស្ថានភាពសហគ្រាស គ្រឹះស្ថានជាសំណាកគំរូ ..... ១១
២.២ ស្ថានភាពការងារ និងការជ្រើសរើសបុគ្គលិក ..... ១៥
២.២.១ ស្ថានភាពការងារ ..... ១៥
២.២.២ ស្ថានភាពជ្រើសរើសបុគ្គលិក ..... ១៨
២.៣ ទស្សនវិស័យការងារតាមក្រុមមុខរបរ ..... ២២
២.៣.១ រដ្ឋបាល និងធនធានមនុស្ស (គ្រប់វិស័យ) ..... ២២
២.៣.២ ហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្ម (លើកលែងវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង) ..... ២៤
២.៣.៣ ការលក់ និងទីផ្សារ (លើកលែងតែវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង) ..... ២៥
២.៣.៤ ជួសជុល ថែទាំ និងគាំទ្រទូទៅ (គ្រប់វិស័យ) ..... ២៥
២.៣.៥ ការគាំទ្រផ្នែកព័ត៌មាន និងបច្ចេកវិទ្យា (លើកលែងតែវិស័យ ICT) ..... ២៦
២.៤ ទស្សនវិស័យការងារតាមអនុវិស័យ ..... ២៧
២.៤.១ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) ..... ២៧
២.៤.២ សេវាស្នាក់នៅ និងភោជនីយដ្ឋាន ..... ៣០
២.៤.៣ សំណង់ ..... ៣៣
២.៤.៤ អប់រំ ..... ៣៦
២.៤.៥ ហិរញ្ញវត្ថុ និងធានារ៉ាប់រង ..... ៣៨
២.៤.៦ សេវាថែទាំសុខភាព ..... ៤១
២.៤.៧ វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ..... ៤៤
២.៤.៨ ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី ..... ៤៧
២.៤.៩ ផលិតអាហារ និងភេសជ្ជៈ ..... ៥០
២.៤.១០ ផលិតកៅស៊ូ និងប្លាស្ទិក ..... ៥២
២.៤.១១ ផលិតផលិតផលឈើ និងក្រដាស ..... ៥៥
២.៤.១២ កម្មន្តសាលផ្សេងៗ ..... ៥៨
២.៤.១៣ ដឹកជញ្ជូន និងស្តុកទំនិញ ..... ៦១
២.៥ មុខរបរដែលមានតម្រូវការខ្ពស់ ..... ៦៤
ជំពូកទី ៣ សេចក្តីសន្និដ្ឋាន ..... ៧២
ឯកសារយោង ..... ៧៣
ឧបសម្ព័ន្ធ កៈ កម្រងសំណួរ ..... ៧៦
ឧបសម្ព័ន្ធ ខៈ វាក្យសព្ទប្រតិបត្តិការ និងគោលគំនិត ..... ៨៧
ឧបសម្ព័ន្ធ គៈ ចរិតលក្ខណៈនៃសហគ្រាស គ្រឹះស្ថាន ..... ៨៩

# បញ្ជីតារាង

តារាងទី ១៖ ចំនួនសំណាកដែលបានសម្ភាសតាមអនុវិស័យ (អ.វ) និងរាជធានី ខេត្ត.................................xiii

តារាងទី ២៖ ចំនួនសំណាកដែលបានសម្ភាសឡើងវិញតាមអនុវិស័យ (អ.វ) ក្នុងឆមាសទី១ ឆ្នាំ២០២៥.........xiii

តារាងទី ៣៖ ចំនួនសហគ្រាស គ្រឹះស្ថាន និងចំនួនកម្មករ និយោជិតតំណាងឱ្យសំណាកគំរូ........................ xviii

តារាងទី ៤៖ លក្ខណវិនិច្ឆ័យចំនួន ៥ សម្រាប់ចាត់ថ្នាក់មុខរបរដែលមានតម្រូវការខ្ពស់ .................................xx

តារាងទី ៥៖ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ពីទស្សនវិស័យសេដ្ឋកិច្ចសកលតាមវិស័យសំខាន់ៗ ......................... ៦

តារាងទី ៦៖ ចំនួនការងារ និងកំណើនការងារដែលនិយោជករំពឹងទុកសម្រាប់ឆមាសទី១ ឆ្នាំ២០២៥ ដល់ឆមាសទី១ ឆ្នាំ២០២៦........................................................................................................................ ១៦

តារាងទី ៧៖ មុខរបរដែលមានឱកាសការងារល្អ និងមានអ្នកស្វែងរកការងារដំបូងច្រើន ............................. ១៨

តារាងទី ៨៖ តារាងសង្ខេបព័ត៌មានចំនួនសហគ្រាស គ្រឹះស្ថាន កម្មករ និយោជិត និងចំនួនប្រកាសជ្រើសរើសដែលរំពឹងទុកតាមរាជធានី ខេត្ត ........................................................................................................ ១៩

តារាងទី ៩៖ ឱកាសការងារសម្រាប់ក្រុមមុខរបរផ្នែករដ្ឋបាល និងធនធានមនុស្ស......................................២៣

តារាងទី ១០៖ ឱកាសការងារសម្រាប់ក្រុមមុខរបរផ្នែកហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្ម...........................២៤

តារាងទី ១១៖ ឱកាសការងារសម្រាប់ក្រុមមុខរបរផ្នែកលក់ និងទីផ្សារ......................................................២៥

តារាងទី ១២៖ ឱកាសការងារសម្រាប់ក្រុមមុខរបរផ្នែកជួសជុល ថែទាំ និងគាំទ្រទូទៅ...................................២៦

តារាងទី ១៣៖ ឱកាសការងារសម្រាប់មុខរបរគាំទ្រផ្នែកព័ត៌មាន និងបច្ចេកវិទ្យា (IT) ...............................២៧

តារាងទី ១៤៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យ ICT.........................................................................២៨

តារាងទី ១៥៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យ ICT.................................៣០

តារាងទី ១៦៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យសេវាស្នាក់នៅ និងភោជនីយដ្ឋាន ....................................៣១

តារាងទី ១៧៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យសេវាស្នាក់នៅ និងភោជនីយដ្ឋាន..៣២

តារាងទី ១៨៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យសំណង់ ......................................................................៣៤

តារាងទី ១៩៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យសំណង់ ............................៣៥

តារាងទី ២០៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យអប់រំ.........................................................................៣៦

តារាងទី ២១៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យអប់រំ................................ ៣៨
តារាងទី ២២៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង ............................................... ៣៩
តារាងទី ២៣៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង..... ៤១
តារាងទី ២៤៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យសេវាថែទាំសុខភាព..................................................... ៤២
តារាងទី ២៥៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យសេវាថែទាំសុខភាព............ ៤៣
តារាងទី ២៦៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង ផលិតផលិតផលធ្វើដំណើរនិងកាបូប ........................................................................................................................... ៤៥
តារាងទី ២៧៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យ GFT.............................. ៤៦
តារាងទី ២៨៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី .............. ៤៨
តារាងទី ២៩៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី ............................................................................................................. ៤៩
តារាងទី ៣០៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យផលិតអាហារ និងភេសជ្ជៈ ............................................ ៥១
តារាងទី ៣១៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យផលិតអាហារ និងភេសជ្ជៈ.... ៥២
តារាងទី ៣២៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យផលិតកៅស៊ូ និងប្លាស្ទិក .............................................. ៥៣
តារាងទី ៣៣៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យផលិតកៅស៊ូ និងប្លាស្ទិក...... ៥៤
តារាងទី ៣៤៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យផលិតផលិតផលឈើ និងក្រដាស.................................. ៥៧
តារាងទី ៣៥៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យផលិតផលិតផលឈើ និងក្រដាស ៥៨
តារាងទី ៣៦៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យកម្មន្តសាលផ្សេងៗ..................................................... ៦០
តារាងទី ៣៧៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យកម្មន្តសាលផ្សេងៗ............ ៦១
តារាងទី ៣៨៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញ ............................................. ៦២
តារាងទី ៣៩៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញ..... ៦៤
តារាងទី ៤០៖ មុខរបរដែលមានតម្រូវការខ្ពស់តាមកម្រិតជំនាញ.......................................................... ៦៥
តារាងទី ៤១៖ មុខរបរមានកំណើនលឿនក្នុងឆមាសទី១ ឆ្នាំ២០២៥ ....................................................... ៦៧

តារាងទី ៤២៖ មុខរបរដែលថយចុះក្នុងឆមាសទី១ ឆ្នាំ២០២៥..................................................................... ៦៩
តារាង គ.១៖ របាយនៃសហគ្រាស គ្រឹះស្ថានសំណាក និងកម្មករនិយោជិតតាមអនុវិស័យ.......................... ៨៩
តារាង គ.២៖ របាយសំណាកតាមទំហំសហគ្រាស គ្រឹះស្ថាន................................................................ ៩០
តារាង គ.៣៖ របាយសំណាកតាមឆ្នាំបង្កើតសហគ្រាស គ្រឹះស្ថាន........................................................ ៩១
តារាង គ.៤៖ របាយសំណាកតាមប្រភេទសហគ្រាស គ្រឹះស្ថាន និងសញ្ជាតិម្ចាស់សហគ្រាស គ្រឹះស្ថាន ......... ៩២
តារាង គ.៥៖ របាយសហគ្រាស គ្រឹះស្ថានតាមប្រភេទអាជីវកម្ម ............................................................ ៩៣

# បញ្ជីរូបភាព


រូបភាពទី ១៖ រចនាសម្ព័ន្ធក្រុមស្រាវជ្រាវ ....................................................................................xv

រូបភាពទី ២៖ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសតាមតំបន់ ២០២២-២០២៣ (គិតជា ប៊ីលានដុល្លារអាម៉េរិក) ៣

រូបភាពទី ៣៖ ទំហំនៃការវិនិយោគផ្ទាល់ពីបរទេសក្នុងប្រទេសកម្ពុជា ២០២២-២០២៤ (គិតជា លានដុល្លារអាម៉េរិក) ៤

រូបភាពទី ៤៖ ចំនួនគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមវិស័យ ២០១៩-២០២៤ ........... ៥

រូបភាពទី ៥៖ ចំនួនការងារដែលបង្កើតដោយគម្រោង QIPs តាមវិស័យ ២០១៩-២០២៤ (គិតជា ពាន់) ........ ៥

រូបភាពទី ៦៖ ដង់ស៊ីតេជាអ្នកស្វែងរកការងារដំបូងតាមវិស័យ (គិតជាភាគរយ) ...................................... ១៧

រូបភាពទី ៧៖ ស្ថានភាពរបស់និយោជកក្នុងការជ្រើសរើសបុគ្គលិកតាមអនុវិស័យ (សន្ទស្សន៍)..................... ២០

រូបភាពទី ៨៖ មូលហេតុដែលនិយោជកលំបាកក្នុងការជ្រើសរើសបុគ្គលិក................................................២២

រូបភាព ខ.១៖ ផែនទីកង្វះជំនាញ ............................................................................................. ៨៨

# អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CSES | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា |
| FDI | ការវិនិយោគផ្ទាល់ពីបរទេស |
| GDP | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) |
| GFT | វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប |
| HR | ធនធានមនុស្ស |
| ICT | បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា |
| ILO | អង្គការអន្តរជាតិខាងការងារ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| IT | ព័ត៌មាន និងបច្ចេកវិទ្យា |
| ISCO | ស្តង់ដារចំណាត់ថ្នាក់មុខរបរអន្តរជាតិ |
| LACMS | ប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| NEA | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| QIPs | គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| TVET | អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UNCTAD | អង្គការសហប្រជាជាតិ ពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ |
| US | សហរដ្ឋអាមេរិក |

# សេចក្ដីសង្ខេប

នៅឆ្នាំ២០២៥ សក្ដានុពលសេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងជះឥទ្ធិពលដល់បរិយាកាសសេដ្ឋកិច្ចរបស់កម្ពុជា។ ល្បឿនយ៉ាងលឿននៃការផ្លាស់ប្ដូរឌីជីថល និងការផ្លាស់ប្ដូរនៃពាណិជ្ជកម្មពិភពលោក ផ្ដល់ឱ្យកម្ពុជាទាំងឱកាស និងបញ្ហាប្រឈម ដែលទាមទារឱ្យកម្ពុជាត្រូវបង្កើនជំហរសេដ្ឋកិច្ចរបស់ខ្លួន។ សមាហរណកម្មនៅក្នុងក្របខណ្ឌសេដ្ឋកិច្ចក្នុងតំបន់ ដូចជាអាស៊ានគាំទ្រដល់ការបង្កើនការនាំចេញ និងការវិនិយោគបរទេស។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជាប្រឈមមុខនឹងបញ្ហាប្រឈមពីការប្រែប្រួលសេដ្ឋកិច្ចពិភពលោក និងភាពតានតឹងភូមិសាស្ត្រនយោបាយ។ ដើម្បីដោះស្រាយនឹងបញ្ហាប្រឈមទាំងនេះប្រកបដោយប្រសិទ្ធភាព កម្ពុជាត្រូវវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ជំរុញការបង្កើតថ្មី និងពង្រឹងភាពធន់ ដើម្បីរក្សាកំណើន និងការប្រកួតប្រជែងប្រកបដោយនិរន្តរភាព។

របាយការណ៍នេះសិក្សាពីទស្សនវិស័យការងារកម្ពុជាសម្រាប់ឆមាសទី១ ឆ្នាំ២០២៥ ដោយផ្ដោតលើការវិភាគទីផ្សារការងារ និន្នាការការងារ និងឱកាសការងារក្នុងវិស័យផ្សេងៗ។ ការសិក្សានេះប្រើប្រាស់ទិន្នន័យពីការសម្ភាសន៍ក្រុមហ៊ុន និងគ្រឹះស្ថានចំនួន ៦៣៨ ដែលគ្របដណ្ដប់លើវិស័យសេដ្ឋកិច្ចសំខាន់ៗចំនួន ១៣ និងរាជធានីខេត្តចំនួន ១០ នៅក្នុងប្រទេសកម្ពុជា។ ការសិក្សានេះមានគោលបំណងផ្ដល់ព័ត៌មានសម្រាប់អ្នកស្វែងរកការងារ និងអ្នកជំនាញធនធានមនុស្សដើម្បីជួយពួកគេក្នុងការសម្រេចចិត្ត និងកសាងយុទ្ធសាស្ត្រអភិវឌ្ឍអាជីព។ ទិន្នន័យនៃការសិក្សានេះត្រូវបានប្រមូលតាមរយៈការសម្ភាសន៍ដែលបានធ្វើឡើងរយៈពេល៤សប្ដាហ៍ ដោយចាប់ផ្ដើមពីថ្ងៃទី០២ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤។ ក្រុមអ្នកស្រាវជ្រាវបានធ្វើការសម្ភាសជាមួយអ្នកជំនាញខាងធនធានមនុស្ស ម្ចាស់ ឬដៃគូភាគហ៊ុន នាយកប្រតិបត្តិ អ្នកគ្រប់គ្រងទូទៅ អ្នកគ្រប់គ្រងផលិតកម្ម និងប្រធានផ្នែកគ្រប់គ្រងជាន់ខ្ពស់ផ្សេងទៀត។

លទ្ធផលអង្កេតបានបង្ហាញពីទស្សនវិស័យចម្រុះសម្រាប់ឱកាសការងារនៅកម្ពុជា។ តម្រូវការកំពុងកើនឡើងសម្រាប់អ្នកជំនាញដែលមានជំនាញក្នុងវិស័យបច្ចេកវិទ្យា និងផលិតកម្ម។ មុខរបរដែលមានការរីកចម្រើនខ្លាំងរួមមានអ្នកដែលមានជំនាញពាក់ព័ន្ធនឹងផ្នែកបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) ប្រតិបត្តិករបញ្ជាម៉ាស៊ីនកាត់ដេរ និងវាយនភណ្ឌ អ្នកគ្រប់គ្រងផ្នែកផលិតកម្ម អ្នកកត់ត្រាផលិតកម្ម អ្នកគ្រប់គ្រងផ្នែកដឹកជញ្ជូន និងអ្នកកត់ត្រាផ្នែកដឹកជញ្ជូន។ តួនាទីទាំងនេះមានសារៈសំខាន់នៅពេលដែលកម្ពុជាកំពុងស្រូបយកនូវបច្ចេកវិទ្យាទំនើប និងលើកកម្ពស់ដំណើរការផលិតកម្ម។ ដើម្បីបំពេញតាមតម្រូវការទាំងនេះ ការបង្កើនជំនាញកម្លាំងពលកម្ម និងប្រព័ន្ធអប់រំដែលស្របតាមតម្រូវការនៃឧស្សាហកម្មដែលកំពុងវិវត្តគឺចាំបាច់ណាស់។

ផ្ទុយទៅវិញ មុខរបរដែលស្ថិតក្នុងវិស័យហិរញ្ញវត្ថុកំពុងប្រឈមមុខនឹងបញ្ហា ខណៈវិស័យនេះកំពុងដំណើរការរៀបចំរចនាសម្ព័ន្ធទៅជាស្វ័យប្រវត្តិកម្ម ក៏ដូចជាការកើនឡើងនូវធនាគារឌីជីថល និងការច្នៃប្រឌិត FinTech។

មុខរបរដែលមានលក្ខណៈដដែលៗ (routine) ត្រូវបានកាត់បន្ថយដោយសារការប្រើប្រាស់នូវបច្ចេកវិទ្យា ឬកម្មវិធីឌីជីថលជាការជំនួយ។ មុខរបរទាក់ទងនឹងការផ្សព្វផ្សាយទីផ្សារ ក៏ឃើញថាមានការធ្លាក់ចុះផងដែរ ដែលឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរតម្រូវការក្នុងទីផ្សារដែលជំរុញដោយការប្រើប្រាស់ទិន្នន័យកាន់តែខ្លាំងឡើង ជាពិសេសការផ្សព្វផ្សាយឌីជីថលដែលតម្រូវឱ្យមានជំនាញបន្ថែម ជាពិសេសផ្នែកប្រើប្រាស់បច្ចេកវិទ្យា។ និន្នាការទាំងនេះសង្កត់ធ្ងន់ទៅលើតម្រូវការសម្រាប់ការបណ្តុះបណ្តាលឡើងវិញ និងការធ្វើពិពិធកម្មជំនាញ ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរទៅក្នុងវិស័យដែលកំពុងរីកចម្រើន។

ទស្សនវិស័យទីផ្សារការងាររបស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០២៥ បង្ហាញពីការបញ្ចូលគ្នានៃឱកាស និងបញ្ហាប្រឈម។ ការវិភាគលើការរីកលូតលាស់ និងការធ្លាក់ចុះនៃមុខរបរនៅក្នុងប្រទេសកម្ពុជា គូសបញ្ជាក់អំពីទីផ្សារការងារដ៏ស្វាហាប់ដែលបង្កើតឡើងដោយភាពជឿនលឿននៃបច្ចេកវិទ្យា និងការផ្លាស់ប្តូរតម្រូវការឧស្សាហកម្ម។ ដើម្បីទាញយកប្រយោជន៍ពីឱកាសរីកចម្រើន គួរតែផ្តល់អាទិភាពដល់ការពង្រឹងការអភិវឌ្ឍជំនាញ ជាពិសេសផ្នែកបច្ចេកវិទ្យា និងភស្តុភារ។

ការពង្រឹងការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានសារៈសំខាន់ណាស់ក្នុងការរៀបចំ និងបំពាក់កម្លាំងពលកម្មជាមួយនឹងជំនាញពាក់ព័ន្ធសម្រាប់តម្រូវការនាពេលអនាគត។ លើសពីនេះ ការបន្តអភិវឌ្ឍជំនាញ និងចំណេះដឹង គឺជាកត្តាចម្បងក្នុងការទទួលបានជោគជ័យក្នុងអាជីព។ ការសិក្សានេះបានបង្ហាញពីសារៈសំខាន់នៃការវិនិយោគលើការអភិវឌ្ឍជំនាញ និងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងបង្កើនឱកាសការងារ។ ការសិក្សានេះក៏បានបង្ហាញពីតួនាទី ដែលមានតម្រូវការខ្ពស់ ដែលភាគច្រើនជាអ្នកស្វែងរកការងារធ្វើលើកដំបូង ដែលត្រូវការជំនាញបន្ថែម និងការបណ្តុះបណ្តាលបន្ថែម ដើម្បីបំពេញតម្រូវការទីផ្សារការងារ។ ការអភិវឌ្ឍជំនាញបច្ចេកទេស និងវិជ្ជាជីវៈ គឺជាកត្តាចាំបាច់ក្នុងការបង្កើនសមត្ថភាពការងារ និងប្រាក់ចំណូលរបស់ប្រជាជនកម្ពុជា។ ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងការរីកចម្រើនបច្ចេកវិទ្យាបាននាំមកនូវបញ្ហាប្រឈមថ្មីៗ ដែលទាមទារឱ្យមានការវិនិយោគបន្ថែមលើការអភិវឌ្ឍធនធានមនុស្ស។

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះផ្តោតសំខាន់ទៅលើទស្សនវិស័យការងារដោយផ្អែកលើផ្នែកតម្រូវការរបស់និយោជក។ សម្រាប់ការជ្រើសរើសសំណាកគំរូ អង្កេតនេះបានប្រើប្រាស់បញ្ជីសហគ្រាស គ្រឹះស្ថានដែលត្រូវបានយកចេញពីប្រព័ន្ធចុះបញ្ជីអាជីវកម្ម ឬស្ថាប័នដែលបានចុះឈ្មោះជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS)។ ការជ្រើសរើសសំណាកត្រូវបានធ្វើឡើងតាមកម្រិត (Stratified) ការជ្រើសរើសតាមគោលបំណង (Purposive) និងការជ្រើសរើសសំណាកដោយចៃដន្យ (Random sampling)។

ការចាប់យកសំណាកសហគ្រាស គ្រឹះស្ថានគឺផ្អែកទៅលើការប្រមូលផ្តុំនៃសកម្មភាពសេដ្ឋកិច្ចអាជីវកម្មនៅក្នុងរាជធានី ខេត្តចំនួន១០ ដែលត្រូវបានជ្រើសរើសដើម្បីប្រមូលទិន្នន័យសម្រាប់ការអង្កេតនេះ។ ខេត្តទាំងនោះរួមមាន ខេត្តកណ្តាល, កំពង់ចាម, កំពង់ស្ពឺ, កំពត, តាកែវ, បាត់ដំបង, ព្រះសីហនុ, ភ្នំពេញ, សៀមរាប និងស្វាយរៀង។ សម្រាប់សកម្មភាពសេដ្ឋកិច្ចត្រូវបានបែងចែកជា ២ គឺវិស័យឧស្សាហកម្ម និងសេវាកម្ម ហើយក្នុងវិស័យនីមួយៗត្រូវបានបែងចែកតាមទំហំដូចជា វិស័យឧស្សាហកម្ម ខ្នាតតូច (កម្មករនិយោជិតចន្លោះពី ៥នាក់ ដល់ ៤៩នាក់) មធ្យម (កម្មករនិយោជិតចន្លោះពី ៥០នាក់ ដល់ ១៩៩នាក់) និងធំ (កម្មករនិយោជិតចាប់ពី ២០០នាក់ឡើង) រីឯវិស័យសេវាកម្ម ខ្នាតតូច (កម្មករនិយោជិតចន្លោះពី ៥នាក់ ដល់ ៤៩នាក់) មធ្យម (កម្មករនិយោជិតចន្លោះពី ៥០ នាក់ ដល់ ៩៩នាក់) និងធំ (កម្មករនិយោជិតពី ១០០នាក់ឡើង)។ ការបែងចែកខ្នាតនៃសកម្មភាពសេដ្ឋកិច្ចនេះ គឺដើម្បីធានានូវការយល់ដឹងពីតម្រូវការជំនាញឱ្យបានទូលំទូលាយដោយផ្អែកលើទំហំអាជីវកម្មផ្សេងៗគ្នា។ ជាលទ្ធផល សំណាកគំរូសហគ្រាស គ្រឹះស្ថានចំនួន ៦៣៨ ត្រូវបានសម្ភាស ដែលតំណាងឱ្យកម្លាំងពលកម្មសរុបចំនួន ២៤១ ៤២៩នាក់។

ប្រភេទអាជីវកម្មទាំងនោះស្ថិតក្នុងក្រុមវិស័យសេដ្ឋកិច្ចធំៗចំនួន១៣ ដែលត្រូវបានកំណត់ និងជ្រើសរើសសម្រាប់ការអង្កេត រួមមាន៖ ១) បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) ២) សេវាស្នាក់នៅ និងភោជនីយដ្ឋាន ៣) សំណង់ ៤) អប់រំ ៥) ហិរញ្ញវត្ថុ និងធានារ៉ាប់រង ៦) សេវាថែទាំសុខភាព ៧) វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ៨) ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី ៩) ផលិតអាហារ និងភេសជ្ជៈ ១០) ផលិតកៅស៊ូ និងប្លាស្ទិក ១១) ផលិតផលឈើ និងក្រដាស ១២) កម្មន្តសាលផ្សេងៗ និង១៣) ដឹកជញ្ជូន និងស្តុកទំនិញ។

## តារាងទី ១៖ ចំនួនសំណាកដែលបានសម្ភាសតាមអនុវិស័យ (អ.វ) និងរាជធានី ខេត្ត

| រាជធានី ខេត្ត | អ.វ 1 | អ.វ 2 | អ.វ 3 | អ.វ 4 | អ.វ 5 | អ.វ 6 | អ.វ 7 | អ.វ 8 | អ.វ 9 | អ.វ 10 | អ.វ 11 | អ.វ 12 | អ.វ 13 | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កណ្តាល | 0 | 0 | 0 | 2 | 5 | 1 | 9 | 3 | 3 | 2 | 6 | 1 | 1 | 33 |
| កំពង់ចាម | 0 | 2 | 1 | 3 | 3 | 1 | 1 | 0 | 0 | 2 | 0 | 0 | 0 | 13 |
| កំពង់ស្ពឺ | 0 | 0 | 0 | 2 | 7 | 0 | 9 | 0 | 1 | 2 | 4 | 6 | 0 | 31 |
| កំពត | 0 | 5 | 0 | 3 | 0 | 0 | 4 | 0 | 3 | 0 | 0 | 3 | 0 | 18 |
| តាកែវ | 0 | 0 | 0 | 0 | 5 | 0 | 20 | 6 | 0 | 0 | 0 | 3 | 0 | 34 |
| បាត់ដំបង | 1 | 1 | 2 | 4 | 8 | 5 | 0 | 0 | 3 | 1 | 0 | 2 | 0 | 27 |
| ព្រះសីហនុ | 1 | 6 | 2 | 2 | 2 | 1 | 3 | 2 | 0 | 2 | 3 | 4 | 2 | 30 |
| ភ្នំពេញ | 13 | 16 | 33 | 56 | 54 | 23 | 46 | 11 | 25 | 21 | 14 | 22 | 49 | 383 |
| សៀមរាប | 0 | 19 | 0 | 7 | 2 | 3 | 0 | 0 | 2 | 0 | 0 | 2 | 1 | 36 |
| ស្វាយរៀង | 0 | 0 | 0 | 0 | 1 | 0 | 7 | 9 | 0 | 5 | 2 | 9 | 0 | 33 |
| សរុប | 15 | 49 | 38 | 79 | 87 | 34 | 99 | 31 | 37 | 35 | 29 | 52 | 53 | 638 |

សម្គាល់៖ អ.វ 1៖ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT), អ.វ 2៖ សេវាស្នាក់នៅ និងភោជនីយដ្ឋាន, អ.វ 3៖ សំណង់, អ.វ 4៖ អប់រំ, អ.វ 5៖ ហិរញ្ញវត្ថុ និងធានារ៉ាប់រង, អ.វ 6៖ សេវាថែទាំសុខភាព, អ.វ 7៖ វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូប, អ.វ 8៖ ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី, អ.វ 9៖ ផលិតអាហារ និងភេសជ្ជៈ, អ.វ 10៖ ផលិតកៅស៊ូ និងប្លាស្ទិក, អ.វ 11៖ ផលិតផលឈើ និងក្រដាស, អ.វ 12៖ កម្មន្តសាលផ្សេងៗ, និង អ.វ 13៖ ការដឹកជញ្ជូន និងស្តុកទំនិញ។

## តារាងទី ២៖ ចំនួនសំណាកដែលបានសម្ភាសឡើងវិញតាមអនុវិស័យ (អ.វ) ក្នុងឆមាសទី១ ឆ្នាំ២០២៥

| អនុវិស័យ | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ | % សំណាកសម្ភាសឡើងវិញ (Repeat sample) |
|---|---|---|---|
| អ.វ 1 | 14 | 8 | 57% |
| អ.វ 2 | 45 | 28 | 62% |
| អ.វ 3 | 34 | 21 | 62% |
| អ.វ 4 | 90 | 53 | 59% |
| អ.វ 5 | 124 | 44 | 35% |
| អ.វ 6 | 34 | 25 | 74% |
| អ.វ 7 | 59 | 39 | 66% |
| អ.វ 8 | 23 | 16 | 70% |
| អ.វ 9 | 24 | 16 | 67% |

| អនុវិស័យ | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ | % សំណាកសម្ភាសឡើងវិញ (Repeat sample) |
|---|---|---|---|
| អ.វ 10 | 24 | 18 | 75% |
| អ.វ 11 | 19 | 15 | 79% |
| អ.វ 12 | 45 | 27 | 60% |
| អ.វ 13 | 42 | 32 | 76% |
| សរុប | 577 | 342 | 59% |

សម្គាល់៖ អ.វ 1៖ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT), អ.វ 2៖ សេវាស្នាក់នៅ និងភោជនីយដ្ឋាន, អ.វ 3៖ សំណង់, អ.វ 4៖ អប់រំ, អ.វ 5៖ ហិរញ្ញវត្ថុ និងធានារ៉ាប់រង, អ.វ 6៖ សេវាថែទាំសុខភាព, អ.វ 7៖ វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូប, អ.វ 8៖ ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី, អ.វ 9៖ ផលិតអាហារ និងភេសជ្ជៈ, អ.វ 10៖ ផលិតកៅស៊ូ និងប្លាស្ទិក, អ.វ 11៖ ផលិតផលឈើ និងក្រដាស, អ.វ 12៖ កម្មន្តសាលផ្សេងៗ, និង អ.វ 13៖ ការដឹកជញ្ជូន និងស្តុកទំនិញ។

## ការបង្កើតកម្រងសំណួរ

កម្រងសំណួរសម្រាប់ការអង្កេតនេះ ត្រូវបានបង្កើតឡើងដោយផ្អែកលើបញ្ជីមុខរបរចំនួន ២៥៦ នៃ ៥ផ្នែកនៃក្រុមមុខរបរ រួមជាមួយនឹងមុខរបរដែលតម្រូវទៅតាមអនុវិស័យសំខាន់ៗចំនួន ១៣។ ក្រុមមុខរបរទាំង ៥ រួមមាន៖ ១) រដ្ឋបាល និងធនធានមនុស្ស ២) ហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្ម ៣) ការលក់ និងទីផ្សារ ៤) ជួសជុល ថែទាំ និងគាំទ្រទូទៅ និង៥) ជំនួយផ្នែកព័ត៌មាន និងបច្ចេកវិទ្យា។ អនុវិស័យទាំង ១៣ រួមមាន៖ ១) បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា (ICT) ២) សេវាស្នាក់នៅ និងភោជនីយដ្ឋាន ៣) សំណង់ ៤) ការអប់រំ ៥) ហិរញ្ញវត្ថុ និងធានារ៉ាប់រង ៦) សេវាថែទាំសុខភាព ៧) វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ៨) ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី ៩) ផលិតអាហារ និងភេសជ្ជៈ ១០) ផលិតជ័រកៅស៊ូ និងប្លាស្ទិក ១១) ផលិតផលិតផលឈើ និងក្រដាស ១២) កម្មន្តសាលផ្សេងៗ និង១៣) ដឹកជញ្ជូន និងស្តុកទំនិញ។ បញ្ជីនេះត្រូវបានបង្កើតឡើងដោយផ្អែកលើបញ្ជីមុខរបររបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ពីឆ្នាំ២០១៧, ២០១៨ និង២០២០ និងទិន្នន័យមុខរបរពីការអង្កេតសេដ្ឋកិច្ច សង្គមកម្ពុជា (CSES) ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០២១។ លើសពីនេះ បញ្ជីនេះត្រូវបានរៀបចំឡើងតាមចំណាត់ថ្នាក់ស្តង់ដាអន្តរជាតិនៃមុខរបរ (ISCO-08 កម្រិតបួនខ្ទង់) ដើម្បីធានាបាននូវការប្រៀបធៀបជាអន្តរជាតិ និងការអភិវឌ្ឍការវាយតម្លៃមុខរបររយៈពេលមធ្យម និងរយៈពេលវែង។

កម្រងសំណួរ ត្រូវបានរៀបចំតាមមុខរបរនីមួយៗ (សូមមើលឧបសម្ព័ន្ធ ក) ដែលអនុញ្ញាតឱ្យអ្នកឆ្លើយតបបំពេញចំនួនកម្មករនិយោជិតបច្ចុប្បន្ន អ្នកស្វែងរកការងារដំបូង ដំណឹងជ្រើសរើសបុគ្គលិក ស្ថានភាពលំបាកក្នុងការជ្រើសរើស និងមូលហេតុដែលពិបាកជ្រើសរើស ប្រាក់ឈ្នួល និងអត្ថប្រយោជន៍បច្ចុប្បន្នសម្រាប់និយោជិត ក៏ដូចជាការរំពឹងទុកក្នុងរយៈពេលមធ្យម (ឧ៖ នៅឆ្នាំក្រោយ) ស្តីពីប្រាក់ឈ្នួល និងអត្ថប្រយោជន៍រំពឹងទុក។

### ពេលវេលាចុះអង្កេត

ដំណើរការនៃការប្រមូលទិន្នន័យមានរយៈពេល៤សប្តាហ៍ ដោយចាប់ផ្តើមពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ ដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៥ ដោយមានអ្នកសម្ភាសចំនួន ១២រូប និងមានការជួយគាំទ្រពីមជ្ឈមណ្ឌលការងារនៅទូទាំងរាជធានី និងខេត្ត ដែលជាគោលដៅនៃការអង្កេតផងដែរ។ ក្រោយពីបិទបញ្ចប់សកម្មភាពការងារប្រមូលទិន្នន័យរួចរាល់ អ្នកបញ្ចូលទិន្នន័យចំនួន ១២នាក់ ទទួលភារកិច្ចបញ្ចូលការឆ្លើយតបទាំងអស់ដែលប្រមូលបានពីការសម្ភាសឱ្យបានត្រឹមត្រូវទៅក្នុងមូលដ្ឋានប្រព័ន្ធបញ្ចូលទិន្នន័យ (KoboToolbox) ហើយដំណើរការនៃការបញ្ចូលទិន្នន័យមានរយៈពេល ៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៤។

### រចនាសម្ព័ន្ធក្រុមស្រាវជ្រាវ

ដោយផ្អែកលើចំនួនសំណាក និងពេលវេលានៃការប្រមូលទិន្នន័យ យើងបានស្នើឡើងនូវការបង្កើតក្រុមអ្នកសម្ភាសចំនួន ២ក្រុម ដើម្បីដាក់ពង្រាយសម្រាប់ការសម្ភាសជាមួយនឹងតំណាងសហគ្រាស គ្រឹះស្ថាន។ ក្រុមនីមួយៗមានអ្នកគ្រប់គ្រង ១នាក់ ដែលអាចគ្រប់គ្រងអ្នកសម្ភាសចំនួន ៦នាក់ ហើយអ្នកគ្រប់គ្រងទាំងអស់ត្រូវរាយការណ៍ទៅអ្នកគ្រប់គ្រងគម្រោង ដែលត្រូវបានជួយដោយអ្នកគ្រប់គ្រង និងពិនិត្យគុណភាពទិន្នន័យ។ យើងក៏បានបង្កើតក្រុមបញ្ចូលទិន្នន័យ ២ក្រុមបន្ថែមទៀត ដើម្បីជាជំនួយដល់ការបញ្ចូលទិន្នន័យឱ្យបានទាន់ពេលវេលា។ ក្រុមបញ្ចូលទិនន័យនីមួយៗមានអ្នកគ្រប់គ្រងចំនួន ១នាក់ ដែលអាចគ្រប់គ្រងអ្នកបញ្ចូលទិន្នន័យចំនួន ៦នាក់ ហើយត្រូវបានរាយការណ៍ផ្ទាល់ទៅកាន់អ្នកគ្រប់គ្រង និងពិនិត្យគុណភាពទិន្នន័យ។

រូបភាពទី ១៖ រចនាសម្ព័ន្ធក្រុមស្រាវជ្រាវ



## ការប្រមូលទិន្នន័យ

ដោយសារភាពស្មុគស្មាញនៃកម្រងសំណួរ ហើយការសម្ភាសត្រូវការចំណាយពេលវេលាយូរ (ជាមធ្យមប្រមាណ ៦០នាទី) ដូច្នេះវិធីសាស្ត្រដែលយើងប្រើប្រាស់ក្នុងការប្រមូលទិន្នន័យ គឺការជួបសម្ភាសផ្ទាល់ទល់មុខគ្នា (face-to-face interview)។ អត្ថប្រយោជន៍នៃវិធីសាស្ត្រនេះ គឺផ្តល់ភាពងាយស្រួលអាចឱ្យយើងធានាបាននូវគុណភាពនៃការឆ្លើយតប ដែលអនុញ្ញាតឱ្យការប្រមូលទិន្នន័យព័ត៌មានទាំងបរិមាណ និងគុណភាពស្តីពីតម្រូវការកម្លាំងពលកម្ម គម្លាត និងកង្វះជំនាញសម្រាប់ប្រភេទមុខរបរនៅលើទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគត។

គោលដៅដែលជាក្រុមអ្នកតបសម្ភាសរបស់យើងគឺតំណាងសហគ្រាស គ្រឹះស្ថានដែលក្នុងនោះអាចជាម្ចាស់ឬដៃគូភាគហ៊ុន នាយកប្រតិបត្តិ អ្នកគ្រប់គ្រងទូទៅ អ្នកគ្រប់គ្រងផលិតកម្ម ប្រធានផ្នែកធនធានមនុស្ស និងប្រធានផ្នែកគ្រប់គ្រងជាន់ខ្ពស់ផ្សេងទៀត ដែលមានចំណេះដឹង និងយល់ច្បាស់ពីស្ថានភាពសហគ្រាស គ្រឹះស្ថានរបស់ខ្លួនដែលទាក់ទងទៅនឹងព័ត៌មានប្រជាសាស្ត្រ ចំនួនកម្មករនិយោជិត ការយល់ឃើញរបស់កម្មករនិយោជិតដែលជាអ្នកស្វែងរកការងារជាលើកដំបូង តួនាទីដែលទំនេរ គម្លាតជំនាញ និងកង្វះខាតជំនាញ។

## ការគ្រប់គ្រងទិន្នន័យ និងនីតិវិធីត្រួតពិនិត្យគុណភាព

នីតិវិធីនៃការគ្រប់គ្រង និងត្រួតពិនិត្យគុណភាពទិន្នន័យ ត្រូវបានបង្កប់នៅក្នុងដំណើរការសំខាន់ៗនៃសកម្មភាពអនុវត្តការអង្កេត ការបង្កើតកម្រងសំណួរ ការបណ្តុះបណ្តាល និងការសម្ភាសសាកល្បង (Pilot-test) ការសម្ភាសផ្ទាល់តាមរយៈការត្រួតពិនិត្យផ្ទាល់ និងនៅការិយាល័យតាមរយៈការពិនិត្យមើលកម្រងសំណួរដែលបានបញ្ចប់។




- ការបង្កើតកម្រងសំណួរ និងសំណួរដែលត្រូវរំលង (Skip-Logic rules) មានការសរសេរណែនាំច្បាស់លាស់ពីទិន្នន័យ ឬតួលេខដែលត្រូវកត់ត្រា ឬវាយបញ្ចូល។
- អ្នកគ្រប់គ្រងគម្រោង អ្នកគ្រប់គ្រងនិងពិនិត្យគុណភាពទិន្នន័យ អ្នកគ្រប់គ្រងក្រុមសម្ភាស អ្នកគ្រប់គ្រងក្រុមបញ្ចូលទិន្នន័យ អ្នកសម្ភាស អ្នកបញ្ចូលទិន្នន័យ និងភាគីទាំងអស់ដែលពាក់ព័ន្ធក្នុងការអង្កេតគឺតម្រូវឱ្យចូលរួមវគ្គបណ្តុះបណ្តាលបញ្ជីសំណួរ ក្រមសីលធម៌ នីតិវិធីប្រមូលទិន្នន័យ រួមទាំងការជ្រើសរើស និងការ

ជំនួសសំណាក ដើម្បីអាចកាត់បន្ថយភាពលំអៀង និងធានាឱ្យបាននូវទិន្នន័យប្រកបដោយគុណភាព ភាពត្រឹមត្រូវ និងភាពដែលអាចទុកចិត្តបាន។

- ការបណ្តុះបណ្តាល និងការយល់ឱ្យបានច្បាស់ពីបញ្ជីសំណួរមុនពេលចាប់ផ្តើមចុះអនុវត្តការសម្ភាសផ្ទាល់គឺជាគោលការណ៍ចាំបាច់ដែលមិនអាចខ្វះបាន ដើម្បីធានាឱ្យបាននូវគុណភាពនៃបញ្ជីសំណួរទាំងការសួរ ការឆ្លើយតប ការកត់ត្រា ការសម្រេចចិត្ត និងកំណត់ចំណាំផ្សេងៗ ដែលអាចនឹងកើតមានឡើងក្នុងដំណើរការនៃការសម្ភាស។
- ការសម្ភាសសាកល្បង (Pilot-test) ក្នុងការធានាបាននូវការយល់ដឹងច្បាស់ពីបញ្ជីសំណួរ អ្នកសម្ភាសតម្រូវឱ្យមានការហ្វឹកហ្វឺន និងអនុវត្តក្នុងពេលសម្ភាសសាកល្បង។ ការផ្តល់មតិយោបល់ត្រឡប់ (Feedback session) ក្រោយពីការសម្ភាសសាកល្បងត្រូវបានធ្វើឡើង ដើម្បីបញ្ជាក់ចំណុចមិនច្បាស់លាស់ណាមួយ ហើយការបណ្តុះបណ្តាលបន្ថែមត្រូវបានផ្តល់ជូន ប្រសិនបើចាំបាច់ ឬត្រូវបានសង្កេតឃើញថាមានភាពមិនស្របគ្នាក្នុងចំណោមអ្នកសម្ភាស។
- ដោយសារការអង្កេតនេះ យើងប្រើប្រាស់ជាក្រដាសបញ្ជីសំណួរ (hard questionnaire) ដូចនេះ រាល់បញ្ជីសំណួរ ដែលបានសម្ភាសរួចត្រូវធ្វើការសម្អាត (clean questionnaire) ឱ្យបានរួចរាល់ត្រឹមត្រូវជាមុនសិន មុននឹងក្រុមការងារបញ្ជូន ឬធ្វើជាទម្រង់ PDF ទៅកាន់អ្នកគ្រប់គ្រង និងពិនិត្យគុណភាពទិន្នន័យ ហើយក្រដាសបញ្ជីសំណួរទាំងអស់ត្រូវប្រមូល និងបញ្ជូនត្រឡប់មកភ្នំពេញវិញ ក្រោយពេលការប្រមូលទិន្នន័យត្រូវបានបិទបញ្ចប់។ ការបញ្ជូន ឬធ្វើបញ្ជីសំណួរជាទម្រង់ PDF គឺតម្រូវឱ្យធ្វើជារៀងរាល់ថ្ងៃ ដើម្បីអាចឱ្យអ្នកគ្រប់គ្រង និងពិនិត្យគុណភាពទិន្នន័យ មានពេលគ្រប់គ្រាន់នៅក្នុងការពិនិត្យ និងអាចផ្តល់មតិយោបល់ត្រឡប់ឱ្យទាន់ពេលវេលា។
- ក្រោយពីការបិទបញ្ចប់ការប្រមូល និងបញ្ចូលទិន្នន័យរួចរាល់ អ្នកគ្រប់គ្រង និងពិនិត្យគុណភាពទិន្នន័យត្រូវសម្អាត និងត្រួតពិនិត្យរាល់ទិន្នន័យណាដែលមិនប្រក្រតី ហើយធ្វើការផ្ទៀងផ្ទាត់ ឬអាចខលសាកសួរត្រឡប់ទៅកាន់អ្នកឆ្លើយតបសម្ភាសដើម្បីបញ្ជាក់ និងទទួលបានទិន្នន័យជាក់លាក់។

បន្ទាប់ពីសម្អាតទិន្នន័យរួចរាល់ ក្រុមការងារប្រើប្រាស់កម្មវិធី STATA និង Excel សម្រាប់ការវិភាគ និងការធ្វើក្រាហ្វិក ឬតារាងផ្សេងៗទៅតាមតម្រូវការប្រើប្រាស់ជាក់ស្តែង។

## ការវិភាគទិន្នន័យ

ទិន្នន័យអង្កេត ដែលជាចំនួនសហគ្រាស គ្រឹះស្ថាន ត្រូវបានកែសម្រួលដោយដាក់មេគុណ (Weighted) យោងតាមចំនួនដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យលទ្ធផលអង្កេតអាចតំណាងឱ្យសេដ្ឋកិច្ចក្នុងប្រព័ន្ធទូទាំងប្រទេស ដែលស្មើនឹងចំនួន ៨ ២៨៤សហគ្រាស គ្រឹះស្ថាន និងចំនួនកម្មករ និយោជិត ១ ៤១២ ៥៨០នាក់ (សម្រាប់តែវិស័យ និងតំបន់ដែលបានជ្រើសរើស) (តារាងទី៣)។

តារាងទី ៣៖ ចំនួនសហគ្រាស គ្រឹះស្ថាន និងចំនួនកម្មករ និយោជិតតំណាងឱ្យសំណាកគំរូ

| វិស័យ | សហគ្រាស គ្រឹះស្ថាន | កម្មករ និយោជិត |
|---|---|---|
| ស្នាក់នៅ និងភោជនីយដ្ឋាន | 628 | 39,883 |
| សំណង់ | 1,179 | 36,342 |
| ការអប់រំ | 517 | 28,266 |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 2,680 | 103,299 |
| វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប | 1,252 | 934,629 |
| សេវាថែទាំសុខភាព | 197 | 6,436 |
| បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) | 133 | 2,953 |
| ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី | 114 | 53,782 |
| ផលិតអាហារ និងភេសជ្ជៈ | 166 | 15,955 |
| ផលិតកៅស៊ូ និងប្លាស្ទិក | 141 | 25,022 |
| ផលិតផលិតផលឈើ និងក្រដាស | 95 | 17,655 |
| កម្មន្តសាលផ្សេងៗ | 826 | 131,104 |
| ការដឹកជញ្ជូន និងស្តុកទំនិញ | 356 | 17,254 |
| សរុប | 8,284 | 1,412,580 |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ

សន្ទស្សន៍នៃទស្សនវិស័យការងារត្រូវបានគណនាដោយដាក់មេគុណ (Weighted) តាមរយៈការវាយតម្លៃរបស់ប្រធានមជ្ឈមណ្ឌលការងារតាមបណ្តារាជធានី ខេត្ត (២០%) និងលទ្ធផលពីអង្កេត (៨០%)។ ប្រភេទមុខរបរតាមស្តង់ដាចំណាត់ថ្នាក់មុខរបរ (ISCO-08) របស់អង្គការអន្តរជាតិខាងការងារ (ILO) ត្រូវបានបញ្ចូលទៅជា ៥ ផ្នែកសំខាន់ៗដូចតទៅ៖ ១) ផ្នែករដ្ឋបាល និងធនធានមនុស្សសម្រាប់គ្រប់វិស័យ ២) ផ្នែកហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្ម (ក្រៅពីវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង) ៣) ផ្នែកលក់ និងទីផ្សារ (ក្រៅពីវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង) ៤) ផ្នែកជួសជុល ថែរក្សា និងគាំទ្រទូទៅ (គ្រប់វិស័យ) និង៥) ផ្នែកគាំទ្របច្ចេកទេសឌីជីថល (ក្រៅពីវិស័យ ICT) និងមុខរបរតាមអនុវិស័យទាំង ១៣ សំខាន់ៗដូចជា៖ ១) បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) ២) សេវាស្នាក់នៅ និងភោជនីយដ្ឋាន ៣) សំណង់ ៤) អប់រំ ៥) ហិរញ្ញវត្ថុ និងធានារ៉ាប់រង ៦) សេវាថែទាំសុខភាព ៧) វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ៨) ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី, ៩) ផលិតអាហារ និងភេសជ្ជៈ, ១០) ផលិតជ័រកៅស៊ូ និងប្លាស្ទិក, ១១) ផលិតផលិតផលឈើ និងក្រដាស, ១២) កម្មន្តសាលផ្សេងៗ និង១៣) ដឹកជញ្ជូន និងស្តុកទំនិញ។

## ការវាយតម្លៃ ការបកស្រាយសន្ទស្សន៍មុខរបរ និងលក្ខណវិនិច្ឆ័យ

- សន្ទស្សន៍នេះបង្ហាញអំពីស្ថានភាព (ងាយស្រួល/ពិបាក) ជ្រើសរើសកម្មករ និយោជិតបច្ចុប្បន្នសម្រាប់និយោជកក្នុងមុខតំណែងជាក់លាក់មួយ ដែលរំពឹងទុករយៈពេល ៦ខែខាងមុខ និងឱកាសការងារសម្រាប់អ្នកស្វែងរកការងារ ដែលមានជំនាញដូចនឹងមុខរបរដែលកំពុងជ្រើសរើស។
- ការវាយតម្លៃរបស់និយោជក ក្នុងការជ្រើសរើសកម្មករនិយោជិតត្រូវបានធ្វើឡើងតាមមាត្រដ្ឋានដូចខាងក្រោម៖ ១ = ងាយស្រួលខ្លាំងក្នុងការជ្រើសរើស ២ = ងាយស្រួលជ្រើសរើស ៣ = ធម្មតា (មានតុល្យភាពរវាងការផ្គត់ផ្គង់ និងតម្រូវការ) ៤ = ពិបាកជ្រើសរើស និង ៥ = ពិបាកខ្លាំងក្នុងការជ្រើសរើស។
- ការវាយតម្លៃនៃភាពងាយស្រួល ឬងាយស្រួលខ្លាំងក្នុងការជ្រើសរើស (តម្លៃនៃ ១ ឬ ២) បង្ហាញថាអ្នកស្វែងរកការងារធ្វើមានឱកាសទាបក្នុងការទទួលបានការងារ ដែលបណ្តាលមកពីភាពប្រកួតប្រជែងខ្ពស់ក្នុងចំណោមអ្នកស្វែងរកការងារក្នុងប្រភេទមុខរបរដូចគ្នា។
- ការវាយតម្លៃពីការលំបាក ឬលំបាកជ្រើសរើសខ្លាំង (តម្លៃនៃ ៤ ឬ ៥) បង្ហាញថាអ្នកស្វែងរកការងារធ្វើមានឱកាសខ្ពស់ក្នុងការទទួលបានការងារ ដែលបណ្តាលមកពីភាពប្រកួតប្រជែងតិចក្នុងចំណោមអ្នកស្វែងរកការងារក្នុងប្រភេទមុខរបរដូចគ្នា។

លទ្ធផលត្រូវបានចាត់ថ្នាក់តាមប្រភេទដូចខាងក្រោម៖

- ប្រសិនបើតម្លៃសន្ទស្សន៍សម្រាប់មុខរបរមួយគឺទាបជាង ២,៨ មានន័យថា៖ ឱកាសតិចក្នុងការទទួលបានការងារសម្រាប់ប្រភេទមុខរបរដូចគ្នា
- ប្រសិនបើវាស្ថិតនៅចន្លោះ ២,៨ និង ៣,២ មានន័យថា៖ ឱកាសធម្មតា ដែលមានតុល្យភាពរវាងការផ្គត់ផ្គង់ និងតម្រូវការ
- ប្រសិនបើតម្លៃសន្ទស្សន៍លើសពី ៣,២ មានន័យថា៖ ឱកាសការងារខ្ពស់ក្នុងការទទួលបានការងារសម្រាប់ប្រភេទមុខរបរដូចគ្នា។

ការវាយតម្លៃមុខរបរដែលមានឱកាសការងារល្អ ត្រូវបានពឹងផ្អែកលើលក្ខណវិនិច្ឆ័យសំខាន់ៗចំនួន៥ ដូចជាស្ថានភាពជ្រើសរើសបុគ្គលិក ដង់ស៊ីតេដំណឹងជ្រើសរើសបុគ្គលិក ប្រាក់ឈ្នួល កំណើនការងារ និងកំណើនរបស់វិស័យ។ រាល់ការជ្រើសរើសមុខរបរដែលមានតម្រូវការទីផ្សារខ្ពស់ និងឱកាសការងារល្អត្រូវបានពឹងផ្អែកលើលក្ខណវិនិច្ឆ័យទាំង៥ ដូចក្នុងតារាងខាងក្រោម។

### តារាងទី ៤៖ លក្ខណវិនិច្ឆ័យចំនួន ៥ សម្រាប់ចាត់ថ្នាក់មុខរបរដែលមានតម្រូវការខ្ពស់

| លក្ខណវិនិច្ឆ័យ | ការពិពណ៌នា |
|---|---|
| **ស្ថានភាពជ្រើសរើសបុគ្គលិក ឬឱកាសការងារសម្រាប់មុខរបរដែលមានឱកាសខ្ពស់** | ការវាយតម្លៃស្ថានភាពជ្រើសរើសបុគ្គលិកត្រូវបានគណនាឡើងពី២ប្រភពទិន្នន័យរួមមាន ទិន្នន័យជ្រើសរើសបុគ្គលិករបស់មជ្ឈមណ្ឌលការងាររាជធានី ខេត្តទាំង ១៣ របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងពីការអង្កេតដែលក្រសួងបានធ្វើលើសហគ្រាស គ្រឹះស្ថានចំនួន ៦៣៨។ បន្ថែមពីនេះ លទ្ធផលសន្ទស្សន៍នេះក៏ត្រូវបានឆ្លងកាត់ការផ្តល់មតិយោបល់ និងវាយតម្លៃពីសំណាក់អ្នកជំនាញខាងធនធានមនុស្សផងដែរ មុននឹងសម្រេចចេញជាសន្ទស្សន៍ឱកាសការងារសម្រាប់មុខរបរនីមួយៗ។ ជាលទ្ធផលសន្ទស្សន៍នេះត្រូវបានយកមកធ្វើជាព័ត៌មានមូលដ្ឋានក្នុងការជ្រើសរើសមុខរបរដែលមានឱកាសការងារល្អ។ |
| **ដង់ស៊ីតេដំណឹងជ្រើសរើសបុគ្គលិក** | ការគណនាសន្ទស្សន៍ឱកាសការងារនេះ ត្រូវបានដាក់ទម្ងន់ជាមួយនឹងដង់ស៊ីតេដំណឹងជ្រើសរើសបុគ្គលិកទៅតាមមុខរបរនីមួយៗ។ សម្រាប់ការជ្រើសរើសមុខតំណែង ក៏ត្រូវបានពិចារណាលើចំនួនជ្រើសរើសបុគ្គលិក និងសន្ទស្សន៍ឱកាសការងារទៅតាមមុខរបរនីមួយៗ។ ចំនួននៃការប្រកាសការងារ និងសន្ទស្សន៍ឱកាសការងារនេះ ពឹងផ្អែកលើកត្តាសំខាន់ពីរដែលត្រូវបានពិចារណានៅពេលជ្រើសរើសមុខតំណែង គឺចំនួននៃការប្រកាសការងារដែលផ្តល់នូវការចង្អុលបង្ហាញដោយផ្ទាល់នៃតម្រូវការ និងសន្ទស្សន៍ឱកាសការងារដែលផ្តល់នូវការវាយតម្លៃលើស្ថានភាពជ្រើសរើស។ |
| **ប្រាក់ឈ្នួលប្រចាំខែ** | ទិន្នន័យប្រាក់ឈ្នួលប្រចាំខែត្រូវបានគណនាឡើងដោយការដាក់មេគុណទៅលើចំនួនអ្នកមានការងារក្នុងមុខរបរដូចគ្នា រួចគណនាជាមធ្យមសម្រាប់មុខតំណែងនីមួយៗ និងត្រូវបានកែសម្រួលជាមួយទិន្នន័យរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ។ ប្រាក់ឈ្នួលដែលបានផ្តល់តំណាងឱ្យតួលេខជាមធ្យម ហើយប្រាក់ឈ្នួលជាក់ស្តែងអាចប្រែប្រួលអាស្រ័យលើកត្តាដូចជា បទពិសោធន៍ ការអប់រំ និងទំហំក្រុមហ៊ុន។ |
| **កំណើនការងារ** | ការជ្រើសរើសមុខរបរដែលមានសក្តានុពលខ្ពស់ត្រូវបានពឹងផ្អែកលើកំណើនការងារតាមមុខរបរដែលបានព្យាករចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CSES) និងចំនួនការងារបន្ថែមពីគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (Qualified Investment Projects – QIPs) អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ការព្យាករនេះបង្ហាញពីតម្រូវការកម្មករ និយោជិតនាពេលខាងមុខសម្រាប់មុខរបរជាក់លាក់។ |
| **កំណើនរបស់វិស័យ** | លក្ខណវិនិច្ឆ័យនេះគឺផ្អែកលើការព្យាករនៃកំណើនក្នុងវិស័យសេដ្ឋកិច្ចផ្សេងៗគ្នា ដែលប្រើប្រាស់ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ វាឆ្លុះបញ្ចាំងពីស្ថានភាពទូទៅរបស់សេដ្ឋកិច្ច និងផលប៉ះពាល់ទៅលើឱកាសការងារក្នុងវិស័យផ្សេងៗ។ |

## ភាពខ្វះខាតនៃការអង្កេត

អង្កេតនេះមានចំណុចខ្វះខាតមួយចំនួន រួមទាំងលទ្ធភាពលំអៀងនៃការឆ្លើយតបពីអ្នកឆ្លើយសំណួរ ដោយសារកត្តាតម្រូវការសង្គម ភាពលំអៀងនៃការទទួលស្គាល់អ្វីមួយ ភាពលំអៀងនៃការចងចាំលើទិន្នន័យចាស់ៗ ឬកត្តាវប្បធម៌ជាដើម។ លើសពីនេះ ការដាក់លេខកូដ ISCO-08 ឱ្យត្រឹមត្រូវនូវមុខរបរក៏ជាបញ្ហាប្រឈមផងដែរ ដោយសារភាពស្មុគស្មាញនៃប្រព័ន្ធចាត់ថ្នាក់ និងលក្ខណៈនៃការវិវត្តការងារ ដែលនាំឱ្យដំណើរការអង្កេតចំណាយពេលយូរ។

ដើម្បីដោះស្រាយដែនកំណត់ទាំងនេះ ការអង្កេតនាពេលអនាគតអាចពិចារណាលើការពង្រីកទំហំសំណាកគំរូ ការអនុវត្តវិធានការត្រួតពិនិត្យលើគុណភាពឱ្យកាន់តែតឹងរ៉ឹង ប្រើប្រាស់បច្ចេកវិទ្យាក្នុងការប្រមូលទិន្នន័យ និងការវិភាគផ្អែកលើបច្ចេកវិទ្យា និងបង្កើតប្រព័ន្ធសរសេរកូដ ISCO-08 ស្តង់ដា។ តាមរយៈដំណោះស្រាយទាំងនេះ ការអង្កេតនាពេលអនាគតអាចធ្វើឱ្យប្រសើរឡើងនូវភាពត្រឹមត្រូវ និងភាពជឿជាក់នៃទិន្នន័យដែលបានប្រមូល និងផ្តល់នូវការយល់ដឹងដ៏រឹងមាំបន្ថែមទៀតរបស់ទីផ្សារការងារនៅកម្ពុជា។

## គោលបំណងនៃអង្កេត

របាយការណ៍ស្តីពី «ទស្សនវិស័យការងារកម្ពុជា ឆមាសទី១ ឆ្នាំ២០២៥» គឺជារបាយការណ៍ស្តីពីការព្យាករមុខរបរ និងការងារ និងជាផ្នែកមួយនៃការព្យាករស្ថានភាពទីផ្សារការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ របាយការណ៍នេះបង្ហាញពីនិន្នាការការងារ និងការពិពណ៌នាយ៉ាងក្បោះក្បាយអំពីឱកាសការងារសម្រាប់មុខរបរផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជាប្រចាំឆមាសទី១ ឆ្នាំ២០២៥។

លទ្ធផលនៃរបាយការណ៍នេះគឺផ្អែកលើទស្សននិយោជក និងអ្នកជំនាញផ្នែកធនធានមនុស្ស ដែលជាលទ្ធផលត្រូវបានផ្តល់មេគុណដែលនិយោជកបានធ្វើការវាយតម្លៃ (៨០%) និងការវាយតម្លៃរបស់ប្រធានមជ្ឈមណ្ឌលទីភ្នាក់ងារជាតិមុខរបរ និងការងាររាជធានី ខេត្ត (២០%)។ វិធីសាស្ត្រនេះធានាថា សន្ទស្សន៍នៃការសិក្សា ឆ្លុះបញ្ចាំងពីទិដ្ឋភាពទីផ្សារការងារកម្ពុជា។

## រចនាសម្ព័ន្ធនៃរបាយការណ៍

របាយការណ៍នេះ ត្រូវបានបែងចែកជា ៣ជំពូក ដើម្បីផ្តល់ជូននូវការវិភាគយ៉ាងទូលំទូលាយអំពីទីផ្សារការងារនៅកម្ពុជា។ ជំពូកទី ១ បង្ហាញពីសូចនាករសេដ្ឋកិច្ចជាតិ និងអន្តរជាតិសំខាន់ៗ ក៏ដូចជានិន្នាការទីផ្សារការងារបច្ចុប្បន្ន។ ជំពូកនេះ ផ្តល់ព័ត៌មាន និងនិន្នាការមួយចំនួនដូចជា កំណើន ផ.ស.ស. ការវិនិយោគផ្ទាល់ពីបរទេស សក្តានុពល និងឱកាសក្នុងទីផ្សារការងារ និងការព្យាករវិស័យការងារមួយចំនួន។

ជំពូកទី ២ ផ្តោតលើការរំពឹងទុកនៃមុខរបរសរុបចំនួន ២៥៦ សម្រាប់ឆមាសទី១ ឆ្នាំ២០២៥។ ជំពូកនេះបានផ្តល់នូវលទ្ធផលអង្កេតលម្អិតអំពីតម្រូវការការងារ កម្រិតប្រាក់ឈ្នួល និងបញ្ហាប្រឈមសក្តានុពលនៅក្នុងអនុវិស័យនីមួយៗ។ ជំពូកនេះមានសារៈសំខាន់ សម្រាប់អ្នកស្វែងរកការងារ និយោជក អ្នកផ្តល់ការបណ្តុះបណ្តាល និងអ្នកតាក់តែងគោលនយោបាយ ដែលបានផ្តល់ព័ត៌មានសំខាន់ៗដូចជា និន្នាការឧស្សាហកម្ម ឱកាសការងារដែលកំពុងរីកចម្រើន និងជំនាញសំខាន់ៗក្នុងការអភិវឌ្ឍគន្លងអាជីព។

ជាចុងក្រោយ ជំពូកទី ៣ បានធ្វើសេចក្តីសន្និដ្ឋានចេញពីលទ្ធផលសំខាន់ៗនៃបាយការណ៍ ដែលជំពូកនេះមានគោលបំណង ផ្តល់ជូនអ្នកស្វែងរកការងារនូវការយល់ដឹង និងព័ត៌មានចាំបាច់ដើម្បីធ្វើការសម្រេចចិត្ត និងស្វែងយល់ទីផ្សារការងារនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព។

# ជំពូកទី ១ សេដ្ឋកិច្ចសកលក្នុងឆ្នាំ២០២៥ និងផលប៉ះពាល់នៃសេដ្ឋកិច្ចសកលមកលើកម្ពុជា

## ១.១ ទស្សនវិស័យសេដ្ឋកិច្ចសកលឆ្នាំ២០២៥

សេដ្ឋកិច្ចសកលក្នុងឆ្នាំ២០២៥ ត្រូវបានព្យាករថានឹងមានកំណើនមធ្យម ប៉ុន្តែជាកំណើនប្រកបដោយស្ថិរភាព ក្នុងអត្រាចន្លោះ ពី ២,៥% ទៅ ៣,៣% [1]។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករពីអត្រាកំណើនថេរក្នុងអត្រា ៣,២% សម្រាប់ឆ្នាំ២០២៤ និងឆ្នាំ២០២៥ [2]។ ស្ថិរភាពនៃសេដ្ឋកិច្ចនេះត្រូវបានកំណត់ដោយកត្តាមួយចំនួនដូចជា ការគ្រប់គ្រងបាននូវអត្រាអតិផរណា ការបន្តឡើងនៃកំណើនការងារ និងការបន្ថយសម្ពាធនៃបញ្ហាខ្សែប្រវាក់ផ្គត់ផ្គង់ [1]។ ទោះជាយ៉ាងណាក៏ដោយ កំណើននេះនៅតែស្ថិតនៅទាបជាងកំណើនមុនវិបត្តិជំងឺកូវីដ-១៩។ ជាមួយគ្នានេះ IMF ក៏បានព្យាករថាអត្រាអតិផរណាសកលលោកនឹងធ្លាក់ចុះពី ៦,៧% នៅឆ្នាំ២០២៣ ដល់ ៥,៨% នៅឆ្នាំ២០២៤ និង ៤,៣% នៅឆ្នាំ២០២៥ [3]។ ធនាគារពិភពលោក (World Bank) ក៏បានផ្តល់នូវទស្សនវិស័យសេដ្ឋកិច្ចសកលស្រដៀងគ្នានេះដែរ។

ទស្សនវិស័យសេដ្ឋកិច្ចសកលឆ្នាំ២០២៥ ជារួមមានភាពវិជ្ជមាន ប៉ុន្តែក៏មាននូវហានិភ័យសំខាន់ៗជាច្រើនកំពុងកើតឡើង។ ក្តីបារម្ភចម្បងមួយគឺការកើនឡើងនៃគោលនយោបាយគាំពារនិយម ដែលជាគោលនយោបាយសេដ្ឋកិច្ច ជាពិសេសពីសហរដ្ឋអាម៉េរិកតាមរយៈការដំឡើងពន្ធនាំចូលដែលរំខានដល់លំហូរពាណិជ្ជកម្មសកល និងការឡើងថ្លៃប្រេងឥន្ធនៈ។ សេដ្ឋកិច្ចរបស់ប្រទេសចិន ក៏ជាកត្តាសំខាន់មួយទៀត ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ចធំជាងគេទីពីររបស់ពិភពលោកអាចជះឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងតំបន់ និងលើសពីនេះ អាចជះឥទ្ធិពលដល់ការរំពឹងទុកនៃកំណើនសេដ្ឋកិច្ចសកល។

ការបន្ថែមលើភាពស្មុគស្មាញនេះ ភាពតានតឹងភូមិសាស្ត្រនយោបាយ និងសង្គ្រាមកំពុងបន្តមាននៅតំបន់មួយចំនួន ដែលគំរាមកំហែងដល់ស្ថិរភាពសកលលោក និងរំខានដល់សកម្មភាពសេដ្ឋកិច្ចបន្ថែមទៀត។ បម្រែបម្រួលអាកាសធាតុក៏អាចបង្កជាហានិភ័យដែលគួរយកចិត្តទុកដាក់ផងដែរ ដោយបញ្ហាអាកាសធាតុធ្ងន់ធ្ងរ និងការកើនឡើងនៃសីតុណ្ហភាពសកលអាចរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ បំផ្លាញហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឱ្យមានបញ្ហាប្រឈមចំពោះសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ។ កំណើនអត្រាអ្នកអត់ការងារធ្វើកាន់តែខ្ពស់ ជាពិសេសនៅក្នុងប្រទេសដែលរងផលប៉ះពាល់ដោយភាពតានតឹងផ្នែកពាណិជ្ជកម្មគឺជាកង្វល់ដ៏ធំមួយ។ ការកើនឡើងនៃចំនួនអ្នកអត់ការងារធ្វើ អាចកំណត់នូវកំណើនសេដ្ឋកិច្ច ប៉ះពាល់ដល់សំណាញ់សុវត្ថិភាពសង្គម និងអាចនាំឱ្យមានភាពចលាចលក្នុងសង្គម។ បញ្ហាចាក់ស្រេះ និងស្មុគស្មាញទាំងនេះ បង្ហាញពីភាពផុយស្រួយនៃការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក និងគូសបញ្ជាក់អំពីតម្រូវការសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ និងវិធានការគោលនយោបាយដែលសកម្ម ដើម្បីកាត់បន្ថយការគំរាមកំហែងដែលអាចកើតមាន។

## ១.២ ស្ថានភាពសេដ្ឋកិច្ច និងសក្ដានុពលនៃកំណើនសេដ្ឋកិច្ចកម្ពុជា

សេដ្ឋកិច្ចប្រទេសកម្ពុជាត្រូវបានព្យាករថានឹងមានកំណើន ៦,៣% នៅឆ្នាំ២០២៥ ដែលជំរុញដោយវិស័យឧស្សាហកម្ម សេវាកម្ម និងកសិកម្ម។ ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ត្រូវបានគេរំពឹងថានឹងឈានដល់ ៥១,៣៩ ពាន់លានដុល្លារអាម៉េរិក ជាមួយនឹង ផ.ស.ស. សម្រាប់មនុស្សម្នាក់មានចំនួន ២ ៩២៤ដុល្លារអាម៉េរិក ដែលកើនឡើងគួរឱ្យកត់សម្គាល់ពី ២ ៧១៣ដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៤ [៥] ដែលបង្ហាញពីភាពប្រសើរឡើងនៃកម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ វិស័យឧស្សាហកម្មត្រូវបានគេព្យាករថានឹងកើនឡើង ៨,៦% ដែលជំរុញដោយកំណើនដ៏រឹងមាំទាំងក្នុងវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ [៥]។ ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យដឹកជញ្ជូន និងស្តុកទំនិញ ក៏ត្រូវបានគេរំពឹងថានឹងរួមចំណែកដល់កំណើនសេដ្ឋកិច្ចផងដែរ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តថវិកាជាង ៩,៣ ពាន់លានដុល្លារអាម៉េរិកសម្រាប់ការចំណាយក្នុងឆ្នាំ២០២៥ ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ។ ថវិកានេះមានគោលបំណងគាំទ្រដល់ការអភិវឌ្ឍស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធ ការកែលម្អការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស និងការធ្វើពិពិធកម្មសេដ្ឋកិច្ច។

វិស័យធំៗទាំងបីត្រូវបានគេរំពឹងថានឹងជំរុញកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជានៅឆ្នាំ២០២៥ ដែលរួមមាន៖

- **វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖** វិស័យនេះដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា ដែលផ្តល់ការងារ និងរួមចំណែកដល់សន្តិសុខស្បៀង។
- **វិស័យឧស្សាហកម្ម៖** វិស័យនេះគ្របដណ្តប់លើឧស្សាហកម្មផ្សេងៗ រួមទាំងវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ដែលត្រូវបានគេរំពឹងថានឹងមានកំណើនជាបន្តបន្ទាប់។
- **វិស័យសេវាកម្ម៖** វិស័យនេះរួមមានវិស័យទេសចរណ៍ ដែលត្រូវបានគេរំពឹងថានឹងងើបឡើងវិញបន្ថែមទៀតក្នុងឆ្នាំ២០២៥ ដែលរួមចំណែកដល់កំណើនសេដ្ឋកិច្ច។

## ១.៣ ស្ថានភាពវិនិយោគកម្ពុជា

### ១.៣.១ ការវិនិយោគផ្ទាល់ពីបរទេស (FDI)

នៅក្នុងឆ្នាំ២០២៤ លំហូរវិនិយោគសកលបានថយចុះប្រមាណ ២% ពី ១ ៣៥៦ប៊ីលានដុល្លារអាម៉េរិក មកត្រឹម ១ ៣៣២ប៊ីលានដុល្លារអាម៉េរិក ដោយសារការព្រួយបារម្ភរបស់វិនិយោគិនពីសេដ្ឋកិច្ច និងសក្តានុពលនៃបញ្ហាប្រឈមនានា ដែលបណ្តាលមកពីភាពតានតឹងភូមិសាស្ត្រនយោបាយ (រូបភាពទី២)។ ភាពមិនច្បាស់លាស់ទាំងនេះបាននាំឱ្យមានការកាត់បន្ថយហិរញ្ញប្បទានសម្រាប់គម្រោងអន្តរជាតិ និងការធុរកិច្ចឆ្លងប្រទេស (cross-border mergers and acquisitions)។ ទោះជាយ៉ាងណាក៏ដោយ ចំនួននៃគម្រោងវិនិយោគលើវិស័យបៃតង (greenfield

investment projects) បានកើនឡើងចំនួន ២% ជាពិសេសនៅក្នុងវិស័យកម្មន្តសាល។ កំណើននេះត្រូវបានគេមើលឃើញនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលចំនួនគម្រោងវិនិយោគថ្មីលើវិស័យបៃតងនេះបានកើនឡើង ១៥%។ ដោយផ្អែកលើកត្តាទាំងនេះ រួមជាមួយនឹងស្ថិរភាពនៃការចំណាយហិរញ្ញវត្ថុ ទស្សនវិស័យនៃកំណើនសេដ្ឋកិច្ចសកលសម្រាប់ឆ្នាំ២០២៤ នឹងអាចមានភាពវិជ្ជមានក្នុងកម្រិតមធ្យម [13]។

រូបភាពទី ២៖ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសតាមតំបន់ ២០២២-២០២៣ (គិតជា ប៊ីលានដុល្លារអាម៉េរិក)




ប្រភព៖ UNCTAD (២០២៤)។

ការវិនិយោគបរទេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅតំបន់អាស៊ីបានធ្លាក់ចុះប្រមាណ ៨% មកនៅត្រឹម ៦២១ពាន់លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៣។ ប្រទេសចិនដែលជាប្រទេសទទួលការវិនិយោគបរទេសធំជាងគេទីពីរបស់ពិភពលោកបានជួបប្រទះនឹងការថយចុះមិនប្រក្រតីនៃលំហូរចូលការវិនិយោគ ប្រមាណ ១៤% មកត្រឹម ១៦៣ពាន់លានដុល្លារអាម៉េរិក។ ដោយឡែក តំបន់អាស៊ីអាគ្នេយ៍គឺជាតំបន់តែមួយគត់ដែលរក្សាកំណើននៃការវិនិយោគផ្ទាល់ពីបរទេសរបស់ខ្លួន ដោយសារតែកំណើនសេដ្ឋកិច្ចដ៏រឹងមាំ និងការភ្ជាប់ខ្សែសង្វាក់តម្លៃសកលយ៉ាងទូលំទូលាយ។

ដោយឡែក កម្ពុជានៅតែបន្តទទួលបានការវិនិយោគដោយផ្ទាល់ពីបរទេស ទោះបីស្ថានភាពសេដ្ឋកិច្ចសកលកំពុងមានភាពមិនប្រាកដប្រជាក៏ដោយ។ ជាក់ស្តែង ការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជាសរុប បានកើនឡើងពី ៤១,០ពាន់លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២១ ដល់ ៥០,៣ពាន់លានដុល្លារអាម៉េរិកនៅពាក់កណ្តាលឆ្នាំ ២០២៤ ដែលបង្ហាញពីទំនុកចិត្តកាន់តែខ្លាំងឡើងពីវិនិយោគិនមកលើសេដ្ឋកិច្ចកម្ពុជា។ អនុវិស័យហិរញ្ញវត្ថុតែងតែទាក់ទាញការវិនិយោគច្រើនជាងគេ ខណៈពេលដែលអនុវិស័យកម្មន្តសាល ជាពិសេសអនុវិស័យវាយនភណ្ឌ កាត់ដេរ

និងផលិតស្បែកជើង ក៏បានបង្ហាញពីកំណើនដ៏រឹងមាំស្របតាមយុទ្ធសាស្ត្រតម្រង់ទិសការនាំចេញរបស់កម្ពុជាផងដែរ។ អនុវិស័យស្នាក់នៅ អចលនទ្រព្យ និងវារីអគ្គីសនី ក៏ទទួលបានការវិនិយោគច្រើនគួរឱ្យកត់សម្គាល់។ យ៉ាងណាមិញ ដើម្បីរក្សាសន្ទុះនេះ និងលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជាលើឆាកតំបន់ និងអន្តរជាតិ ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ មូលធនមនុស្ស និងបរិយាកាសធុរកិច្ចដែលអំណោយផល ពិតជាមានសារៈសំខាន់ ។

រូបភាពទី ៣៖ ទំហំនៃការវិនិយោគផ្ទាល់ពីបរទេសក្នុងប្រទេសកម្ពុជា ២០២២-២០២៤ (គិតជា លានដុល្លារអាម៉េរិក)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា (២០២៤)

### ១.៣.២ គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs) តាមវិស័យ

តាមរយៈរបាយការណ៍ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ចំនួនគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs) ក្នុងវិស័យឧស្សាហកម្មបានងើបឡើងវិញដែលមានសន្ទុះយ៉ាងឆាប់រហ័សក្រោយការរាតត្បាតនៃជំងឺកូវីដ-១៩ ដោយកើនពី ១៦៩គម្រោង ក្នុងឆ្នាំ២០២១ ទៅដល់ ៤១៤គម្រោង ក្នុងឆ្នាំ២០២៤។ រីឯចំនួនគម្រោង QIPs ក្នុងវិស័យកសិកម្ម និងកសិឧស្សាហកម្មហាក់មានកំណើនថេរ ខណៈពេលដែលវិស័យសេវាកម្មទទួលបានគម្រោងវិនិយោគថ្មីតិចជាងមុនការរាតត្បាតនៃជំងឺកូវីដ-១៩ (រូបភាពទី៤)។ បន្ថែមពីនេះ គម្រោង QIPs ទាំងនោះ អាចបង្កើតការងារប្រមាណ ៣០៧ពាន់កន្លែង ក្នុងឆ្នាំ២០២៣ និងប្រមាណ ៣២៥ពាន់កន្លែង ក្នុងឆ្នាំ២០២៤ ដែលក្នុងនោះវិស័យឧស្សាហកម្មមានចំណែកច្រើនជាងវិស័យផ្សេងទៀត ស្មើនឹងប្រមាណ ៣០៧ពាន់កន្លែង (រូបភាពទី៥)។

រូបភាពទី ៤៖ ចំនួនគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមវិស័យ ២០១៩-២០២៤




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។

រូបភាពទី ៥៖ ចំនួនការងារដែលបង្កើតដោយគម្រោង QIPs តាមវិស័យ ២០១៩-២០២៤ (គិតជា ពាន់)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។

សរុបមក កំណើននៃគម្រោងវិនិយោគ QIPs និងកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មបានបង្ហាញពីតម្រូវការកម្លាំងពលកម្មដែលមានជំនាញកាន់តែខ្ពស់នាពេលអនាគត ដើម្បីគាំទ្រដល់ការវិវត្តដ៏ឆាប់រហ័សនៃវិស័យនេះ ក៏ដូចជាការផ្លាស់ប្តូរនៃនិន្នាការតម្រូវការកម្លាំងពលកម្មសកល។

## ១.៤ ឥទ្ធិពលនៃនិន្នាការសេដ្ឋកិច្ចពិភពលោកមកលើកម្ពុជា

### ១.៤.១ កត្តាប្រឈម

បរិការណ៍សេដ្ឋកិច្ចសកលឆ្នាំ២០២៥ ត្រូវបានរំពឹងថានឹងមានផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានលើសេដ្ឋកិច្ចកម្ពុជា។ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានគេរំពឹងថានឹងបន្តកើនឡើងក្នុងឆ្នាំ ២០២៥ ប៉ុន្តែមានកំណើនយឺតជាងមុនវិបត្តិជំងឺរាតត្បាតកូវីដ-១៩។ ហានិភ័យនានាដែលអាចមានឥទ្ធិពលដល់កម្ពុជារួមមាន៖

- **ការធ្លាក់ចុះនៃសេដ្ឋកិច្ចសកល៖** ការធ្លាក់ចុះនៃសេដ្ឋកិច្ចសំខាន់ៗ ជាពិសេសនៅសហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុបអាចជះឥទ្ធិពលអវិជ្ជមានដល់ការនាំចេញផលិតផលឧស្សាហកម្មកម្ពុជា ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ចទាំងនេះអាចនាំឱ្យមានការកាត់បន្ថយការចំណាយរបស់អ្នកប្រើប្រាស់។
- **ភាពតានតឹងផ្នែកពាណិជ្ជកម្ម៖** ការកើនឡើងនូវលទ្ធិគាំពារនិយម និងភាពតានតឹងពាណិជ្ជកម្មអាចរំខានដល់ការនាំចូលទៅកាន់ទីផ្សារនាំចេញសំខាន់ៗរបស់ប្រទេសកម្ពុជា។
- **ភាពតានតឹងផ្នែកហិរញ្ញវត្ថុ៖** ការរឹតបន្តឹងហិរញ្ញវត្ថុសកល និងកម្រិតបំណុលកើនឡើងអាចបង្កហានិភ័យដល់វិស័យហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា។
- **ការប្រែប្រួលតម្លៃទំនិញ៖** ការប្រែប្រួលតម្លៃទំនិញសកល ជាពិសេសតម្លៃប្រេង និងអាហារអាចប៉ះពាល់ដល់អតិផរណា និងការចំណាយនៅកម្ពុជា។

វិស័យសេដ្ឋកិច្ចសំខាន់ៗ និងផលប៉ះពាល់កំណើនសេដ្ឋកិច្ចកម្ពុជា រួមមាន៖ វិស័យកាត់ដេរ ទេសចរណ៍ កសិកម្ម និងសំណង់ [12]។

តារាងទី ៥៖ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ពីទស្សនវិស័យសេដ្ឋកិច្ចសកលតាមវិស័យសំខាន់ៗ

| វិស័យ | ការពិពណ៌នា | ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ពីទស្សនវិស័យសេដ្ឋកិច្ចសកល |
|---|---|---|
| វាយនភណ្ឌ សម្លៀកបំពាក់ | ជាវិស័យនាំចេញដ៏ធំបំផុត ដែលជាចំណែកដ៏សំខាន់នៃផលិតផលក្នុងស្រុកសរុបនិងកំណើនការងារ។ | ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកអាចកាត់បន្ថយតម្រូវការសម្លៀកបំពាក់កម្ពុជា ដោយសារការធ្លាក់ចុះការចំណាយរបស់អតិថិជនក្នុងទីផ្សារនាំចេញធំៗ។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើនសមាហរណកម្មក្នុងតំបន់ និងការធ្វើពិពិធកម្មពាណិជ្ជកម្មអាចផ្តល់ឱកាសថ្មីៗតាមរយៈការបើកទីផ្សារថ្មីៗ សម្រាប់ការនាំចេញសម្លៀកបំពាក់កម្ពុជា ។ |
| ទេសចរណ៍ | ជាផ្នែកមួយដ៏សំខាន់ដល់ផលិតផលក្នុងស្រុកសរុប និងបង្កើនការងារ ជាសក្តានុពលដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ច។ | ការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍ពិភពលោកត្រូវបានគេរំពឹងថានឹងជំរុញវិស័យនេះបន្ថែម។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជាចាំបាច់ត្រូវដោះស្រាយបញ្ហាប្រឈមនានាដូចជា ការអភិវឌ្ឍ |

| វិស័យ | ការពិពណ៌នា | ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ពីទស្សនវិស័យសេដ្ឋកិច្ចសកល |
|---|---|---|
| | | ហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើពិពិធកម្មផលិតផល ដើម្បីទាញយកប្រយោជន៍ពេញលេញពីឱកាសនេះ។ |
| កសិកម្ម | បានផ្តល់កំណើនការងារជាផ្នែកសំខាន់នៃចំនួនប្រជាជន និងរួមចំណែកដល់សន្តិសុខស្បៀង។ | ការប្រែប្រួលតម្លៃទំនិញសកលអាចប៉ះពាល់ដល់ផលិតកម្មកសិកម្ម និងការរកប្រាក់ចំណូលដោយប៉ះពាល់ដល់តម្លៃធាតុចូល និងទិន្នផលកសិកម្ម។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពចូលទៅកាន់ទីផ្សារក្នុងតំបន់ និងការវិនិយោគ លើបច្ចេកវិទ្យាកសិកម្មអាចបង្កើនភាពធន់របស់វិស័យនេះដោយការបង្កើនលទ្ធភាពទទួលបានទីផ្សារ និងការកែលម្អផលិតភាព ។ |
| សំណង់ | ជាកត្តាជំរុញដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ប៉ុន្តែបច្ចុប្បន្នក៏កំពុងជួបប្រទះនឹងការធ្លាក់ ចុះផងដែរ។ | លក្ខខណ្ឌសេដ្ឋកិច្ចសកល និងកត្តាក្នុងស្រុកដូចជាការកែតម្រូវទីផ្សារអចលនទ្រព្យនឹងមានឥទ្ធិពលលើការស្ទុះងើបឡើងវិញរបស់វិស័យនេះផងដែរ ។ |

ប្រភព៖ ការរៀបចំរបស់អ្នកស្រាវជ្រាវ

### ១.៤.២ សក្តានុពល និងឱកាស

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានព្យាករថាសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៥ នឹងមានកំណើន ៦,៣% ជាមួយនឹងអតិផរណា ២,៥%។ សេដ្ឋកិច្ចកម្ពុជានៅតែស្ថិតក្នុងគន្លងកំណើនវិជ្ជមាននៅឆ្នាំ ២០២៥ ហើយកំណើននេះបណ្តាលមកពី៖

- **ការងើបឡើងវិញនៃសេដ្ឋកិច្ចសកល៖** ការបន្តស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចនៅសហភាពអឺរ៉ុប និងទីផ្សារនាំចេញសំខាន់ៗផ្សេងទៀតរបស់កម្ពុជា អាចជួយជំរុញតម្រូវការសម្រាប់ការនាំចេញ។
- **ការងើបឡើងវិញនៃវិស័យទេសចរណ៍៖** ការងើបឡើងវិញនៃវិស័យទេសចរណ៍ពិភពលោកត្រូវបានគេរំពឹងថានឹងផ្តល់អត្ថប្រយោជន៍ដល់វិស័យទេសចរណ៍របស់ប្រទេសកម្ពុជា។
- **លំហូរនៃការវិនិយោគ៖** លំហូរវិនិយោគផ្ទាល់ពីបរទេសដែលមានស្ថិរភាពត្រូវបានគេរំពឹងថានឹងជួយដល់កំណើនសេដ្ឋកិច្ច។

- **ការធ្វើសមាហរណកម្មក្នុងតំបន់៖** ការបង្កើនពាណិជ្ជកម្មជាមួយបណ្តាប្រទេសអាស៊ានអាចផ្តល់នូវឱកាសថ្មីសម្រាប់ធុរកិច្ចកម្ពុជា។
- **ការងើបឡើងវិញនៃវិស័យកម្មន្តសាល៖** ការងើបឡើងវិញរបស់វិស័យកម្មន្តសាល ជាពិសេសវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប កំពុងតែជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។
- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ៖** ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធត្រូវបានគេរំពឹងថានឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅឆ្នាំ២០២៥។ នេះរួមបញ្ចូលទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធំៗ ដូចជាព្រលានយន្តហោះ ផ្លូវល្បឿនលឿន និងកំពង់ផែទឹកជ្រៅ ជាដើម។

## ១.៥ ស្ថានភាពបច្ចុប្បន្ននៃទីផ្សារការងារកម្ពុជា

អត្រាចូលរួមកម្លាំងពលកម្មរបស់កម្ពុជាមានកម្រិតខ្ពស់ ដោយ ៨៣,៣% នៃប្រជាជនស្ថិតក្នុងអាយុធ្វើការបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដែលតួលេខនេះបានបង្ហាញពីសក្តានុពលនៃកម្លាំងពលកម្មកម្ពុជាក្នុងទីផ្សារការងារ។ អត្រានៃការចូលរួមក្នុងកម្លាំងពលកម្មក្នុងចំណោមស្ត្រីគឺ ៦៩,៥% ហើយក្នុងចំណោមបុរសគឺ ៨២,៥% សម្រាប់ឆ្នាំ២០២៣ [3]។ ភាពខុសគ្នានៃអត្រាចូលរួមនេះ អាចបណ្តាលមកពីកត្តាសង្គម វប្បធម៌ និងតួនាទីយេនឌ័រផ្សេងៗនៅក្នុងសង្គមកម្ពុជា ខណៈកម្លាំងពលកម្មសរុបនៅក្នុងប្រទេសកម្ពុជាត្រូវបានរាយការណ៍ថា មានចំនួនសរុប ១១ ១២០ ៣២៧នាក់ ក្នុងឆ្នាំ២០២៣។

អត្រានិកម្មភាពធ្វើនៅកម្ពុជាមានកម្រិតទាបដែលត្រូវបានប៉ាន់ប្រមាណថាមានត្រឹម ០,៧% ក្នុងឆ្នាំ២០២៣។ នេះបង្ហាញថា មានប្រជាជនតិចតួចបំផុតក្នុងកម្លាំងពលកម្ម ដែលកំពុងស្វែងរកការងារ ប៉ុន្តែមិនមានការងារធ្វើ។ ទោះជាយ៉ាងណាក៏ដោយ ភាពអត់ការងារធ្វើរបស់យុវជនអាយុ ១៥-២៤ គឺមានអត្រាខ្ពស់ប្រមាណ ២,១% ដែលបង្ហាញពីបញ្ហាប្រឈមមួយចំនួនដូចជាភាពមិនស៊ីគ្នាដែលអាចកើតមានរវាងប្រព័ន្ធអប់រំ និងជំនាញ។ ម្យ៉ាងវិញទៀត អត្រាអ្នកអត់ការងារធ្វើគឺខ្ពស់ក្នុងចំណោមយុវជន ក៏អាចបណ្តាលមកពីការចូលរួមកាន់តែច្រើនឡើងរបស់យុវជនក្នុងការទទួលបានការអប់រំផងដែរ។

ទីផ្សារការងារកម្ពុជាបានផ្តោតទៅលើវិស័យសំខាន់ៗមួយចំនួន ដូចជាវិស័យកាត់ដេរ និងផលិតកម្មធុនស្រាល ការផលិតអាហារ និងភេសជ្ជៈ សំណង់ និងអចលនទ្រព្យ និងវិស័យទេសចរណ៍ [5]។ ជាក់ស្តែង តម្លៃនាំចេញរបស់វិស័យកម្មកាត់ដេរ មានចំណែកធំជាងគេក្នុងចំណោមតម្លៃនាំចេញសរុបរបស់កម្ពុជាទៅក្នុងទីផ្សារអន្តរជាតិ [8]។ ការពឹងផ្អែកតែលើវិស័យមួយចំនួនខាងលើបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាងាយរងគ្រោះដោយសារការប៉ះទង្គិចពីខាងក្រៅ និងការប្រែប្រួលនៃតម្រូវការពិភពលោក។ ជាក់ស្តែង ការរាតត្បាតនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យកាត់ដេរ ដែលនាំឱ្យបាត់បង់ការងារ និងការកើនឡើងនៃភាពអត់ការងារធ្វើ [5]។ ស្រដៀងគ្នានេះដែរ ការធ្លាក់

ចុះនៃសេដ្ឋកិច្ចសកល ឬការផ្លាស់ប្តូរនៃតម្រូវការផលិតផលសម្លៀកបំពាក់ អាចមានផលប៉ះពាល់ដល់សេដ្ឋកិច្ច និងទីផ្សារការងារកម្ពុជា។ ពិពិធកម្មសេដ្ឋកិច្ច និងការលើកកម្ពស់កំណើនក្នុងវិស័យផ្សេងទៀតមានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយភាពងាយរងគ្រោះនេះ។

## ១.៦ ការផ្លាស់ប្តូររចនាសម្ព័ន្ធនៅក្នុងសេដ្ឋកិច្ចកម្ពុជា

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានផ្លាស់ប្តូររចនាសម្ព័ន្ធក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលនាំឱ្យជះឥទ្ធិពលដល់ទីផ្សារការងារ និងរួមចំណែកដល់បញ្ហាប្រឈមនៃភាពអត់ការងារធ្វើ និងកង្វះការងារ។ ការប្រែប្រួលនៃរចនាសម្ព័ន្ធសំខាន់ៗមួយចំនួនរួមមានៈ

- **ការផ្លាស់ប្តូរពីវិស័យកសិកម្មទៅជាឧស្សាហកម្ម និងសេវាកម្មៈ** កម្លាំងពលកម្មក្នុងវិស័យកសិកម្មបានថយចុះពី ៥៤% ក្នុងឆ្នាំ២០១០ ដល់ ៣១% ក្នុងឆ្នាំ២០២៣ ជាមួយនឹងការកើនឡើងនៃការងារក្នុងវិស័យកម្មន្តសាល និងសេវាកម្ម។ ការផ្លាស់ប្តូរនេះឆ្លុះបញ្ចាំងពីនិន្នាការនៃការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហូបនីយកម្ម ដោយប្រទេសកម្ពុជាបានផ្លាស់ប្តូរពីសេដ្ឋកិច្ចដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសមួយដែលមានវិស័យឧស្សាហកម្ម និងសេវាកម្មដែលកំពុងរីកចម្រើន។ ការផ្លាស់ប្តូរនេះត្រូវបានជំរុញដោយកត្តាមួយចំនួនដូចជា ការកើនឡើងនៃការវិនិយោគផ្ទាល់ពីបរទេស កំណើននៃឧស្សាហកម្មកាត់ដេរ និងការរីកចម្រើននៃវិស័យទេសចរណ៍។
- **ភាពជឿនលឿននៃបច្ចេកវិទ្យាៈ** ប្រទេសកម្ពុជាកំពុងផ្លាស់ប្តូរឆ្ពោះទៅរកឧស្សាហកម្ម ៤,០ ដែលត្រូវបានកំណត់ដោយការកើនឡើងនៃសមាហរណកម្មនៃបច្ចេកវិទ្យាឌីជីថល និងស្វ័យប្រវត្តិកម្មក្នុងវិស័យផ្សេងៗ។ ការផ្លាស់ប្តូរនេះទាមទារឱ្យមានកម្លាំងពលកម្មជំនាញ ដែលមានសមត្ថភាពសម្របខ្លួនទៅនឹងបច្ចេកវិទ្យាថ្មីៗ និងការធ្វើការជាមួយនឹងគ្រឿងចក្រ និងប្រព័ន្ធឌីជីថលកម្រិតខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ការទទួលយកបច្ចេកវិទ្យាថ្មីនៅក្នុងប្រទេសកម្ពុជានៅមានកម្រិត ដែលអាចរារាំងដល់កំណើនសេដ្ឋកិច្ច និងធ្វើឱ្យអ្នកជំនាញកាន់តែមានភាពមិនស៊ីសង្វាក់គ្នានៅក្នុងទីផ្សារការងារ។ ជាឧទាហរណ៍ ការកើនឡើងនៃការប្រើប្រាស់ស្វ័យប្រវត្តិកម្មក្នុងផលិតកម្ម អាចជះឥទ្ធិពលអវិជ្ជមានដល់កម្មករនិយោជិតមានជំនាញទាប ឬគ្មានជំនាញ ដែលការណ៍នេះតម្រូវឱ្យពួកគេត្រូវទទួលការបណ្តុះបណ្តាលជំនាញថ្មី ឬបង្កើនជំនាញ ដើម្បីរក្សាបានការប្រកួតប្រជែងក្នុងទីផ្សារការងារ។
- **ការកើនឡើងនៃនគរូបនីយកម្មៈ** នគរូបនីយកម្មដែលមានល្បឿនលឿនបាននាំឱ្យមានការកើនឡើងនៃចំនួនប្រជាជននៅទីក្រុង ជាពិសេសនៅរាជធានីភ្នំពេញ ខណៈដែលតំបន់ជនបទអាចប្រឈមមុខនឹងបញ្ហាចំណាកស្រុក និងការថយចុះនៃកម្លាំងពលកម្មក្នុងវិស័យកសិកម្ម។ ល្បឿនលឿននៃនគរូបនីយកម្មក៏បានធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គមនៅតាមទីក្រុងមានតម្រូវការកើនឡើង ដែលអាចរួមចំណែកបន្ថែមទៀតដល់បញ្ហាប្រឈមរបស់ទីផ្សារការងារ។

- **ភាពមិនស៊ីគ្នានៃជំនាញ៖** ការផ្លាស់ប្តូរឆ្ពោះទៅរកឧស្សាហកម្ម និងសេវាកម្ម ទាមទារកម្លាំងពលកម្មដែលមានជំនាញខុសពីអ្នកដែលមានការងារធ្វើក្នុងវិស័យកសិកម្ម។ ប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលត្រូវសម្របខ្លួនក្នុងការផ្តល់ការអប់រំ និងបណ្តុះបណ្តាលក្នុងវិស័យមួយចំនួនដូចជា បច្ចេកវិទ្យាព័ត៌មាន ការផលិត និងសេវាកម្ម ដើម្បីបំពេញតម្រូវការនៃសេដ្ឋកិច្ចដែលកំពុងផ្លាស់ប្តូរ [4]។ ភាពមិនស៊ីគ្នារវាងជំនាញ ដែលត្រូវការសម្រាប់ឧស្សាហកម្ម ៤,0 និងកម្រិតជំនាញបច្ចុប្បន្ននៃកម្លាំងពលកម្ម គឺជាបញ្ហាប្រឈមដ៏សំខាន់ ដែលអាចនាំឱ្យការប្រើប្រាស់កម្លាំងពលកម្មមិនអស់សក្តានុពល ឬអ្នកអត់ការងារធ្វើ ជាពិសេសក្នុងចំណោមយុវជន និងអ្នកដែលមានការអប់រំក្នុងកម្រិតទាប។
- **ការផ្លាស់ប្តូរមុខរបរ៖** ភាពជឿនលឿនផ្នែកបច្ចេកវិទ្យា ជាពិសេសស្វ័យប្រវត្តិកម្ម អាចនាំទៅដល់ការផ្លាស់ប្តូរតម្រូវការមុខរបរក្នុងវិស័យមួយចំនួន។ កម្មករនិយោជិតក្នុងវិស័យដែលកំពុងមានការផ្លាស់ប្តូរបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស ចាំបាច់ត្រូវរៀនបន្ថែមនូវជំនាញ និងចំណេះដឹងដើម្បីសម្របខ្លួនទៅនឹងបច្ចេកវិទ្យាថ្មីៗ និងតួនាទីរបស់ខ្លួនដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាព និងផលិតភាពខ្ពស់។ ការវិនិយោគលើកម្មវិធីបណ្តុះបណ្តាលជំនាញឡើងវិញ និងបង្កើនជំនាញគឺមានភាពចាំបាច់ដើម្បីជួយឱ្យកម្មករនិយោជិតផ្លាស់ប្តូរមុខរបរ ឬអាចស្វែងរកការងារក្នុងឧស្សាហកម្មថ្មី។
- **វិសមភាពប្រាក់ឈ្នួល៖** ភាពខុសគ្នាខាងប្រាក់ឈ្នួលអាចកើតមានរវាងអ្នកដែលមានការងារធ្វើក្នុងវិស័យដែលត្រូវការជំនាញខ្ពស់ និងអ្នកធ្វើការក្នុងវិស័យដែលត្រូវការជំនាញទាប [9] ដែលនេះអាចបណ្តាលឱ្យមានវិសមភាពប្រាក់ចំណូល និងបញ្ហាប្រឈមនានា។ ជាងនេះទៅទៀត ការអភិវឌ្ឍឧស្សាហកម្មក្នុងវិស័យដែលប្រើកម្លាំងពលកម្ម រួមជាមួយការធ្វើចំណាកស្រុកទៅក្រៅប្រទេសបានដាក់សម្ពាធកាន់តែខ្លាំងលើប្រាក់ឈ្នួលក្នុងស្រុក។ ការណ៍នេះអាចកាត់បន្ថយសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងទីផ្សារពិភពលោក នៅពេលតម្លៃពលកម្មក្នុងប្រទេសកើនឡើង។

# ជំពូកទី ២ លទ្ធផលអង្កេត

## ២.១ ស្ថានភាពសហគ្រាស គ្រឹះស្ថានជាសំណាកគំរូ

ផ្នែកនេះបង្ហាញអំពីចរិតលក្ខណៈនៃសហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យដែលបានជ្រើសរើស។ សហគ្រាស គ្រឹះស្ថានត្រូវបានបែងចែកតាមអនុវិស័យ ចំនួនកម្មករនិយោជិត ការចុះបញ្ជីប្រភេទអាជីវកម្ម និងឆ្នាំដែលត្រូវបានបង្កើត។ ក្នុងសំណាកគំរូនេះ សហគ្រាស គ្រឹះស្ថាន ១០០% ត្រូវបានចាត់ទុកថាស្ថិតនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធដោយសារសហគ្រាស គ្រឹះស្ថានទាំងអស់នោះបានចុះបញ្ជីពាណិជ្ជកម្មជាមួយនឹងក្រសួងពាណិជ្ជកម្ម ឬស្ថាប័នរដ្ឋាភិបាលផ្សេងៗទៀត។ សហគ្រាស គ្រឹះស្ថានជាសំណាកសរុបមានចំនួន ៦៣៨ ដែលស្មើនឹងកម្មករនិយោជិតសរុបចំនួន ២៤១,៤២៩នាក់ បម្រើការងារនៅក្នុង ១៣ អនុវិស័យ ដែលក្នុងនោះសហគ្រាស គ្រឹះស្ថានធុនតូចមានចំនួន ២៤៨ (៣៨,៩%), ធុនមធ្យមមានចំនួន ១៦៧ (២៦,២%) និងធុនធំមានចំនួន ២២៣ (៣៥,០%)។ សហគ្រាស គ្រឹះស្ថាន ៤៦,៩% ជាសហគ្រាស គ្រឹះស្ថានមានម្ចាស់ភាគហ៊ុនជាជនជាតិខ្មែរ ខណៈម្ចាស់ភាគហ៊ុនជាជនបរទេស ៤២,៩% និងម្ចាស់ភាគហ៊ុនជាខ្មែរនិងបរទេសមានចំនួន ១០,២%។ បន្ថែមលើនេះ ក្នុងចំណោមសំណាកគំរូទាំងអស់ការចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមាន ៥៦,០% និងក្រុមហ៊ុនឯកកម្មសិទ្ធិមាន ២២,៩%។ សហគ្រាស គ្រឹះស្ថានភាគច្រើនត្រូវបានបង្កើតក្រោយឆ្នាំ១៩៩៩ (៩៤,៥%) ដែលក្នុងនោះ សហគ្រាស គ្រឹះស្ថានប្រមាណ ៥០% បានបង្កើតនៅក្នុងចន្លោះឆ្នាំ២០១១ និងឆ្នាំ២០២០ ខណៈសហគ្រាស គ្រឹះស្ថានដែលបានបង្កើតក្នុងចន្លោះឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ មានចំនួន ២៤,៧%។

ខាងក្រោមនេះបង្ហាញពីចរិតលក្ខណៈសំខាន់ៗរបស់សហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យទាំង ១៣ ដែលក្នុងនោះមានលក្ខណៈពិសេសរៀងៗខ្លួន។

**អនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន៖** ចំនួនសហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះស្មើនឹង ៧,៧% នៃសហគ្រាស គ្រឹះស្ថានសរុប ប៉ុន្តែកម្មករនិយោជិតក្នុងវិស័យនេះមានត្រឹម ៤,០% នៃកម្មករនិយោជិតសរុបប៉ុណ្ណោះ។ អនុវិស័យនេះមានសហគ្រាស គ្រឹះស្ថានធុនតូចដែលមានកម្មករនិយោជិតចន្លោះ ៥ ទៅ ៤៩នាក់ ដល់ទៅ ៤២,៩% ខណៈសហគ្រាស គ្រឹះស្ថានធុនមធ្យម និងធុនធំមាន ៣២,៧% និង ២៤,៥% រៀងគ្នាប៉ុណ្ណោះ។ បន្ថែមលើនេះ សហគ្រាស គ្រឹះស្ថានជាងពាក់កណ្ដាលនៅក្នុងអនុវិស័យនេះជាសហគ្រាស គ្រឹះស្ថានឯកកម្មសិទ្ធ និងក្រុមហ៊ុនសហកម្មសិទ្ធទទួលខុសត្រូវមានកម្រិត សរុបស្មើនឹង ៦៣,៣%។ មួយភាគធំ ឬ ៦៧,៣% នៃសហគ្រាស គ្រឹះស្ថានជាអង្គភាពទោល និងជិត ៨០% ជាសហគ្រាស គ្រឹះស្ថានមានម្ចាស់ភាគហ៊ុនជាជនជាតិខ្មែរ។

**អនុវិស័យសំណង់៖** អនុវិស័យនេះមានសហគ្រាស គ្រឹះស្ថាន ៦,០% នៃសហគ្រាស គ្រឹះស្ថានសរុប និងកម្មករនិយោជិតស្មើនឹង ១,៩% នៃកម្មករនិយោជិតសរុប។ អនុវិស័យនេះសម្បូរទៅដោយសហគ្រាស គ្រឹះស្ថានធុនតូច

(៥០,០%) និងសហគ្រាស គ្រឹះស្ថានធុនមធ្យម (៣៤,២%)។ សហគ្រាស គ្រឹះស្ថានជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមានប្រមាណ ៦២,៨%។ ក្នុងវិស័យនេះ សហគ្រាស គ្រឹះស្ថានលើស ៥០% មានម្ចាស់ភាគហ៊ុនខ្មែរ និងប្រមាណ ៣២% មានភាគហ៊ុនបរទេស និងមួយចំនួនទៀតម្ចាស់ភាគហ៊ុនជាខ្មែរនិងបរទេស។

**អនុវិស័យអប់រំ៖** សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះមានចំនួន ១២,៤% នៃសហគ្រាស គ្រឹះស្ថានសរុប ខណៈកម្មករនិយោជិតមានចំនួនស្មើនឹង ២,៨% នៃកម្មករនិយោជិតសរុប។ សហគ្រាស គ្រឹះស្ថានធុនតូចមានចំនួន ៣៥,៤%, ធុនមធ្យមចំនួន ៣៤,៤% និងធុនធំ ៣០,៤%។ សហគ្រាស គ្រឹះស្ថាន ៣១,៦% ជាអង្គភាពទោល និង ៤៦,៨% ជាសាខា។ ដោយឡែក សហគ្រាស គ្រឹះស្ថានភាគច្រើនជាក្រុមហ៊ុនឯកកម្មសិទ្ធិ (៤១,៨%) និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (៣៩,២%)។

**អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង៖** ចំនួនសហគ្រាស គ្រឹះស្ថាននៅក្នុងវិស័យនេះមានច្រើនដែលស្ថិតក្នុងលំដាប់ទីពីបន្ទាប់ពីវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ឬស្មើនឹង ១៣,៦% នៃចំនួនសហគ្រាស គ្រឹះស្ថានសរុប។ ខុសប្លែកពីវិស័យផ្សេងទៀត អនុវិស័យនេះភាគច្រើនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត (៦៣,២%) និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (២៣,០%)។ ចំពោះកម្មសិទ្ធិភាគហ៊ុន សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះហាក់មានតុល្យភាពរវាងការវិនិយោគពីម្ចាស់ភាគហ៊ុនខ្មែរ និងបរទេស ដោយសហគ្រាស គ្រឹះស្ថានមានភាគហ៊ុនខ្មែរ មានចំនួន ៤២,៥%, បរទេសមានចំនួន ៣៦,៨% និងភាគហ៊ុនខ្មែរនិងបរទេស មានចំនួន ២០,៧%។

**អនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប៖** ខណៈដែលសហគ្រាស គ្រឹះស្ថាននៅក្នុងវិស័យនេះមានចំណែកច្រើនជាងគេធៀបនឹងអនុវិស័យផ្សេងទៀត ឬស្មើនឹង ១៥,៥% នៃសហគ្រាស គ្រឹះស្ថានសរុប អនុវិស័យនេះក៏បានស្រូបយកកម្លាំងពលកម្មច្រើនផងដែរ ដែលស្មើនឹង ៥៨,១% នៃកម្មករនិយោជិតសរុប ដោយសារតែសហគ្រាស គ្រឹះស្ថានភាគច្រើន (៨៣,៨%) ជាសហគ្រាស គ្រឹះស្ថានធុនធំ និងសហគ្រាស គ្រឹះស្ថានធុនមធ្យម (១៥,២%)។ តែទោះជាយ៉ាងណាក៏ដោយ សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះភាគច្រើនជាអង្គភាពទោល (៨០,៨%) ហើយសហគ្រាស គ្រឹះស្ថានប្រមាណ ៨៦,៩% មានភាគហ៊ុនបរទេសសុទ្ធ។

**អនុវិស័យថែទាំសុខភាព៖** សហគ្រាស គ្រឹះស្ថានក្នុងវិស័យនេះមានចំនួនតិច និងមានទំហំតូច ខណៈកម្មករនិយោជិតក្នុងអនុវិស័យនេះមានត្រឹម ០,៦% នៃកម្មករនិយោជិតសរុបប៉ុណ្ណោះ។ ប្រភេទនៃអាជីវកម្មក្នុងអនុវិស័យនេះគឺជាក្រុមហ៊ុនឯកកម្មសិទ្ធិ (៣៨,២%) និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (៥៥,៩%)។ សហគ្រាស គ្រឹះស្ថានក្នុងវិស័យនេះមានចំនួនតិចតួចប៉ុណ្ណោះដែលមានការបើកអាជីវកម្មជាសាខា ព្រោះថា ៨៥,៣% នៃសហគ្រាស គ្រឹះស្ថានជាអង្គភាពទោល។

**អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា៖** អនុវិស័យនេះមានចំនួនសហគ្រាស គ្រឹះស្ថានស្មើនឹង ២,៤% នៃសហគ្រាស គ្រឹះស្ថានសរុប ដែលក្នុងនោះមានសហគ្រាស គ្រឹះស្ថានដល់ទៅ ៦៦,៧% ជាសហគ្រាស គ្រឹះស្ថានធុនតូច ដែលនាំឱ្យការរួមចំណែកនៃកម្មករនិយោជិតមានត្រឹមតែ ០,៤% នៃកម្មករនិយោជិតសរុប។ យើងសង្កេតឃើញថាពាក់កណ្តាល ឬ ៥៣,៣% នៃសហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះប្រកបអាជីវកម្មបែបក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និង ៣៣,៣% ជាក្រុមហ៊ុនឯកកម្មសិទ្ធិ។ ភាគច្រើននៃសហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យនេះ (៨០,០%) មានម្ចាស់ភាគហ៊ុនខ្មែរ ១០០% និង ៦៦,៧% ជាអង្គភាពទោល។

**អនុវិស័យផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី៖** សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះចូលរួមចំណែកត្រឹមតែ ៤,៩% នៃសហគ្រាស គ្រឹះស្ថានសរុប ប៉ុន្តែបានស្រូបយកកម្លាំងពលកម្មសរុបដល់ទៅ ១១,០% ដោយសារតែសហគ្រាស គ្រឹះស្ថានក្នុងវិស័យនេះ ដល់ទៅ ៦៧,៧% ជាសហគ្រាស គ្រឹះស្ថានធុនធំ ខណៈ ១២,៩% ជាសហគ្រាស គ្រឹះស្ថានធុនតូច និង ១៩,៤% ជាសហគ្រាស គ្រឹះស្ថានធុនមធ្យម។ គួរឱ្យចាប់អារម្មណ៍ ៩០,៣% នៃសហគ្រាស គ្រឹះស្ថានសរុបជាកម្មសិទ្ធបរទេស។ ដោយឡែក សហគ្រាស គ្រឹះស្ថានក្នុងវិស័យនេះហាក់មានតុល្យភាពរវាងការប្រកបអាជីវកម្មបែបអង្គភាពទោល និងបែបមានសាខា ដោយអង្គភាពទោលមាន ៥៤,៨% និងស្នាក់ការកណ្តាលនិងសាខាមាន ៤៥,២%។ សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះជិត ១៦,១% ប៉ុណ្ណោះដែលជាក្រុមហ៊ុនឯកកម្មសិទ្ធិ និង ៧៧,៤% ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។

**អនុវិស័យផលិតអាហារ និងភេសជ្ជៈ៖** សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះចូលរួមចំណែក ៥,៨% នៃសហគ្រាស គ្រឹះស្ថានសរុប និង ១,៦% នៃកម្មករនិយោជិតសរុប។ សហគ្រាស គ្រឹះស្ថានក្នុងវិស័យនេះមាន ៥១,៤% ជាសហគ្រាស គ្រឹះស្ថានធុនតូច រីឯសហគ្រាស គ្រឹះស្ថានធុនមធ្យមមាន ៣២,៤% និងធុនធំ ១៦,២%។ សហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យនេះក៏ហាក់មានតុល្យភាពរវាងការវិនិយោគដោយបរទេស (ទាំងស្រុងឬមួយផ្នែក) និងការវិនិយោគក្នុងស្រុក ដោយសហគ្រាស គ្រឹះស្ថាន ៤៨,៦% មានម្ចាស់ភាគហ៊ុនបរទេសទាំងស្រុង ឬមួយផ្នែក និង ៥១,៤% មានម្ចាស់ភាគហ៊ុនសញ្ជាតិខ្មែរទាំងស្រុង។ ដោយឡែក ការប្រកបអាជីវកម្មជាអង្គភាពទោលមាន ៧៣,០%។ សហគ្រាស គ្រឹះស្ថានជាងពាក់កណ្តាលក្នុងអនុវិស័យនេះ (៦២,២%) ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ខណៈ ២៧,០% ជាក្រុមហ៊ុនឯកកម្មសិទ្ធិ។

**អនុវិស័យផលិតកៅស៊ូ និងប្លាស្ទិក៖** សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះមានចំណែកប្រមាណ ៥,៥% នៃចំនួនសហគ្រាស គ្រឹះស្ថានសរុប និង ២,៧% នៃចំនួនកម្មករនិយោជិតសរុប។ សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះមាន ៦០% ជាសហគ្រាស គ្រឹះស្ថានធុនតូច ខណៈ ៣៤,៣% ជាសហគ្រាស គ្រឹះស្ថានធុនមធ្យម និង ៥,៧% ជាសហគ្រាស គ្រឹះស្ថានធុនធំ។ សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះ ៦០% ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។ ដោយឡែក សហគ្រាស គ្រឹះស្ថាន ៧៧,១% ជាអង្គភាពទោល ខណៈ ២២,៩% ជាស្នាក់ការកណ្តាល និងសាខា។

**អនុវិស័យផលិតផលិតផលឈើ និងក្រដាស៖** សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះមានចំណែកតិចតួច ឬត្រឹម ៤,៥% នៃសហគ្រាស គ្រឹះស្ថានសរុប និងមានចំណែកកម្មករនិយោជិតប្រមាណ ១,៥% នៃចំនួនកម្មករសរុប។ អនុវិស័យនេះសម្បូរទៅដោយសហគ្រាស គ្រឹះស្ថានធុនតូច និងមធ្យម (ធុនតូច ៤១,៤% និងធុនមធ្យម ៤៤,៨%)។ ថ្វីត្បិតតែជិត ៦២,១% នៃសហគ្រាស គ្រឹះស្ថានសរុបក្នុងអនុវិស័យនេះជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គួរកត់សម្គាល់ផងដែរថា អនុវិស័យក៏មានប្រភេទសហគ្រាស គ្រឹះស្ថានជាក្រុមហ៊ុនសហកម្មសិទ្ធទទួលខុសត្រូវមានកម្រិតដល់ទៅ ១៧,២% ខណៈក្រុមហ៊ុនឯកកម្មសិទ្ធិមានត្រឹម ២០,៧%។ ដោយឡែក អនុវិស័យនេះក៏សម្បូរទៅដោយសហគ្រាស គ្រឹះស្ថានដែលមានភាគហ៊ុនបរទេសសុទ្ធដល់ទៅ ៦៥,៥% ខណៈសហគ្រាស គ្រឹះស្ថានភាគហ៊ុនខ្មែរសុទ្ធមាន ២៤,១%។ សហគ្រាស គ្រឹះស្ថានភាគតិច ឬ ១៧,២% ប៉ុណ្ណោះ ដែលមានការបើកជាសាខានៅតាមបណ្ដាទីតាំងផ្សេងៗគ្នា។

**អនុវិស័យកម្មន្តសាលផ្សេងៗ៖** សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះបានរួមចំណែកដល់ទៅ ៨,២% នៃសហគ្រាស គ្រឹះស្ថានសរុប និង ៨,៣% នៃកម្មករនិយោជិតសរុប។ សហគ្រាស គ្រឹះស្ថាន ២៥,០% នៃសហគ្រាស គ្រឹះស្ថានសរុប ជាសហគ្រាស គ្រឹះស្ថានធុនតូច ខណៈសហគ្រាស គ្រឹះស្ថានធុនមធ្យម និងធុនធំមានចំនួនប្រហាក់ប្រហែលគ្នា ឬស្មើនឹង ៣៨,៥% និង ៣៦,៥% រៀងគ្នា នៃសហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះសរុប។ សហគ្រាស គ្រឹះស្ថានឯកកម្មសិទ្ធិមានតិចតួច ឬ ១៣,៥% ប៉ុណ្ណោះ ខណៈ ១១,៥% ជាក្រុមហ៊ុនសហកម្មសិទ្ធទទួលខុសត្រូវមានកម្រិត និងដល់ទៅ ៧១,២% ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។ អនុវិស័យនេះក៏សម្បូរការវិនិយោគពីបរទេស ដោយសហគ្រាស គ្រឹះស្ថានដែលមានភាគហ៊ុនបរទេសសុទ្ធមានចំនួន ៥៧,៧% និងមានភាគហ៊ុនបរទេសភាគខ្លះមានចំនួន ១៣,៥%។ លើសពីនេះ ប្រមាណ ៦០% នៃសហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះជាអង្គភាពទោល។

**អនុវិស័យដឹកជញ្ជូន និងស្ដុកទំនិញ៖** សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះបានរួមចំណែក ៨,៣% នៃសហគ្រាស គ្រឹះស្ថានសរុប និងស្មើនឹង ២,៦% នៃចំនួនកម្មករនិយោជិតសរុប ហើយមាន ៤៩,១% ជាសហគ្រាស គ្រឹះស្ថានធុនតូច។ សហគ្រាស គ្រឹះស្ថាន ៤៣,៤% និង ៤១,៥% ជាសហគ្រាស គ្រឹះស្ថានមានភាគហ៊ុនខ្មែរ និងបរទេសរៀងគ្នា។ មួយភាគធំនៃសហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះ ឬប្រមាណ ៥៧% ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងជាអង្គភាពទោល។

*សូមមើលឧបសម្ព័ន្ធ គ អំពីព័ត៌មានលម្អិតអំពីចរិតលក្ខណៈនៃសហគ្រាស គ្រឹះស្ថាន។*

## ២.២ ស្ថានភាពការងារ និងការជ្រើសរើសបុគ្គលិក

### ២.២.១ ស្ថានភាពការងារ

ការរំពឹងទុករបស់និយោជកលើកំណើនការងារតាមអនុវិស័យ បានបង្ហាញពីទិដ្ឋភាពដ៏ស្មុគស្មាញរួមមានទាំងឱកាស និងបញ្ហាប្រឈមមួយចំនួន។ អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) មានភាពលេចធ្លោជាមួយនឹងកំណើនពីរខ្ទង់ដ៏រឹងមាំ ដែលបង្ហាញពីតម្រូវការខ្លាំងសម្រាប់ដំណោះស្រាយបច្ចេកវិទ្យា និងបដិវត្តន៍កុំព្យូទ័រ ដែលធ្វើឱ្យអនុវិស័យនេះបាន និងកំពុងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឌីជីថលូបនីយកម្មនៅកម្ពុជា។ និន្នាការនេះបង្ហាញពីការវិនិយោគលើបច្ចេកវិទ្យាដែលកំពុងរីកចម្រើន ដូចជាផលិតផលបច្ចេកវិទ្យាថ្មីៗ ដូចជាបញ្ញាសិប្បនិមិត្ត ស្របពេលដែលការពង្រឹងសន្តិសុខតាមអ៊ីនធឺណិត ក៏នឹងក្លាយជាអាទិភាពមួយសម្រាប់វឌ្ឍនភាពប្រកបដោយនិរន្តរភាព។

ទន្ទឹមនឹងនេះ អនុវិស័យមួយចំនួនដែលមានកំណើនការងារក្នុងកម្រិតមធ្យមរួមមាន ហិរញ្ញវត្ថុ និងធានារ៉ាប់រង, ការអប់រំ, និងការដឹកជញ្ជូន និងស្តុកទំនិញ។ សេវាកម្មទាំងនេះបង្ហាញពីស្ថិរភាពជាមួយនឹងឱកាសដែលកើតចេញពីការបង្កើតថ្មីនៃប្រព័ន្ធធនាគារឌីជីថល ការកើនឡើងនៃថ្នាលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងសកម្មភាពពាណិជ្ជកម្មអេឡិចត្រូនិក។ ការងារក្នុងអនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រងកើនឡើងដោយសារការទទួលបានអត្ថប្រយោជន៍ពីការរីកចម្រើននៃ FinTech ដោយការលើកកម្ពស់សេវាកម្មអតិថិជនជាមួយសេវាទូទាត់រហ័ស និងការអនុលោមតាមបទប្បញ្ញត្តិនានា។ ដូចគ្នាដែរ ការងារក្នុងអនុវិស័យអប់រំនឹងមានតម្រូវការបន្ថែមដោយសារតម្រូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ លទ្ធភាពទទួលការអប់រំ និងការសិក្សាតាមថ្នាលអេឡិចត្រូនិកមានការកើនឡើងដែលជំរុញការវិនិយោគក្នុងការអភិវឌ្ឍជំនាញស្របតាមតម្រូវការទីផ្សារ។

ម៉្យាងវិញទៀត ចំនួនការងារក្នុងអនុវិស័យសេវាស្នាក់នៅ និងភោជនីយដ្ឋាន និងអនុវិស័យផលិតអាហារ និងភេសជ្ជៈបង្ហាញពីកំណើនវិជ្ជមានតិចតួចនៅឡើយ។ ទោះបីជាការកើនឡើងនៃការធ្វើដំណើរ និងការកើនឡើងចំនួនភ្ញៀវទេសចរណ៍កំពុងជំរុញតម្រូវការសម្រាប់សណ្ឋាគារ និងការស្នាក់នៅផ្សេងទៀតក៏ដោយ ការស្ទុះងើបឡើងវិញនេះមិនទាន់បានប្រែក្លាយទៅជាកំណើនគួរឱ្យកត់សម្គាល់នៅឡើយទេ។

ស្របពេលជាមួយគ្នានេះ អនុវិស័យសំណង់ក៏បង្ហាញពីកំណើនតិចតួច ដែលបង្ហាញពីបញ្ហាប្រឈមនៅក្នុងអនុវិស័យនេះ។ ដូចគ្នានេះដែរ អនុវិស័យផលិតផលិតផលឈើ និងក្រដាសប្រឈមមុខនឹងបញ្ហាប្រឈមក្នុងតម្រូវការ និងការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ ទាមទារការធ្វើពិពិធកម្ម និងបង្កើនប្រសិទ្ធភាពសម្រាប់កំណើននាពេលអនាគត។

សរុបមក ទិន្នន័យបង្ហាញថាសេដ្ឋកិច្ចមានភាពធន់ ដោយមានកំណើនវិជ្ជមាននៅតាមអនុវិស័យផ្សេងៗ ទន្ទឹមនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ កំពុងតែផ្លាស់ប្តូរនូវរបៀបនៃការផលិត និងការប្រើប្រាស់។ យុទ្ធសាស្ត្រដែលផ្តោត

លើការវិនិយោគបច្ចេកវិទ្យា ការអភិវឌ្ឍជំនាញឌីជីថល នវានុវត្តន៍ ព្រមទាំងការគាំទ្រគោលនយោបាយដែលពាក់ព័ន្ធនឹងក្លាយជាកត្តាសំខាន់ដើម្បីជានាកំណើនសេដ្ឋកិច្ចប្រកបដោយភាពធន់ និងចីរភាព។ ដោយឡែក ការរកដំណោះស្រាយជាក់លាក់សម្រាប់អនុវិស័យដែលកំពុងប្រឈម ព្រមទាំងការជំរុញនវានុវត្តន៍ នឹងជួយជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។

តារាងទី ៦៖ ចំនួនការងារ និងកំណើនការងារដែលនិយោជករំពឹងទុកសម្រាប់ឆមាសទី១ ឆ្នាំ២០២៥ ដល់ឆមាសទី១ ឆ្នាំ២០២៦

| វិស័យ | ឆ្នាំគោល ឆមាសទី២ ២០២៤ | ឆមាសទី១ ២០២៥ | ឆមាសទី២ ២០២៦ | ឆមាសទី១ ២០២៦ | កំណើនជាមធ្យមក្នុងមួយឆមាស (ឆ១ ២០២៥ - ឆ១ ២០២៦) |
|---|---|---|---|---|---|
| ស្នាក់នៅ និងភោជនីយដ្ឋាន | 39,883 | 3.4% | 1.0% | 0.3% | 1.6% |
| សំណង់ | 36,342 | 2.0% | 1.2% | -1.9% | 0.4% |
| ការអប់រំ | 28,266 | 4.5% | 2.3% | 11.6% | 6.1% |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 103,299 | 5.9% | 1.4% | 2.3% | 3.2% |
| វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប | 934,629 | 9.1% | 2.7% | 0.9% | 4.2% |
| សេវាថែទាំសុខភាព | 6,436 | 3.3% | 1.4% | 0.9% | 1.9% |
| បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) | 2,953 | 10.3% | 5.3% | 2.5% | 6.0% |
| ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី | 53,782 | 6.1% | -2.6% | 6.5% | 3.3% |
| ផលិតអាហារ និងភេសជ្ជៈ | 15,955 | 6.1% | 2.4% | 0.8% | 3.1% |
| ផលិតកៅស៊ូ និងប្លាស្ទិក | 25,022 | 9.2% | 1.2% | 1.2% | 3.9% |
| ផលិតផលិតផលឈើ និងក្រដាស | 17,655 | 2.2% | 2.3% | 1.2% | 1.9% |
| កម្មន្តសាលផ្សេងៗ | 131,104 | -0.8% | 14.9% | 7.3% | 7.2% |
| ការដឹកជញ្ជូន និងស្តុកទំនិញ | 17,254 | 5.1% | 2.9% | 1.8% | 3.3% |
| សរុប | 1,412,580 | 7.2% | 3.4% | 2.0% | 4.2% |

*ចំណាំ៖ ឆ = ឆមាស។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ

រូបភាពទី៦ បង្ហាញពីដង់ស៊ីតេអ្នកស្វែងរកការងារដំបូងតាមអនុវិស័យ ដោយក្នុងនោះអនុវិស័យកាត់ដេរ ស្បែកជើង និងសម្លៀកបំពាក់មានចំនួនអ្នកស្វែងរកការងារធ្វើលើកដំបូងច្រើនជាងគេ (២៣ ៧៩០នាក់) ដែលឆ្លុះបញ្ចាំងពីការទាក់ទាញនៃអនុវិស័យនេះ ឬផ្តល់ឱកាសការងារច្រើន និងអាចជាចំណុចចាប់ផ្តើមសម្រាប់អ្នកដែលមិនទាន់មានបទពិសោធន៍ការងារ។ អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) លេចធ្លោជាមួយនឹង

អត្រាដង់ស៊ីតេខ្ពស់បំផុតគឺ ១២,៣៦% (២៧០នាក់) ដែលបង្ហាញពីលំហូរចូលយ៉ាងច្រើននៃអ្នកដែលមានជំនាញខ្ពស់ បើទោះបីជាអនុវិស័យនេះនៅមានទំហំភាគច្រើនជាខ្នាតតូចក៏ដោយ។

ផ្ទុយទៅវិញ អនុវិស័យមួយចំនួនដូចជា ការផលិតគ្រឿងអេឡិចត្រូនិក និងបរិក្ខារអគ្គិសនី រាយការណ៍អំពីចំនួន និងដង់ស៊ីតេនៃអ្នកស្វែងរកការងារដំបូងមានកម្រិតទាប។ អនុវិស័យផ្សេងទៀតដូចជា ការអប់រំ និងផលិតកម្មផ្សេងទៀតមានដង់ស៊ីតេកម្រិតមធ្យមសម្រាប់ឱកាសការងារសមរម្យសម្រាប់អ្នកចូលថ្មី ឬស្វែងរកការងារលើកដំបូង។

សរុបមក ទិន្នន័យឆ្លុះបញ្ចាំងពីឱកាសផ្សេងៗគ្នាសម្រាប់អ្នកស្វែងរកការងារធ្វើលើកដំបូង ដោយវិស័យខ្លះបង្ហាញពីដង់ស៊ីតេខ្ពស់ និងសក្តានុពលសម្រាប់កំណើន ខណៈវិស័យខ្លះទៀតអាចត្រូវការយុទ្ធសាស្ត្រដើម្បីទាក់ទាញអ្នកស្វែងរកការងារធ្វើលើកដំបូងបន្ថែមទៀត។

រូបភាពទី ៦៖ ដង់ស៊ីតេជាអ្នកស្វែងរកការងារដំបូងតាមវិស័យ (គិតជាភាគរយ)




សម្គាល់៖ ដង់ស៊ីតេ = ចំនួនអ្នកស្វែងរកការងារដំបូងក្នុងវិស័យនីមួយៗ ធៀបនឹងចំនួនការងារសរុបក្នុងវិស័យនោះ

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ

តារាងទី៧ ខាងក្រោមបង្ហាញពីមុខរបរដែលទទួលយកអ្នកស្វែងរកការងារដំបូងច្រើនជាងគេ ដែលនេះជាព័ត៌មានមូលដ្ឋានដ៏សំខាន់សម្រាប់ការជ្រើសរើសអាជីពសម្រាប់អ្នកស្វែងរកការងារដំបូងរបស់ខ្លួន ដោយបង្ហាញពីមុខតំណែង បម្រែបម្រួលសន្ទស្សន៍ឱកាសការងារ ប្រាក់ខែ និងអត្ថប្រយោជន៍ផ្សេងៗ។ តួនាទីនីមួយៗទាមទារកម្រិតផ្សេងៗគ្នានៃការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញដែលអាចបញ្ជាក់ពីនិន្នាការទីផ្សារការងារបច្ចុប្បន្ន

សម្រាប់និយោជក អ្នកផ្តល់ការអប់រំនិងបណ្តុះបណ្តាល និងយុវជនក្នុងការយល់ដឹងអំពីសក្តានុពលនៃទិដ្ឋភាពការងារនៅកម្ពុជា។

តារាងទី ៧៖ មុខរបរដែលមានឱកាសការងារល្អ និងមានអ្នកស្វែងរកការងារដំបូងច្រើន

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 8141 | អ្នកបញ្ជាម៉ាស៊ីនផលិតផលិតផលជ័រកៅស៊ូ | 3.30 | 4.00 | $ 200 | $ 41 |
| 2 | 2163 | អ្នករចនាម៉ូតផលិតផល និងសម្លៀកបំពាក់ | 4.11 | 4.00 | $ 481 | $ 30 |
| 3 | 3331 | ភ្នាក់ងារប្រមូលទំនិញចេញ និងដឹកជញ្ជូនចេញ និងបញ្ជូនបន្ត | 3.29 | 3.97 | $ 668 | $ 89 |
| 4 | 8183 | អ្នកបញ្ជាម៉ាស៊ីនវេចខ្ចប់ ច្រកដាក់ដប និងដាក់ផ្លាកសញ្ញា | 1.73 | 3.93 | $ 243 | $ 69 |
| 5 | 3122 | អ្នកមើលការខុសត្រូវការផលិតក្នុងរោងចក្រ | 2.85 | 3.91 | $ 667 | $ 68 |
| 6 | 2141 | វិស្វករឧស្សាហកម្ម និងផលិតកម្ម | 3.66 | 3.91 | $ 556 | $ 64 |
| 7 | 7532 | អ្នកកាត់សំលៀកបំពាក់ និងអ្នកធ្វើគំរូសំលៀកបំពាក់ដែលពាក់ព័ន្ធ | 3.09 | 3.81 | $ 264 | $ 66 |
| 8 | 2353 | គ្រូបង្រៀនភាសាផ្សេងទៀត | 2.83 | 3.80 | $ 454 | $ 31 |
| 9 | 2166 | អ្នករចនាក្រាហ្វិច និងម៉ាលធីមេឌៀ | 2.83 | 3.67 | $ 721 | $ 127 |
| 10 | 3322 | អ្នកតំណាងលក់ផ្នែកពាណិជ្ជកម្ម | 3.30 | 3.65 | $ 478 | $ 70 |
| 11 | 8153 | អ្នកបញ្ជាម៉ាស៊ីនដេរ | 2.41 | 3.63 | $ 226 | $ 59 |
| 12 | 7512 | អ្នកដុតនំ អ្នកធ្វើនំម្សៅ និងជំណាប់ | 3.43 | 3.57 | $ 201 | $ 60 |
| 13 | 2221 | វិជ្ជាជីវៈខាងគិលានុប្បដ្ឋាយិកា | 3.34 | 3.36 | $ 501 | $ 99 |
| 14 | 3312 | មន្ត្រីឥណទាន និងប្រាក់កម្ចី | 3.02 | 3.21 | $ 409 | $ 121 |
| 15 | 5244 | អ្នកលក់ ឬអ្នកទីផ្សារតាមទូរស័ព្ទ | 2.83 | 3.20 | $ 444 | $ 89 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.២.២ ស្ថានភាពជ្រើសរើសបុគ្គលិក

តារាងទី៨ បង្ហាញពីស្ថានភាពសេដ្ឋកិច្ចតាមរាជធានីខេត្តនៃប្រទេសកម្ពុជាតាមរយៈចំនួនសហគ្រាស គ្រឹះស្ថាន និងចំនួនរំពឹងទុកនៃបុគ្គលិកដែលនឹងជ្រើសរើស។ ក្រៅពីរាជធានីភ្នំពេញ ខេត្តកណ្តាល តាកែវ និងកំពង់ស្ពឺ មានសកម្មភាពសេដ្ឋកិច្ចល្អប្រសើរ ដោយអំណោយផលពីទីតាំងភូមិសាស្ត្រ ដែលអាចបង្កើតការងារបានច្រើនជាងគេ។ រាជធានីភ្នំពេញជាមជ្ឈមណ្ឌលដ៏សំខាន់មួយក្នុងការទាក់ទាញអ្នកវិនិយោគ និងកម្លាំងពលកម្មយ៉ាងច្រើន ដោយ

ទទួលបានអត្ថប្រយោជន៍ពីលំហូរចូលទាំងធនធានមនុស្ស និងសេវាកម្មផ្សេងៗ។ ទន្ទឹមនេះ រាជធានីខេត្តទាំងនេះ ក៏កំពុងប្រឈមមុខនឹងការរំពឹងទុកថាមុខតំណែងទំនេរផងដែរ ដែលបង្ហាញពីតម្រូវការកម្លាំងពលកម្មជំនាញ ដើម្បីបំពេញតម្រូវការក្នុងស្រុក។

ផ្ទុយទៅវិញ ខេត្តកំពង់ចាម មានចំនួនសហគ្រាស គ្រឹះស្ថាន និងកម្លាំងពលកម្មតិចជាងគេ ដែលជាសញ្ញាបង្ហាញថាសកម្មភាពសេដ្ឋកិច្ចនៅទីនោះនៅមានកម្រិតទាប ហើយឱកាសក្នុងការអភិវឌ្ឍ និងទាក់ទាញការវិនិយោគក៏មានកម្រិតផងដែរ។

តារាងទី ៨៖ តារាងសង្ខេបព័ត៌មានចំនួនសហគ្រាស គ្រឹះស្ថាន កម្មករ និយោជិត និងចំនួនប្រកាសជ្រើសរើសដែលរំពឹងទុកតាមរាជធានី ខេត្ត

| ខេត្ត | ចំនួនសហគ្រាស គ្រឹះស្ថាន | ចំនួនកម្មករ និយោជិត | ចំនួនប្រកាសជ្រើសរើសដែលរំពឹងទុក |
|---|---|---|---|
| ខេត្តកណ្តាល | 402 | 137,906 | 7,830 |
| ខេត្តកំពង់ចាម | 261 | 10,796 | 1,037 |
| ខេត្តកំពង់ស្ពឺ | 486 | 154,424 | 5,159 |
| ខេត្តកំពត | 213 | 71,626 | 3,911 |
| ខេត្តតាកែវ | 434 | 215,800 | 5,639 |
| ខេត្តបាត់ដំបង | 436 | 14,329 | 1,008 |
| ខេត្តព្រះសីហនុ | 379 | 47,186 | 6,501 |
| ខេត្តសៀមរាប | 371 | 13,219 | 1,523 |
| ខេត្តស្វាយរៀង | 303 | 143,552 | 6,230 |
| រាជធានីភ្នំពេញ | 4,998 | 603,743 | 39,502 |
| សរុប | 8,284 | 1,412,580 | 78,339 |

*ចំណាំ៖ ទិន្នន័យនេះជាទិន្នន័យតំណាងឱ្យសំណាកគំរូដែលគណនាចេញពីការដាក់មេគុណ (weighted value)។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

រូបភាពទី ៧ បង្ហាញពីសន្ទស្សន៍នៃស្ថានភាពជ្រើសរើសបុគ្គលិក ដែលឆ្លុះបញ្ចាំងពីតម្រូវការជ្រើសរើសបុគ្គលិកនៅទូទាំងអនុវិស័យផ្សេងៗ ដោយអនុវិស័យស្នាក់នៅមានសន្ទស្សន៍ខ្ពស់ជាងគេ (៣,៤៣) ដែលបង្ហាញពីតម្រូវការខ្ពស់សម្រាប់បុគ្គលិក ដែលទំនងជាត្រូវបានជំរុញដោយការងើបឡើងវិញនៃសកម្មភាពធ្វើដំណើរ និងបដិសណ្ឋារកិច្ច ។ អនុ-វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប មានសន្ទស្សន៍ ៣,២៦ បង្ហាញពីតម្រូវការកម្លាំងពលកម្មដ៏រឹងមាំនៃវិស័យនេះ ដែលទំនងជាត្រូវបានជះឥទ្ធិពលពីការកើនឡើងនៃតម្រូវការខាងក្រៅ និងមួយភាគជាផលជះពីនិន្នាការភូមិសាស្ត្រនយោបាយ។ អនុវិស័យសេវាថែទាំសុខភាពក៏បង្ហាញពីសក្តានុពលជ្រើសរើសបុគ្គលិកផងដែរ ជាមួយនឹងសន្ទស្សន៍ ៣,២១ ដែលឆ្លុះបញ្ចាំងពីតម្រូវការដែលកំពុងបន្តក្នុងការថែទាំសុខភាព។ ដូចគ្នានេះដែរ អនុវិស័យផលិតអាហារ និងភេសជ្ជៈ (៣,២៩) និងអនុវិស័យផលិតកម្មកៅស៊ូ និងប្លាស្ទិក (៣,២៣) បង្ហាញពី

តម្រូវការជ្រើសរើសបុគ្គលិក ដែលការណ៍នេះឆ្លុះបញ្ចាំងពីតួនាទីសំខាន់នៃឧស្សាហកម្មទាំងនេះនៅក្នុងសេដ្ឋកិច្ច។ អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញមានសន្ទស្សន៍ ៣,២២ ដែលជានិន្នាការនៃការកើនឡើងនៃសកម្មភាពពាណិជ្ជកម្មអេឡិចត្រូនិក (E-commerce) និងខ្សែសង្វាក់ផ្គត់ផ្គង់។

រូបភាពទី ៧៖ ស្ថានភាពរបស់និយោជកក្នុងការជ្រើសរើសបុគ្គលិកតាមអនុវិស័យ (សន្ទស្សន៍)




*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

ការវិភាគលើរូបភាពទី៨ បង្ហាញពីមូលហេតុលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម ដែលបានផ្តល់ព័ត៌មានបន្ថែមទៅលើបញ្ហាប្រឈម ដែលនិយោជកកំពុងជួបប្រទះនៅក្នុងវិស័យរបស់ខ្លួន។ កត្តាសំខាន់ដែលជះឥទ្ធិពលដល់ការជ្រើសរើសបុគ្គលិកគឺ «បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច» ដែលការណ៍នេះបង្ហាញថាក្រុមហ៊ុនកំពុងស្វែងរកបេក្ខជនដែលមានជំនាញបច្ចេកទេស ឬវិជ្ជាជីវៈចាំបាច់សម្រាប់តួនាទីដែលពួកគេកំពុងព្យាយាមបំពេញ។ បន្ថែមពីនេះ មូលហេតុផ្សេងទៀតដែលជាឧបសគ្គក្នុងការជ្រើសរើសកម្លាំងពលកម្មរួមមានបញ្ហាមួយចំនួនដូចជា បទពិសោធន៍ (៣០,២៦%) និងគុណវុឌ្ឍិ (១៦,៥៤%)។ មូលហេតុទាំងបីខាងលើនេះ ជាមូលហេតុចម្បងដែលធ្វើឱ្យមានកង្វះជំនាញ (មើលឧបសម្ព័ន្ធ ខ រូបភាព ខ.១)។

ការប្រកួតប្រជែងពីនិយោជកផ្សេងទៀត គឺជាបញ្ហាប្រឈមដ៏គួរឱ្យកត់សម្គាល់មួយផងដែរ ដោយមាន ៤៤,០៩% នៃសហគ្រាស គ្រឹះស្ថានទទួលស្គាល់ថាកត្តានេះជាឧបសគ្គក្នុងការជ្រើសរើសបុគ្គលិកដែលមានជំនាញបច្ចេកទេសច្បាស់លាស់ និងបទពិសោធន៍ខ្ពស់។ ការប្រកួតប្រជែងនេះបង្ហាញពីទីផ្សារការងារដែលបេក្ខជនមានជម្រើសច្រើន ធ្វើឱ្យសហគ្រាស គ្រឹះស្ថានជួបការលំបាកក្នុងការទាក់ទាញ និងរក្សាទុកបុគ្គលិកដែលមានទេពកោសល្យ។

ក្នុងនោះ លក្ខខណ្ឌមិនល្អដែលផ្តល់ជូនសម្រាប់មុខតំណែង (ឧ. ប្រាក់ខែទាប) (២៨,៨៨%) និងឧបសគ្គផ្សេងទៀតរួមមានមុខតំណែង ឬប្រភេទការងារទទួលបានចំណាប់អារម្មណ៍តិច (២៣,៤៩%) ដែលបង្ហាញពីភាពមិនស៊ីគ្នារវាងភាពអាចរកបានការងារ និងចំណាប់អារម្មណ៍របស់អ្នកស្វែងរកការងារ ព្រមទាំងបញ្ហាចម្ងាយពីកន្លែងធ្វើការ និងកន្លែងស្នាក់នៅ ដោយកន្លែងការងារនៅដាច់ស្រយាល ឬពិបាកក្នុងធ្វើដំណើរ (៩,៨៣%) ដែលប៉ះពាល់ដល់ភាពងាយស្រួលក្នុងការផ្សារភ្ជាប់មុខតំណែងទំនេរទៅអ្នកស្វែងរកការងារ។ ដោយឡែក ការងារតាមរដូវ (៤,៦៤%) និងការងារដែលតម្រូវឱ្យមានការប្តូរវេនយប់ ឬម៉ោងធ្វើការមិនសមស្រប (១,៧៤%) ក៏ជាបញ្ហាប្រឈមបន្ថែមសម្រាប់វិស័យមួយចំនួន ប៉ុន្តែកត្តាទាំងនេះហាក់ដូចជាមិនសូវមានផលប៉ះពាល់ទេបើប្រៀបធៀបទៅនឹងតម្រូវការជំនាញ និងការប្រកួតប្រជែង។

សរុបមក តារាងគូសបញ្ជាក់អំពីបញ្ហាជ្រើសរើសបុគ្គលិកច្រើនមុខ ដែលកង្វះខាតនៃជំនាញ ការប្រកួតប្រជែង និងការទាមទារគុណវុឌ្ឍិជាមូលហេតុយ៉ាងសំខាន់ ដែលជាឧបសគ្គដល់និយោជកក្នុងការជ្រើសរើសបុគ្គលិក។ បញ្ហាប្រឈមទាំងនេះ បង្ហាញពីតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងកម្លាំងពលកម្ម ដោយផ្តោតលើការវិនិយោគក្នុងកម្មវិធីបណ្តុះបណ្តាល ការលើកកម្ពស់លក្ខខណ្ឌការងារ និងការជំរុញឱ្យមានសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈផ្សេងៗ ដើម្បីទាក់ទាញបេក្ខជនដែលមានសមត្ថភាពឱ្យកាន់តែទូលំទូលាយ និងបង្កើតបរិយាកាសជ្រើសរើសបុគ្គលិកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពជាងមុន។

រូបភាពទី ៨៖ មូលហេតុដែលនិយោជកលំបាកក្នុងការជ្រើសរើសបុគ្គលិក




*ចំណាំ៖ សម្រាប់ពណ៌ទឹកក្រូច គឺជាមូលហេតុដែលធ្វើឱ្យមានកង្វះជំនាញ (មើលឧបសម្ព័ន្ធ ខ រូបភាព ខ.១)។

**ចំនួនសហគ្រាស គ្រឹះស្ថានជួបបញ្ហាលំបាកក្នុងការជ្រើសរើសបុគ្គលិកគឺ ១ ១០៤។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

## ២.៣ ទស្សនវិស័យការងារតាមក្រុមមុខរបរ

### ២.៣.១ រដ្ឋបាល និងធនធានមនុស្ស (គ្រប់វិស័យ)

តាមការសិក្សាស្រាវជ្រាវ បានបង្ហាញឱ្យឃើញថាទីផ្សារការងារនៅកម្ពុជាមានការប្រែប្រួល និងមានកំណើនតម្រូវការកម្លាំងពលកម្មក្នុងវិស័យមួយចំនួននៅឆមាសទី១ ឆ្នាំ២០២៥។ គួររំលឹកឡើងវិញថា សម្រាប់សន្ទស្សន៍ដែលកាន់តែខ្ពស់គឺមានន័យថាឱកាសការងារសម្រាប់ក្រុមមុខរបរណាមួយនោះកាន់តែល្អ។ នៅក្នុងឆមាសទី១ ឆ្នាំ២០២៥ នេះ ឱកាសការងារសម្រាប់ក្រុមមុខរបរផ្នែករដ្ឋបាល និងធនជានមនុស្សបានបង្ហាញថាក្រុមមុខរបរមួយ

ចំនួនកំពុងតែមានតម្រូវការខ្ពស់ ដូចជាអ្នកមើលការខុសត្រូវការិយាល័យ (៣,៨៦) បន្ទាប់មកអ្នកជំនាញផ្នែកធនធានមនុស្ស ឬជ្រើសរើសបុគ្គលិក (៣,៧០) បុគ្គលិក ឬជំនួយការផ្នែកធនធានមនុស្ស (៣,៤៤) និងនាយកគ្រប់គ្រងធនធានមនុស្ស (៣,២៥) ជាដើម (តារាងទី៩)។ ក្រៅពីនេះ ឱកាសការងារសម្រាប់ក្រុមមុខរបរផ្សេងទៀត ដូចជាបុគ្គលិកការិយាល័យទូទៅ លេខាធិការផ្នែករដ្ឋបាល និងប្រតិបត្តិ លេខាធិការទូទៅ និងអ្នកទទួលភ្ញៀវទូទៅគឺមានតម្រូវការមធ្យម។

សម្រាប់អ្នកដែលមានជំនាញគ្រប់គ្រងការិយាល័យ គឺជាជំនាញដែលទទួលបានប្រាក់ឈ្នួលខ្ពស់បំផុត។ មុខតំណែងដែលរំពឹងថាទទួលបានប្រាក់ខែខ្ពស់ជាងគេក្នុងឆមាសទី១ ឆ្នាំ២០២៥ នេះគឺអ្នកមើលការខុសត្រូវការិយាល័យ និងនាយកគ្រប់គ្រងធនធានមនុស្ស។ តួនាទីអ្នកគ្រប់គ្រងការិយាល័យមានតម្រូវការខ្ពស់ក្នុងទីផ្សារការងារនៅប្រទេសកម្ពុជា ដោយសារគ្រប់អាជីវកម្ម និងការវិនិយោគតម្រូវឱ្យមានអ្នកជំនាញក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលប្រកបដោយប្រសិទ្ធភាព ជំនាញទំនាក់ទំនង សមត្ថភាពក្នុងការគ្រប់គ្រងក្រុម ជួយសម្របសម្រួល និងដោះស្រាយបញ្ហាផ្សេងៗទៀត។ តួនាទីជាអ្នកគ្រប់គ្រងធនធានមនុស្សក៏មានតម្រូវការខ្ពស់ផងដែរ ដោយសារមានតម្រូវការក្នុងការគ្រប់គ្រងកម្លាំងពលកម្មប្រកបដោយប្រសិទ្ធភាព និងអនុលោមទៅតាមច្បាប់ស្តីពីការងារ។

តារាងទី ៩៖ ឱកាសការងារសម្រាប់ក្រុមមុខរបរផ្នែករដ្ឋបាល និងធនធានមនុស្ស

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 3341 | អ្នកមើលការខុសត្រូវការិយាល័យ | 3.13 | 3.86 | $ 1,019 | $ 187 |
| 2 | 2423 | អ្នកជំនាញផ្នែកធនធានមនុស្ស ឬជ្រើសរើសបុគ្គលិក | 3.27 | 3.70 | $ 584 | $ 141 |
| 3 | 4416 | បុគ្គលិក ឬជំនួយការផ្នែកធនធានមនុស្ស | 3.40 | 3.44 | $ 441 | $ 70 |
| 4 | 1212 | នាយកគ្រប់គ្រងធនធានមនុស្ស | 3.11 | 3.25 | $ 977 | $ 186 |
| 5 | 4110 | បុគ្គលិកការិយាល័យទូទៅ | 2.83 | 3.20 | $ 504 | $ 99 |
| 6 | 3343 | លេខាធិការផ្នែករដ្ឋបាល និងប្រតិបត្តិ | 2.96 | 3.11 | $ 548 | $ 99 |
| 7 | 4120 | លេខាធិការ (ទូទៅ) | 2.50 | 3.00 | $ 614 | $ 87 |
| 8 | 4226 | អ្នកទទួលភ្ញៀវ (ទូទៅ) | 2.60 | 2.84 | $ 319 | $ 67 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

## ២.៣.២ ហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្ម (លើកលែងវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង)

លទ្ធផលនៃសិក្សាស្រាវជ្រាវ បង្ហាញឱ្យឃើញថាទីផ្សារការងារក្នុងក្រុមមុខរបរផ្នែកហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្ម កំពុងមានកំណើនខ្លាំង និងផ្តល់ឱកាសការងារច្រើនដល់អ្នកដែលមានជំនាញសម្រាប់បំពេញតម្រូវការទីផ្សារការងារប្រទេសកម្ពុជា ជាពិសេសមុខតំណែងដូចជា ជំនួយការគណនេយ្យករ និងអ្នកជំនាញគ្រប់គ្រងការផ្គត់ផ្គង់ ដែលត្រូវបានព្យាករថានឹងមានតម្រូវការខ្ពស់ក្នុងឆមាសទី១ ឆ្នាំ២០២៥ បើប្រៀបធៀបនឹងមុខតំណែងផ្សេងៗទៀត។

ការងារក្នុងក្រុមមុខរបរនេះ ប្រាក់ឈ្នួលមានការប្រកួតប្រជែងទៅតាមតួនាទី និងមុខតំណែងការងារនីមួយៗ។ ការងារដែលមានតួនាទីជាអ្នកគ្រប់គ្រងទទួលបានប្រាក់ឈ្នួលខ្ពស់ ដោយតួនាទីនេះទទួលខុសត្រូវខ្ពស់ដូចជាក្នុងប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ និងត្រូវមានកម្រិតជំនាញច្បាស់លាស់ក្នុងការដោះស្រាយបញ្ហា និងជំនាញខ្ពស់ក្នុងការគ្រប់គ្រងស្ថិរភាពហិរញ្ញវត្ថុក្នុងអាជីវកម្មទាំងមូល។ ក្រៅពីនេះ ប្រាក់ឈ្នួលនៃប្រភេទមុខរបរផ្សេងទៀតមានគម្លាតផ្សេងៗគ្នាទៅតាមតួនាទី និងមុខតំណែងនីមួយៗ ដោយគម្លាតប្រាក់ឈ្នួលនេះផ្អែកទៅលើទំនួលខុសត្រូវ កម្រិតជំនាញ និងបទពិសោធន៍។

សរុបមក ទីផ្សារការងារក្នុងក្រុមមុខរបរផ្នែកហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្មនេះនៅតែបន្តមានតម្រូវការទីផ្សារការងារក្នុងប្រទេសកម្ពុជា។ លើសពីនេះ ឱកាសការងារមានកាន់តែច្រើនសម្រាប់អ្នកមានជំនាញហិរញ្ញវត្ថុច្បាស់លាស់ ដូចនេះដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ បុគ្គលម្នាក់ៗត្រូវបន្តអភិវឌ្ឍជំនាញ បទពិសោធន៍ដើម្បីយកទៅអនុវត្តការងារក្នុងក្រុមមុខរបរនេះប្រកបដោយភាពជោគជ័យ និងអាចបំពេញតម្រូវការទីផ្សារការងារប្រកបដោយភាពប្រកួតប្រជែងខ្ពស់។

តារាងទី ១០៖ ឱកាសការងារសម្រាប់ក្រុមមុខរបរផ្នែកហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្ម

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 3313 | ជំនួយការគណនេយ្យករ | 3.08 | 3.29 | $ 506 | $ 87 |
| 2 | 1324 | នាយកគ្រប់គ្រងការផ្គត់ផ្គង់ ការចែកចាយ និងពាក់ព័ន្ធផ្សេងទៀត | 2.64 | 3.25 | $ 1,434 | $ 269 |
| 3 | 2411 | គណនេយ្យករ (កម្រិតខ្ពស់) ឬសវនករ | 3.39 | 3.20 | $ 841 | $ 199 |
| 4 | 4311 | បុគ្គលិកទូទៅផ្នែកកត់ត្រាគណនេយ្យ និងបញ្ជី | 3.22 | 3.16 | $ 435 | $ 83 |
| 5 | 3323 | បុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម | 3.25 | 3.08 | $ 539 | $ 100 |
| 6 | 1211 | នាយកគ្រប់គ្រងហិរញ្ញវត្ថុ | 3.15 | 2.81 | $ 1,455 | $ 256 |
| 7 | 4321 | បុគ្គលិកផ្នែកកត់ត្រាខាងស្តុកទំនិញ | 2.86 | 2.52 | $ 409 | $ 98 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៣.៣ ការលក់ និងទីផ្សារ (លើកលែងតែវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង)

តារាងទី ១១ បានបង្ហាញឱ្យឃើញថា ការងារសម្រាប់ជំនាញគ្រប់គ្រងការផ្សព្វផ្សាយ ទំនាក់ទំនងសាធារណៈ និងផ្នែកលក់ នៅក្នុងឆមាសទី២ ឆ្នាំ២០២៤ និងឆមាសទី១ ឆ្នាំ២០២៥ មានតម្រូវការយ៉ាងខ្លាំងក្នុងទីផ្សារការងារកម្ពុជា។ ចំពោះប្រាក់ឈ្នួលសម្រាប់អ្នកមានតួនាទីជានាយកគ្រប់គ្រងទទួលបានប្រាក់ឈ្នួលខ្ពស់ជាងគេ ដែលក្នុងនោះមានដូចជានាយកគ្រប់គ្រងការលក់និងទីផ្សារ និងនាយកគ្រប់គ្រងការផ្សព្វផ្សាយនិងទំនាក់ទំនងសាធារណៈ។ ជំនាញអ្នកគ្រប់គ្រងការលក់ និងទីផ្សារនេះ ក៏ជាជំនាញដែលទទួលបានការលើកទឹកចិត្តខ្ពស់ និងអត្ថប្រយោជន៍ច្រើនផងដែរ។ តាមទិន្នន័យបានបង្ហាញថា ការងារផ្នែកលក់ និងទីផ្សារមានសក្តានុពលដែលអាចបង្កើតឱកាសការងារច្រើន និងមានភាពចាំបាច់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា។ អាជីពក្នុងក្រុមមុខរបរនេះមានតម្រូវការចាំបាច់នៅក្នុងទីផ្សារការងារ ហើយប្រាក់ឈ្នួលក៏មានភាពប្រកួតប្រជែងទៅតាមតួនាទី និងផ្នែកនីមួយៗផងដែរ។ ខណៈដែលការងារក្នុងក្រុមមុខរបរនេះមានតម្រូវការ និងឱកាសការងារច្រើន បុគ្គលត្រូវមានជំនាញច្បាស់លាស់ គុណវុឌ្ឍិ ការច្នៃប្រឌិត យុទ្ធសាស្ត្រល្អៗក្នុងការអភិវឌ្ឍសមត្ថភាព ដើម្បីបំពេញនូវតម្រូវការជំនាញ និងសម្រេចភាពជោគជ័យក្នុងក្រុមមុខរបរនេះ។

តារាងទី ១១៖ ឱកាសការងារសម្រាប់ក្រុមមុខរបរផ្នែកលក់ និងទីផ្សារ

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 1222 | នាយកគ្រប់គ្រងការផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ | 4.40 | 4.17 | $ 960 | $ 176 |
| 2 | 2432 | វិជ្ជាជីវៈខាងទំនាក់ទំនងសាធារណៈ | 3.20 | 3.50 | $ 559 | $ 125 |
| 3 | 3322 | អ្នកតំណាងលក់ផ្នែកពាណិជ្ជកម្ម | 3.30 | 3.42 | $ 546 | $ 79 |
| 4 | 2431 | វិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ | 3.08 | 3.17 | $ 640 | $ 128 |
| 5 | 1221 | នាយកគ្រប់គ្រងការលក់ និងទីផ្សារ | 3.19 | 3.13 | $ 1,166 | $ 401 |
| 6 | 5244 | អ្នកលក់ ឬអ្នកទីផ្សារតាមទូរស័ព្ទ | 2.83 | 2.70 | $ 549 | $ 82 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៣.៤ ជួសជុល ថែទាំ និងគាំទ្រទូទៅ (គ្រប់វិស័យ)

ឱកាសការងារសម្រាប់ក្រុមមុខរបរក្នុងផ្នែកជួសជុល ថែទាំ និងគាំទ្រទូទៅបានបង្ហាញថាតួនាទីជាអ្នកជំនាញអគ្គិសនី អ្នកដឹកជញ្ជូនអីវ៉ាន់ អ្នកបើកបររថយន្ត និងអ្នកមើលការខុសត្រូវផ្នែកសម្អាតនិងការថែរក្សាក្នុងសហគ្រាស

មានតម្រូវការមធ្យម សម្រាប់ធមាសទី១ ឆ្នាំ២០២៥។ ផ្ទុយទៅវិញ ការងារជាអ្នកមើលការខុសត្រូវអាគារ អ្នកសម្អាតអនាម័យនិងអ្នកជួយកិច្ចការផ្សេងៗក្នុងសហគ្រាស និងអ្នកការពារសន្តិសុខ មានតម្រូវការទាបក្នុងធមាសទី១ ឆ្នាំ២០២៥។ គួរកត់សម្គាល់ផងដែរថា ទោះបីតួនាទីជាអ្នកមើលការខុសត្រូវអាគារបានបង្ហាញពីឱកាសការងារទាប ប៉ុន្តែការងារនេះអាចទទួលបានប្រាក់ឈ្នួលខ្ពស់ជាងគេក្នុងចំណោមការងារផ្សេងៗក្នុងផ្នែកជួសជុល ថែទាំ និងគាំទ្រទូទៅនេះ។ ជាងអគ្គិសនី និងអ្នកបើកបររថយន្តក៏អាចទទួលបានប្រាក់ឈ្នួលខ្ពស់គួរសមបន្ទាប់ពីអ្នកមើលការខុសត្រូវអាគារដែរ។

តារាងទី ១២៖ ឱកាសការងារសម្រាប់ក្រុមមុខរបរផ្នែកជួសជុល ថែទាំ និងគាំទ្រទូទៅ

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ធមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ធមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 9621 | អ្នកនាំសារ អ្នកដឹកជញ្ជូនកញ្ចប់អីវ៉ាន់ និងអ្នកជួយយួរវ៉ាលី | 3.13 | 3.17 | $ 252 | $ 97 |
| 2 | 7411 | ជាងអគ្គិសនីទូទៅ | 3.09 | 3.12 | $ 367 | $ 153 |
| 3 | 8322 | អ្នកបើកបររថយន្តតូច រថយន្តឈ្នួល និងរថយន្តវែន | 3.03 | 3.00 | $ 316 | $ 90 |
| 4 | 5151 | អ្នកមើលការខុសត្រូវផ្នែកសម្អាត និងការថែរក្សាក្នុងសហគ្រាស | 2.08 | 2.90 | $ 275 | $ 71 |
| 5 | 5414 | អ្នកការពារសន្តិសុខ | 3.10 | 2.67 | $ 257 | $ 80 |
| 6 | 9112 | អ្នកសម្អាតអនាម័យ និងអ្នកជួយធ្វើកិច្ចការផ្សេងៗក្នុងសហគ្រាស | 2.89 | 2.66 | $ 246 | $ 80 |
| 7 | 5153 | អ្នកមើលការខុសត្រូវអាគារ | 2.47 | 2.00 | $ 419 | $ 58 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៣.៥ ការគាំទ្រផ្នែកព័ត៌មាន និងបច្ចេកវិទ្យា (លើកលែងតែវិស័យ ICT)

ទិន្នន័យស្តីពីទីផ្សារការងារផ្នែកព័ត៌មាន និងបច្ចេកវិទ្យាក្នុងធមាសទី១ ឆ្នាំ២០២៥ បានបង្ហាញពីឱកាសការងារល្អៗ ដែលក្នុងនោះក្រុមមុខរបរដែលមានតម្រូវការខ្ពស់ជាងគេក្នុងទីផ្សារការងារគឺអ្នកដែលមានតួនាទីជានាយកគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា ដែលមានទាំងសន្ទស្សន៍ការងារ និងប្រាក់ឈ្នួលខ្ពស់ជាងគេធៀបទៅនឹងប្រភេទមុខរបរផ្សេងទៀត។ ទន្ទឹមគ្នានេះ អ្នកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ, អ្នករចនាក្រាហ្វិច និងម៉ាលជីមេឌៀ, អ្នកតម្លើង និងអ្នកផ្តល់សេវាបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា, និងអ្នកបច្ចេកទេសគាំទ្រដល់អ្នកប្រើប្រាស់នូវបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ក៏សុទ្ធតែបង្ហាញពីតម្រូវការខ្ពស់ក្នុងទីផ្សារការងារផងដែរ។

ចំពោះប្រាក់ឈ្នួលសម្រាប់ការងារក្នុងក្រុមមុខរបរទាំងនេះ គឺមានភាពប្រកួតប្រជែងគ្នាទៅតាមតួនាទី និងមុខតំណែងនីមួយៗ។ នាយកគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាទទួលបានប្រាក់ឈ្នួលខ្ពស់ជាងគេដោយទទួលបានចំនួនប្រមាណ ១ ០១៩ដុល្លារអាមេរិក និងទទួលបានអត្ថប្រយោជន៍ផ្សេងជាច្រើនផងដែរ។ តារាងទី១៣ ជារួមបង្ហាញថា ការងារក្នុងផ្នែកព័ត៌មាន និងបច្ចេកវិទ្យា គឺជាការងារដែលមានតម្រូវការខ្ពស់ក្នុងទីផ្សារការងារនៅកម្ពុជា ហើយប្រាក់ឈ្នួលក្នុងវិស័យនេះក៏មានភាពប្រកួតប្រជែងខ្លាំងផងដែរ។ ការណ៍នេះ បញ្ជាក់ឱ្យឃើញថា ប្រទេសកម្ពុជាកំពុងតែមានតម្រូវការយ៉ាងខ្លាំងក្លាចំពោះបច្ចេកវិទ្យា ដើម្បីជំរុញការអភិវឌ្ឍប្រទេស និងឆ្ពោះទៅរកភាពជឿនលឿនក្នុងវិស័យបច្ចេកវិទ្យានាពេលអនាគត។

តារាងទី ១៣៖ ឱកាសការងារសម្រាប់មុខរបរគាំទ្រផ្នែកព័ត៌មាន និងបច្ចេកវិទ្យា (IT)

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 1330 | នាយកគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា | 3.37 | 3.85 | $ 1,019 | $ 266 |
| 2 | 2522 | អ្នកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ | 2.74 | 3.50 | $ 579 | $ 62 |
| 3 | 2166 | អ្នករចនាក្រាហ្វិច និងម៉ាល់ធីមេឌៀ | 2.83 | 3.50 | $ 674 | $ 83 |
| 4 | 7422 | អ្នកតម្លើង និងអ្នកផ្តល់សេវាបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា | 3.35 | 3.33 | $ 537 | $ 43 |
| 5 | 3512 | អ្នកបច្ចេកទេសគាំទ្រដល់អ្នកប្រើប្រាស់នូវបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា | 4.03 | 3.25 | $ 484 | $ 50 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

## ២.៤ ទស្សនវិស័យការងារតាមអនុវិស័យ

### ២.៤.១ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT)

អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) នៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥នេះ ដែលបង្ហាញតាមរយៈការកើនឡើងនូវចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS ពីចំនួន ១ ២២៩ ក្នុងឆមាសទី២ ឆ្នាំ២០២៤ មកដល់ចំនួន ១ ៦៣០ សហគ្រាស គ្រឹះស្ថាន ក្នុងឆមាសទី១ ឆ្នាំ២០២៥។ ទន្ទឹមនឹងការកើនឡើងនៃចំនួនសហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះ ការផ្គត់ផ្គង់កម្មករជំនាញក្នុងទីផ្សារការងារក៏បានកើនឡើងទាំងបរិមាណ និងគុណភាព។ ជាក់ស្តែង ភាគរយនៃសហគ្រាស

គ្រឹះស្ថានដែលរាយការណ៍ពីការលំបាកក្នុងការជ្រើសរើសបុគ្គលិក បានធ្លាក់ចុះពី ៣៦,៣៩% មកត្រឹម ១៦,៣៦% ហើយភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស ក៏បានធ្លាក់ចុះ ពី ៣,០៨% មកត្រឹម ១,០% ផងដែរ។

សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិតស្មើនឹង ៣,០៣ បង្ហាញពីស្ថានភាពក្នុងការស្វែងរកបេក្ខជនមកបំពេញការងារមានភាពងាយស្រួលជាងឆមាសមុន។ ការរីកចម្រើនយ៉ាងឆាប់រហ័សនេះត្រូវបានជំរុញដោយការកើនឡើងនៃឌីជីថលូបនីយកម្មរបស់ប្រទេសកម្ពុជា ការកើនឡើងនៃតម្រូវការសេវាកម្ម IT និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍។ កម្មករ និយោជិតជំនាញក្នុងអនុវិស័យនេះ ក៏ត្រូវប្រឈមនឹងការបង្កើនភាពប្រកួតប្រជែងក្នុងទីផ្សារការងារ ដែលតម្រូវឱ្យមានការបន្តអភិវឌ្ឍជំនាញជាប្រចាំទាំងជំនាញទន់ និងជំនាញរឹង។ ជំនាញទន់ដែលមានតម្រូវការខ្ពស់ជាងគេ ចំនួន ៥ រួមមាន ជំនាញទំនាក់ទំនងផ្ទាល់មាត់, ការដោះស្រាយបញ្ហា, ជំនាញទំនាក់ទំនងជាលាយលក្ខណ៍អក្សរ , ការសម្របសម្រួល, និងការគ្រប់គ្រងពេលវេលា។ ជំនាញបច្ចេកទេស ឬ ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់រួមមានមូលដ្ឋានគ្រឹះកុំព្យូទ័រ, ការដោះស្រាយបញ្ហាប្រព័ន្ធ និងសុវត្ថិភាពតាមអ៊ីនធឺណិត, ជំនាញទីផ្សារឌីជីថល, ចំណេះដឹងផ្នែកច្បាប់ និងអនុលោមភាព, និងជំនាញការវិភាគប្រព័ន្ធ និងការវាយតម្លៃ។

តារាងទី ១៤៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យ ICT

| បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 1,229 | 1,630 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 78.60% | 76.99% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 49.31% | 41.96% |
| | 5-19 | 49.23% | 48.28% |
| | 20-99 | 1.46% | 8.22% |
| | 100-199 | 0.00% | 0.80% |
| | 200-499 | 0.00% | 0.55% |
| | 500+ | 0.00% | 0.18% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 4.14% | 30.65% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 58.70% | 19.10% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 33.04% | 70.60% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 36.39% | 16.36% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 3.08% | 1.00% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 3.26 | 3.03 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 1,369 | 205 |

| | |
|---|---|
| ១. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ |
| ២. ការដោះស្រាយបញ្ហា | |
| ៣. ជំនាញទំនាក់ទំនងជាលាយលក្ខណ៍អក្សរ | |
| ៤. ការសម្របសម្រួល | |
| ៥. ការគ្រប់គ្រងពេលវេលា | |
| ១. មូលដ្ឋានគ្រឹះកុំព្យូទ័រ | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ |
| ២. ការដោះស្រាយបញ្ហាប្រព័ន្ធ និងសុវត្ថិភាពតាមអ៊ីនធឺណិត | |
| ៣. ជំនាញទីផ្សារឌីជីថល | |
| ៤. ចំណេះដឹងផ្នែកច្បាប់ និងអនុលោមភាព | |
| ៥. ការវិភាគប្រព័ន្ធ និងការវាយតម្លៃ | |
| ១. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក |
| ២. មិនមានទិន្នន័យ | |
| ៣. មិនមានទិន្នន័យ | |
| ៤. មិនមានទិន្នន័យ | |
| ៥. មិនមានទិន្នន័យ | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្លេង), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

ការវិភាគទីផ្សារការងារសម្រាប់អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា(ICT) បង្ហាញថា ក្នុងឆមាសទី១ ឆ្នាំ២០២៥ មុខតំណែងចំនួនពីរដែលមានឱកាសការងារខ្ពស់ជាងគេក្នុងវិស័យនេះ គឺមុខតំណែងជាអ្នករចនាក្រាហ្វិក និងម៉ាលធីមេឌៀ (Multimedia) និងមុខតំណែងជាអ្នកដំឡើង និងអ្នកផ្តល់សេវាបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា ខណៈពេលដែលមុខតំណែងជាគណនេយ្យករ (កម្រិតខ្ពស់) ឬសវនករ និងអ្នកវិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារអាចមានឱកាសការងារកម្រិតធម្មតាបើធៀបនឹងការងារផ្សេងទៀត។

តារាងទី១៥ ដដែលនេះបង្ហាញពីប្រាក់ឈ្នួលក្នុងអនុវិស័យ ICT តាមមុខរបរផ្សេងៗគ្នា ដោយអ្នកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ បានក្លាយជាអ្នកជំនាញដែលមានប្រាក់ឈ្នួលខ្ពស់បំផុត ដោយទទួលបានជាមធ្យមប្រចាំខែចំនួន ១ ០០៤ដុល្លារអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់ឈ្នួលមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងទៅតាមតួនាទី និងជំនាញផ្សេងៗគ្នា។ ជាក់ស្តែង ទោះបីជាឱកាសការងារសម្រាប់អ្នកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រមានកម្រិតទាបជាងគេ ប៉ុន្តែមុខរបរនេះទទួលបានប្រាក់ឈ្នួលរហូតដល់ជាង ៣ដង ច្រើនជាងអ្នកវិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ និងអ្នកដែលមានមុខតំណែងជាអ្នករចនាក្រាហ្វិក និងម៉ាលធីមេឌៀ។ ដោយឡែក មុខរបរដែលមានសន្ទស្សន៍ខ្ពស់ជាងគេសម្រាប់ឆមាសទី១ ឆ្នាំ២០២៥ គឺអ្នកតម្លើង និងអ្នកផ្តល់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា និងអ្នករចនាក្រាហ្វិច និងម៉ាលធីមេឌៀ (៤,០) ដែលបង្ហាញពីឱកាសច្រើនសម្រាប់អ្នកស្វែងរកការងារធ្វើ និងមានជំនាញដែលឆ្លើយតបនឹងតួនាទីទាំងនេះ។

តារាងទី ១៥៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យ ICT

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 7422 | អ្នកតម្លើង និងអ្នកផ្តល់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា | 3.35 | 4.00 | $ 408 | |
| 2 | 2166 | អ្នករចនាក្រាហ្វិច និងម៉ាល់ធីមេឌៀ | 2.83 | 4.00 | $ 317 | |
| 3 | 2411 | គណនេយ្យករ (កម្រិតខ្ពស់) ឬសវនករ | 3.39 | 3.00 | $ 600 | |
| 4 | 2431 | វិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ | 3.08 | 3.00 | $ 309 | $ 20 |
| 5 | 2522 | អ្នកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ | 2.74 | 2.00 | $ 1,004 | |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៤.២ សេវាស្នាក់នៅ និងភោជនីយដ្ឋាន

តារាងទី ១៦ ផ្តល់នូវទិដ្ឋភាពនៃអនុវិស័យសេវាស្នាក់នៅ និងភោជនីយដ្ឋានក្នុងប្រទេសកម្ពុជា។ ចំនួនសរុបនៃសហគ្រាស និងគ្រឹះស្ថានក្នុងវិស័យនេះមានការថយចុះតិចតួចពី ៥ ៥៧១ ក្នុងឆមាសទី២ ឆ្នាំ២០២៤ មកត្រឹម ៥ ៤២១ ក្នុងឆមាសទី១ ឆ្នាំ២០២៥ ដែលភាគច្រើននៃសហគ្រាស គ្រឹះស្ថាន (៨០,៨៧%) ជាសហគ្រាស មានបុគ្គលិកពី ៥ ទៅ ១៩ នាក់។ ភាគរយនៃសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញមានការថយចុះគួរឱ្យកត់សម្គាល់ពី ៣៥,៨៤% មក ១៧,៨៧% ផ្ទុយមកវិញភាគរយនៃសហគ្រាស គ្រឹះស្ថានដែលជួបនឹងកង្វះជំនាញមានការកើនឡើងគួរឱ្យបារម្ភពី ៣,៣០% មក ១៣,២២% ដែលបង្ហាញអំពីតម្រូវការបង្កើនការបណ្តុះបណ្តាលជំនាញ ហើយជំនាញបច្ចេកទេសដែលត្រូវការជាងគេទាំង ៥ នៅក្នុងអនុវិស័យសេវាស្នាក់នៅ និងភោជនីយដ្ឋានរួមមាន ភាសាអង់គ្លេស, ការត្រួតពិនិត្យប្រតិបត្តិការ, ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ, ការគ្រប់គ្រងធនធានមនុស្ស, និងជំនាញការវិភាគការគ្រប់គ្រងគុណភាព។ បន្ថែមពីលើជំនាញរឹងទាំង ៥ ខាងលើ អ្នកធ្វើការនៅក្នុងអនុវិស័យសេវាស្នាក់នៅ និងភោជនីយដ្ឋាន ត្រូវការជំនាញទន់ដូចជា ការដោះស្រាយបញ្ហា, ការគ្រប់គ្រងអតិថិជន, ជំនាញទំនាក់ទំនងផ្ទាល់មាត់, ជំនាញទំនាក់ទំនងជាលាយលក្ខណ៍អក្សរ , និងការសម្របសម្រួល។

ភាគរយនៃសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ មានការកើនឡើងពី ៥២,០១% មក ៦១,១២%។ ទោះយ៉ាងណាក៏ដោយ ចំនួនប្រកាសជ្រើសរើសកម្មករនិយោជិតដែលរំពឹងទុក និងសន្ទស្សន៍ឱកាសការងារសម្រាប់កម្មករនិយោជិតមានការថយចុះ យ៉ាងខ្លាំងពី ៥ ៦០៨កន្លែង ក្នុងឆមាសទី២ ឆ្នាំ២០២៤ មកត្រឹម ២ ២៦៨កន្លែង ក្នុងឆមាសទី១ ឆ្នាំ២០២៥ដែលបង្ហាញពីការថយចុះនៃតម្រូវការទីផ្សារការងារ។

លើសពីនេះ ភាគរយនៃសហគ្រាស គ្រឹះស្ថានដែលផ្ដល់ឱកាសដល់អ្នកស្វែងរកការងារដំបូងថយចុះពី ៥៧,៣២% មក ២៣,៦១% ដែលអាចប៉ះពាល់ដល់យុវជនដែលទើបបញ្ចប់ការសិក្សា និងពុំធ្លាប់មានបទពិសោធន៍ការងារពីមុន។

តារាងទី ១៦៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យសេវាស្នាក់នៅ និងភោជនីយដ្ឋាន

| សេវាស្នាក់នៅ និងភោជនីយដ្ឋាន | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 5,571 | 5,421 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 59.38% | 59.12% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 16.78% | 11.47% |
| | 5-19 | 76.13% | 80.87% |
| | 20-99 | 5.49% | 5.92% |
| | 100-199 | 0.83% | 0.85% |
| | 200-499 | 0.59% | 0.70% |
| | 500+ | 0.18% | 0.18% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 35.84% | 17.87% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្ដល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 57.32% | 23.61% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 52.01% | 61.12% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 32.24% | 45.22% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 3.30% | 13.22% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 3.52 | 3.43 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 5,608 | 2,268 |
| ១. ការដោះស្រាយបញ្ហា | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | | |
| ២. ការគ្រប់គ្រងអតិថិជន | | | |
| ៣. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | | | |
| ៤. ជំនាញទំនាក់ទំនងជាលាយលក្ខណ៍អក្សរ | | | |
| ៥. ការសម្របសម្រួល | | | |
| ១. ភាសាអង់គ្លេស | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | | |
| ២. ការត្រួតពិនិត្យប្រតិបត្តិការ | | | |
| ៣. ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ | | | |
| ៤. ការគ្រប់គ្រងធនធានមនុស្ស | | | |
| ៥. ការវិភាគការគ្រប់គ្រងគុណភាព | | | |
| ១. ការប្រកួតប្រជែងខ្លាំងពីនិយោជកផ្សេងទៀត | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក | | |
| ២. កង្វះខាតបេក្ខជនជាទូទៅ | | | |
| ៣. កង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ | | | |
| ៤. លក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែងនេះ (ឧ. ប្រាក់ខែតិច) | | | |

| ៥. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច |
|---|

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្ដើង), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

សន្ទស្សន៍សម្រាប់តួនាទីជំនួយការគណនេយ្យករ អ្នកទទួលភ្ញៀវក្នុងសណ្ឋាគារ និងបុគ្គលិក ឬជំនួយការផ្នែកធនធានមនុស្ស មានការធ្លាក់ចុះបើប្រៀបធៀបទៅនឹងឆមាសទី២ ឆ្នាំ២០២៤ ប៉ុន្តែមុខរបរទាំងនេះនៅតែស្ថិតក្នុងកម្រិតឱកាសការងារធម្មតា ឬជាមុខរបរដែលមានតម្រូវការមធ្យម ខណៈដែលមុខរបរភាគច្រើនក្នុងអនុវិស័យនេះសុទ្ធតែបានធ្លាក់ទៅក្នុងកម្រិតឱកាសការងារទាប មានន័យថាមានការថយចុះនូវតម្រូវការបើប្រៀបធៀបទៅនឹងឆមាសទី២ ឆ្នាំ២០២៤ (តារាងទី១៧)។

ទិន្នន័យប្រាក់ឈ្នួលក្នុងតារាងដដែលបង្ហាញថា នាយកគ្រប់គ្រងសណ្ឋាគារ គឺជាមុខតំណែងដែលមានឱកាសការងារខ្ពស់ជាងគេ ព្រមទាំងមានប្រាក់ឈ្នួលខ្ពស់បំផុត ដោយទទួលបានជាមធ្យមប្រចាំខែចំនួន ៨៧៥ ដុល្លារអាម៉េរិក ដែលឆ្លុះបញ្ចាំងពីតួនាទីជាអ្នកដឹកនាំ និងការទទួលខុសត្រូវខ្ពស់របស់ពួកគេ។ បន្ទាប់មកគឺ ជំនួយការគណនេយ្យករ ចុងភៅ និងបុគ្គលិក ឬជំនួយការផ្នែកធនធានមនុស្ស គឺជាមុខតំណែងដែលមានប្រាក់ឈ្នួលខ្ពស់ជាងមុខរបរដទៃទៀតនៅក្នុងវិស័យនេះ។

សម្រាប់មុខតំណែងទូទៅទោះបីជាមានប្រាក់ឈ្នួលគោលទាបក៏ដោយ ការងារនៅក្នុងវិស័យនេះមានឱកាសច្រើន និងសក្ដានុពលនៃប្រាក់ចំណូលបន្ថែមដូចជាប្រាក់រង្វាន់ (Tip)។ លើសពីនេះ ដោយសារការខិតខំប្រឹងប្រែងក្នុងការទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិ និងក្នុងស្រុក ធ្វើឱ្យតម្រូវការសេវាកម្មបដិសណ្ឋារកិច្ចត្រូវបានគេរំពឹងថានឹងកើនឡើង ដែលជំរុញការបង្កើតការងារបន្ថែម និងកំណើនសេដ្ឋកិច្ច។

តារាងទី ១៧៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យសេវាស្នាក់នៅ និងភោជនីយដ្ឋាន

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 1411 | នាយកគ្រប់គ្រងសណ្ឋាគារ | 3.29 | 4.40 | $ 875 | $ 185 |
| 2 | 3313 | ជំនួយការគណនេយ្យករ | 3.08 | 3.00 | $ 480 | $ 139 |
| 3 | 4224 | អ្នកទទួលភ្ញៀវក្នុងសណ្ឋាគារ | 3.32 | 2.90 | $ 333 | $ 94 |
| 4 | 4416 | បុគ្គលិក ឬជំនួយការផ្នែកធនធានមនុស្ស | 3.40 | 2.85 | $ 446 | $ 82 |
| 5 | 4226 | អ្នកទទួលភ្ញៀវ (ទូទៅ) | 2.60 | 2.75 | $ 384 | $ 115 |
| 6 | 5131 | អ្នកបំរើ | 3.60 | 2.64 | $ 307 | $ 128 |
| 7 | 5151 | អ្នកមើលការខុសត្រូវផ្នែកសម្អាត និងការថែរក្សាក្នុងសហគ្រាស | 2.08 | 2.47 | $ 377 | $ 94 |

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 8 | 5120 | ចុងភៅ | 3.84 | 2.43 | $ 447 | $ 112 |
| 9 | 5414 | អ្នកការពារសន្តិសុខ | 3.10 | 2.00 | $ 246 | $ 132 |
| 10 | 5142 | អ្នកតុបតែងសម្ផស្សអោយគេ និងអ្នកធ្វើការដែលពាក់ព័ន្ធ | 3.05 | 2.00 | $ 207 | $ 56 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៤.៣ សំណង់

ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS មានការថយចុះពី ២ ០៩០ ក្នុងឆមាសទី២ ឆ្នាំ២០២៤ មកត្រឹម ១ ៩៨៤ ក្នុងឆមាសទី១ ឆ្នាំ២០២៥។ កំណើនអវិជ្ជមាននេះ គឺប៉ះពាល់ដោយសារការធ្លាក់ចុះនៃគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគអចលនទ្រព្យនៅកម្ពុជា។ ការធ្លាក់ចុះនៃការសាងសង់អគារ បានធ្វើឱ្យកំណើនអវិជ្ជមាននេះកាន់តែធ្ងន់ធ្ងរ ដែលរួមចំណែកដល់ការធ្លាក់ចុះនៃចំនួនការងារនៅក្នុងអនុវិស័យនេះពី ៦ ៧៦កន្លែង មកត្រឹម ១ ០៤០កន្លែង ដែលបង្ហាញពីបម្រែបម្រួលតម្រូវការទីផ្សារការងារក្នុងអនុវិស័យនេះ។ បន្ថែមពីលើនេះ អនុវិស័យនេះមានអាជីវកម្មខ្នាតតូចច្រើនដែល ៨០,៦៥% នៃសហគ្រាស គ្រឹះស្ថានមានបុគ្គលិកពី ៥នាក់ ទៅ ១៩នាក់ នេះបង្ហាញពីសារៈសំខាន់របស់អាជីវកម្មខ្នាតតូច និងមធ្យម ក្នុងការបង្កើតការងារក្នុងអនុវិស័យសំណង់។ ដោយឡែក ភាគរយសហគ្រាស គ្រឹះស្ថាន ដែលជួបបញ្ហាគម្លាតជំនាញមានការថយចុះគួរឱ្យកត់សម្គាល់ (ពី ១៧,១៩% មក ៥,៧៦%) និងភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាកង្វះជំនាញ (ពី ៨,៨៧% មក ៥,៣១%) ដែលបង្ហាញពីភាពប្រសើរឡើងនូវជំនាញរបស់កម្មករ និយោជិត។ ខណៈដែល សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិតមានការថយចុះពី ៣,៥១ មក ២,៩៨ ស្របពេលដែលចំនួនប្រកាសជ្រើសរើសកម្មករនិយោជិតដែលរំពឹងទុកក៏មានការថយចុះគួរឱ្យកត់សម្គាល់ដូចគ្នា ដែលជាសញ្ញាបង្ហាញថាទីផ្សារការងារក្នុងអនុវិស័យសំណង់នឹងបន្តថយចុះនូវតម្រូវការកម្លាំងពលកម្ម។ ការបណ្តុះបណ្តាលជំនាញឱ្យស្របតាមតម្រូវការទីផ្សារ នៅតែដើរតួនាទីយ៉ាងសំខាន់សម្រាប់បេក្ខជនដែលកំពុងស្វែងរកការងារ ដើម្បីទទួលបានការងារល្អក្នុងអនុវិស័យនេះ។ ជំនាញបច្ចេកទេសសំខាន់ៗ ដែលជាតម្រូវការក្នុងអនុវិស័យនេះរួមមានជំនាញទីផ្សារឌីជីថល, ការត្រួតពិនិត្យប្រតិបត្តិការ, គណនេយ្យ និងហិរញ្ញវត្ថុ, ការវិភាគការគ្រប់គ្រងគុណភាព និងភាសាអង់គ្លេស រួមទាំងជំនាញទន់ចំនួន ៥ ទៀតដូចជាជំនាញការដោះស្រាយបញ្ហា, ការត្រួតពិនិត្យ, ការសម្របសម្រួល, ការគ្រប់គ្រងអតិថិជន និងជំនាញទំនាក់ទំនងផ្ទាល់មាត់។

## តារាងទី ១៨៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យសំណង់

| សំណង់ | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 2,090 | 1,984 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 63.06% | 60.38% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 11.91% | 3.07% |
| | 5-19 | 71.05% | 80.65% |
| | 20-99 | 14.83% | 14.06% |
| | 100-199 | 1.24% | 1.36% |
| | 200-499 | 0.67% | 0.55% |
| | 500+ | 0.29% | 0.30% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 17.19% | 5.76% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 87.62% | 4.86% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 44.36% | 41.74% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 21.94% | 1.08% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 8.87% | 5.31% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 3.51 | 2.98 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 6,676 | 1,040 |
| ១. ការដោះស្រាយបញ្ហា | | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការត្រួតពិនិត្យ | | | |
| ៣. ការសម្របសម្រួល | | | |
| ៤. ការគ្រប់គ្រងអតិថិជន | | | |
| ៥. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | | | |
| ១. ជំនាញទីផ្សារឌីជីថល | | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការត្រួតពិនិត្យប្រតិបត្តិការ | | | |
| ៣. ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ | | | |
| ៤. ការវិភាគការគ្រប់គ្រងគុណភាព | | | |
| ៥. ភាសាអង់គ្លេស | | | |
| ១. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក | |
| ២. កន្លែងធ្វើការដាច់ស្រយាល ឬពិបាកមធ្យោបាយធ្វើដំណើរ | | | |
| ៣. ការប្រកួតប្រជែងខ្លាំងពីនិយោជកផ្សេងទៀត | | | |
| ៤. កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧ. សញ្ញាបត្រ) | | | |
| ៥. មិនសូវមានមនុស្សចាប់អារម្មណ៍នឹងការងារប្រភេទនេះ | | | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្លេក), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

ក្នុងឆមាសទី១ ឆ្នាំ២០២៥ អនុវិស័យសំណង់ផ្តល់ឱកាសការងារខ្ពស់សម្រាប់ជំនួយការគណនេយ្យករ ខណៈពេលដែល វិស្វករសំណង់ស៊ីវិល, អ្នកចាក់ប្លង់សេ ចាក់សាប ដាងបូក និងអ្នកធ្វើការដែលពាក់ព័ន្ធ, អ្នកលក់ ឬអ្នកទីផ្សារតាមទូរស័ព្ទ, អ្នកធ្វើការផ្នែកផ្តល់ព័ត៌មានដល់អតិថិជន, លេខាធិការ (ទូទៅ), និងអ្នកទទួលភ្ញៀវ (ទូទៅ) មានឱកាសការងារកម្រិតធម្មតា។

អនុវិស័យសំណង់ ជាអនុវិស័យដែលមានប្រាក់ឈ្នួលមធ្យមប្រចាំខែខ្ពស់គួរឱ្យកត់សម្គាល់ ធៀបនឹងអនុវិស័យផ្សេងទៀត ក្នុងនោះតួនាទីដែលមានប្រាក់ឈ្នួលខ្ពស់ជាងគេគឺ នាយកគ្រប់គ្រងការលក់ និងទីផ្សារ ដែលមានប្រាក់ឈ្នួលជាមធ្យមប្រមាណ ១ ៦៣៧ដុល្លារអាម៉េរិកក្នុងមួយខែ ទោះបីជាតួនាទីនេះមានឱកាសការងារទាបជាងតួនាទីផ្សេងទៀតក៏ដោយ។ តួនាទីផ្សេងទៀតដែលមានប្រាក់ឈ្នួលខ្ពស់ផងដែររួមមាន វិស្វករអគ្គិសនី ដែលមានប្រាក់ឈ្នួល ១ ០៣៧ដុល្លារអាម៉េរិក, អ្នកលក់ ឬអ្នកទីផ្សារតាមទូរស័ព្ទ ដែលមានប្រាក់ឈ្នួល ៨៣៨ដុល្លារអាម៉េរិក និងវិស្វករសំណង់ស៊ីវិលមានប្រាក់ឈ្នួលប្រមាណ ៧៧៤ដុល្លារអាម៉េរិក។ លើសពីនេះ មុខរបរផ្សេងទៀតដូចជា ជំនួយការគណនេយ្យករ, អ្នកចាក់ប្លង់សេ ចាក់សាប ដាងបូក និងអ្នកធ្វើការដែលពាក់ព័ន្ធ, លេខាធិការ, និងអ្នកទទួលភ្ញៀវ មានប្រាក់ឈ្នួលប្រចាំខែទាបជាងគេ គឺចន្លោះពី ២៥០ ទៅ ៦១០ដុល្លារអាម៉េរិក។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថាតួលេខទាំងនេះគឺជាប្រាក់ឈ្នួលជាមធ្យមប៉ុណ្ណោះ ហើយប្រាក់ឈ្នួលពិតប្រាកដប្រែប្រួលអាស្រ័យលើកត្តាជាច្រើនដូចជាជំនាញ បទពិសោធន៍ ទីតាំងភូមិសាស្ត្រ និងទំហំនៃសហគ្រាស គ្រឹះស្ថាន។

តារាងទី ១៩៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យសំណង់

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 3313 | ជំនួយការគណនេយ្យករ | 3.08 | 3.50 | $ 610 | $ 87 |
| 2 | 7114 | អ្នកចាក់ប្លង់សេ ចាក់សាប ដាងបូក និងអ្នកធ្វើការដែលពាក់ព័ន្ធ | 2.57 | 3.00 | $ 300 | $ 25 |
| 3 | 5244 | អ្នកលក់ ឬអ្នកទីផ្សារតាមទូរស័ព្ទ | 2.83 | 3.00 | $ 838 | $ 165 |
| 4 | 4229 | អ្នកធ្វើការផ្នែកផ្តល់ព័ត៌មានដល់អតិថិជន | - | 3.00 | $ 286 | |
| 5 | 4120 | លេខាធិការ (ទូទៅ) | 2.50 | 3.00 | $ 515 | $ 110 |
| 6 | 4226 | អ្នកទទួលភ្ញៀវ (ទូទៅ) | 2.60 | 3.00 | $ 250 | |
| 7 | 2142 | វិស្វករសំណង់ស៊ីវិល | 3.95 | 2.93 | $ 774 | $ 138 |
| 8 | 2151 | វិស្វករអគ្គិសនី | 3.24 | 2.56 | $ 1,037 | $ 185 |
| 9 | 1221 | នាយកគ្រប់គ្រងការលក់ និងទីផ្សារ | 3.19 | 2.00 | $ 1,637 | |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

## ២.៤.៤ អប់រំ

តារាងទី ២០ បានបង្ហាញពីវឌ្ឍនភាពជាវិជ្ជមាននៃអនុវិស័យអប់រំ នៅក្នុងឆមាសទី២ ឆ្នាំ២០២៤ និងឆមាសទី១ នៃឆ្នាំ២០២៥ ក្នុងនោះកំណើននៃសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS មានការកើនឡើងពីចំនួន ៨០៤ ទៅ ៨៦៦។ ភាគរយនៃសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ មានការកើនឡើងពី ៧៦,៤៩% ទៅ ៧៨,១៨% ហើយចំណែកនៃទំហំសហគ្រាស គ្រឹះស្ថាននៅតែមានស្ថិរភាពដោយមានភាពប្រែប្រួលតិចតួចបំផុតតាមប្រភេទទំហំនៃសហគ្រាស គ្រឹះស្ថាន។ ដោយឡែក ភាគរយនៃសហគ្រាស គ្រឹះស្ថានភាគច្រើនប្រមាណជា ៩០% ជាសហគ្រាស គ្រឹះស្ថានមីក្រូ តូច និងមធ្យម ដែលមានកម្មករ និយោជិតក្រោម ១០០នាក់។ ភាគរយនៃសហគ្រាស គ្រឹះស្ថានដែលបានផ្តល់ឱកាសការងារដល់អ្នកស្វែងរកការងារលើកដំបូងមានក៏មានការធ្លាក់ចុះប្រមាណ ៤៩% ដែលបណ្តាលមកពីសហគ្រាស គ្រឹះស្ថានជួបប្រទះបញ្ហាគម្លាតជំនាញ ដែលមានការកើនឡើងគួរឱ្យកត់សម្គាល់ពី ១៧,១៣% រហូតដល់ ៣៣,២២% រៀងគ្នា បណ្តាលឱ្យគ្រឹះស្ថាន សហគ្រាសក្នុងអនុវិស័យនេះប្តូរនិន្នាការក្នុងការជ្រើសរើសបុគ្គលិកដែលមានជំនាញ និងបទពិសោធន៍ការងារវិញ។

យ៉ាងណាមិញ ទោះបីជាសន្ទស្សន៍ឱកាសការងារសម្រាប់កម្មករនិយោជិតមានការកើនឡើងក៏ដោយ ក៏ចំនួនប្រកាសជ្រើសរើសកម្មករនិយោជិតដែលរំពឹងទុក ត្រូវបានធ្លាក់ចុះពីចំនួន ២ ២៧៦នាក់ មកត្រឹម ១ ៦៩០នាក់។ ទន្ទឹមនឹងនេះ និយោជកនៅតែជួបបញ្ហាប្រឈមចម្បងក្នុងការជ្រើសរើសបុគ្គលិក ដោយសារកង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ, បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច, លក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែងនេះ (ឧ. ប្រាក់ខែតិច) និងបទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការជាដើម។

តារាងទី ២០៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យអប់រំ

| អប់រំ | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 804 | 866 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 76.49% | 78.18% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 9.83% | 9.70% |
| | 5-19 | 50.00% | 50.58% |
| | 20-99 | 30.97% | 30.72% |
| | 100-199 | 6.72% | 6.81% |
| | 200-499 | 2.11% | 2.08% |
| | 500+ | 0.37% | 0.12% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 17.13% | 33.22% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 91.20% | 42.95% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 61.27% | 77.50% |

| | | |
|---|---|---|
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | 13.47% | 24.29% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | 6.73% | 13.75% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | 2.89 | 2.92 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | 2,276 | 1,690 |
| ១. ការដោះស្រាយបញ្ហា | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | | |
| ៣. ការគ្រប់គ្រងអតិថិជន | | |
| ៤. ការសម្របសម្រួល | | |
| ៥. ការគ្រប់គ្រងពេលវេលា | | |
| ១. ភាសាអង់គ្លេស | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការគ្រប់គ្រងធនធានមនុស្ស | | |
| ៣. ជំនាញទីផ្សារឌីជីថល | | |
| ៤. ជំនាញរដ្ឋបាលការិយាល័យ | | |
| ៥. ការវិភាគការគ្រប់គ្រងគុណភាព | | |
| ១. កង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក | |
| ២. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | | |
| ៣. មិនសូវមានមនុស្សចាប់អារម្មណ៍នឹងការងារប្រភេទនេះ | | |
| ៤. លក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែងនេះ (ឧ. ប្រាក់ខែតិច) | | |
| ៥. បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ | | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្លេក), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

ទិដ្ឋភាពការងារសម្រាប់មុខរបរដែលបានបង្ហាញនៅក្នុងតារាងទី ២១ មានការផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់រវាងសន្ទស្សន៍ឱកាសការងារ និងភាពប្រែប្រួលតាមតួនាទីផ្សេងៗគ្នា។ កត្តាដែលជំរុញឱ្យមានការផ្លាស់ប្ដូរនោះអាចបណ្ដាលមកពីកត្តាមួយចំនួនដូចជា កត្តាប្រាក់ខែ ឬកម្រិតប្រាក់ខែ និងអត្ថប្រយោជន៍ផ្សេងៗរបស់មុខរបរនីមួយៗ។ ក្នុងនោះមុខរបរដែលមានឱកាសការងារខ្ពស់សម្រាប់ឆមាសទី១ ឆ្នាំ២០២៥ មានដូចជា គ្រូបង្រៀនភាសាផ្សេងទៀត, បុគ្គលិកទូទៅផ្នែកកត់ត្រាគណនេយ្យ និងបញ្ជី, អ្នកទទួលភ្ញៀវ (ទូទៅ), និងបុគ្គលិកការិយាល័យទូទៅ។ មុខរបររួមមាន គ្រូបង្រៀនអប់រំវិជ្ជាជីវៈ និងអ្នកអប់រំកុមារតូចៗមានឱកាសការងារ និងតម្រូវការធម្មតា ហើយមុខរបរដែលមានឱកាសការងារទាបនៅក្នុងឆមាសទី១ ឆ្នាំ២០២៥ រួមមានជំនួយការគ្រូបង្រៀន, គ្រូបង្រៀននៅថ្នាក់មធ្យមសិក្សា, អ្នកការពារសន្តិសុខ, និងគ្រូបង្រៀននៅថ្នាក់បឋមសិក្សា។ ប្រាក់បៀវត្សរ៍ខ្ពស់បំផុតជាមធ្យមសម្រាប់មុខរបរក្នុងអនុវិស័យនេះប្រចាំខែចំនួនប្រមាណ ៤៥៤ ដុល្លារអាមេរិក។ ការកើនឡើងនៃឱកាសការងារអាចត្រូវបានជំរុញតាមរយៈការបង្កើតឡើងនូវគ្រឹះស្ថានអប់រំ និងបណ្ដុះបណ្ដាលថ្មីៗក្នុងប្រទេស។

តារាងទី ២១៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យអប់រំ

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 2353 | គ្រូបង្រៀនភាសាផ្សេងទៀត | 2.83 | 3.80 | $ 454 | $ 31 |
| 2 | 4311 | បុគ្គលិកទូទៅផ្នែកកត់ត្រាគណនេយ្យ និងបញ្ជី | 3.22 | 3.56 | $ 345 | $ 40 |
| 3 | 4226 | អ្នកទទួលភ្ញៀវ (ទូទៅ) | 2.60 | 3.38 | $ 262 | $ 39 |
| 4 | 4110 | បុគ្គលិកការិយាល័យទូទៅ | 2.83 | 3.33 | $ 337 | $ 31 |
| 5 | 2320 | គ្រូបង្រៀនអប់រំវិជ្ជាជីវៈ | 3.43 | 3.00 | $ 269 | $ 16 |
| 6 | 2342 | អ្នកអប់រំកុមារតូចៗ | 2.90 | 2.88 | $ 410 | $ 210 |
| 7 | 5312 | ជំនួយការគ្រូបង្រៀន | 2.00 | 2.60 | $ 352 | $ 129 |
| 8 | 2330 | គ្រូបង្រៀននៅថ្នាក់មធ្យមសិក្សា | 3.22 | 2.46 | $ 442 | $ 64 |
| 9 | 5414 | អ្នកការពារសន្តិសុខ | 3.10 | 2.36 | $ 224 | $ 47 |
| 10 | 2341 | គ្រូបង្រៀននៅថ្នាក់បឋមសិក្សា | 2.99 | 2.31 | $ 317 | $ 27 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៤.៥ ហិរញ្ញវត្ថុ និងធានារ៉ាប់រង

ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS មានការកើនឡើងពី ៤ ១១០ ក្នុងឆមាសទី២ ឆ្នាំ២០២៤ មក ៤ ១៤៥ ក្នុងឆមាសទី១ ឆ្នាំ២០២៥។ កំណើននេះត្រូវបានជំរុញដោយការកើនឡើងនូវទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ការកើនឡើងនៃតម្រូវការសេវាហិរញ្ញវត្ថុ កំណើនសហគ្រាស គ្រឹះស្ថានខ្នាតតូច និងវិស័យធានារ៉ាប់រងដែលកំពុងរីកចម្រើន។ តារាងទី២២ បង្ហាញពីកំណើននៃសហគ្រាស គ្រឹះស្ថានខ្នាតតូច ដែលមានបុគ្គលិកចំនួន ៥-១៩នាក់ រហូតដល់ ៤៤,៧៣% (ពីអត្រា៤១,២២% ក្នុងឆមាសទី២ ឆ្នាំ២០២៤)។ ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារលើកដំបូងមានការធ្លាក់ចុះយ៉ាងខ្លាំងពី ៧៨,៤៧% ក្នុងឆមាសទី២ ឆ្នាំ២០២៤ មកប្រមាណ ១៣,០% ក្នុងឆមាសទី១ ឆ្នាំ២០២៥ ប៉ុន្តែការណ៍នេះអាចមកពីបម្រែបម្រួលតាមរដូវកាលប៉ុណ្ណោះ។ បន្ថែមលើនេះ ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាកង្វះជំនាញបានធ្លាក់ចុះពី ៩,៤០% មក ៥,១៧% ក្នុងរយៈពេលដូចគ្នា។ បញ្ហាប្រឈមដែលសហគ្រាស គ្រឹះស្ថានជួបបញ្ហាកង្វះជំនាញ និងមានការលំបាកក្នុងការជ្រើសរើសបុគ្គលិក ដោយបញ្ហាគម្លាតជំនាញមាននិន្នាការប្រសើរឡើងតិចតួចប៉ុណ្ណោះ ពី ២៤,៦៤% មក ២៥,៨១%។ អនុវិស័យនេះក៏ត្រូវប្រឈមមុខ

នឹងបញ្ហាផ្សេងទៀតដូចជា បេក្ខជនមិនសូវមានមនុស្សចាប់អារម្មណ៍នឹងការងារប្រភេទនេះ, បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច, ការប្រកួតប្រជែងខ្លាំងពីនិយោជកផ្សេងទៀត, កង្វះបេក្ខជនដែលមានអាកប្បកិរិយាភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ, និងលក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែងនេះ (ឧ. ប្រាក់ខែតិច)។ យ៉ាងណាក្តី សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករនិយោជិតមានការកើនឡើងពី ២,៨២ ទៅ ២,៩៥ ខណៈពេលដែលចំនួនប្រកាសជ្រើសរើសកម្មករនិយោជិតក៏មានការកើនឡើងយ៉ាងខ្លាំងដែរពី ១ ៦២៨កន្លែង ដល់ ៥ ៨៣៦ កន្លែង នេះជាសញ្ញាបង្ហាញថាទីផ្សារការងារក្នុងអនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រងនឹងមានកំណើនវិជ្ជមាន។

តារាងទី ២២៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង

| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 4,110 | 4,145 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 95.26% | 95.25% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 18.88% | 17.52% |
| | 5-19 | 41.22% | 44.73% |
| | 20-99 | 37.88% | 35.75% |
| | 100-199 | 1.00% | 0.99% |
| | 200-499 | 0.66% | 0.68% |
| | 500+ | 0.36% | 0.34% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 24.64% | 25.81% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 78.47% | 12.91% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 55.46% | 78.00% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 21.93% | 17.31% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 9.40% | 5.17% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 2.82 | 2.95 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 1,626 | 5,836 |
| ១. ការដោះស្រាយបញ្ហា | | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការគ្រប់គ្រងអតិថិជន | | | |
| ៣. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | | | |
| ៤. ការសម្របសម្រួល | | | |
| ៥. ការគ្រប់គ្រងពេលវេលា | | | |
| ១. ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ | | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការគ្រប់គ្រងធនធានមនុស្ស | | | |
| ៣. ការវិភាគការគ្រប់គ្រងគុណភាព | | | |
| ៤. ការត្រួតពិនិត្យប្រតិបត្តិការ | | | |

| | |
|---|---|
| ៥. ភាសាអង់គ្លេស | |
| ១. មិនសូវមានមនុស្សចាប់អារម្មណ៍នឹងការងារប្រភេទនេះ | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក |
| ២. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | |
| ៣. ការប្រកួតប្រជែងខ្លាំងពីនិយោជកផ្សេងទៀត | |
| ៤. កង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ | |
| ៥. លក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែងនេះ (ឧ. ប្រាក់ខែតិច) | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្ដើង), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

ទិដ្ឋភាពការងារសម្រាប់អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រងសម្រាប់ឆមាសទី១ ឆ្នាំ២០២៥ បានបង្ហាញពីឱកាសការងារល្អសម្រាប់អ្នកលក់ ឬអ្នកទីផ្សារតាមទូរស័ព្ទ ដែលក្នុងនោះយើងក៏សង្កេតឃើញថាប្រភេទមុខរបរនេះក៏បានប្រែប្រួលពីតម្រូវការមធ្យមក្នុងឆមាសទី២ ឆ្នាំ២០២៤ មកជាតម្រូវការខ្ពស់ក្នុងឆមាសទី១ ឆ្នាំ២០២៥។ ការងារជាមន្ត្រីឥណទាន និងប្រាក់កម្ចី ក៏បានរួចផុតពីបន្ទាត់តម្រូវការមធ្យមមកជាការងារដែលមានតម្រូវការខ្ពស់ផងដែរ។ រីឯមុខរបរមួយចំនួនទៀតដូចជាបុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម, អ្នកទទួលភ្ញៀវ (ទូទៅ), គណនេយ្យករ (កម្រិតខ្ពស់)ឬសវនករ, និងវិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ គឺមានឱកាសការងារទាបនៅឆមាសទី១ ឆ្នាំ២០២៥។

ដោយឡែក ប្រាក់បៀវត្សរ៍ក្នុងអនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រងមានភាពខុសគ្នាទៅតាមតួនាទី និងជំនាញ ដោយនាយកគ្រប់គ្រងហិរញ្ញវត្ថុមានប្រាក់បៀវត្សរ៍ខ្ពស់ជាងមុខរបរផ្សេងៗទៀតក្នុងអនុវិស័យនេះ។ ក្នុងនោះប្រាក់ចំណូលខ្ពស់បំផុតជាមធ្យមដែលទទួលបានគឺ ១ ៧៤៦ដុល្លារអាម៉េរិក និងមានអត្ថប្រយោជន៍ផ្សេងទៀតចំនួន ២០៩ដុល្លារអាម៉េរិក សម្រាប់តួនាទីនាយកគ្រប់គ្រងហិរញ្ញវត្ថុ តាមដោយមុខរបរដែលមានប្រាក់ចំណូលខ្ពស់បន្ទាប់គឺគណនេយ្យករ (កម្រិតខ្ពស់) ឬសវនករ ដែលអាចរកប្រាក់ចំណូលប្រចាំខែបានចំនួន ១ ៣៣៩ដុល្លារអាម៉េរិក និងប្រាក់អត្ថប្រយោជន៍ផ្សេងៗចំនួន ១៨១ដុល្លារអាម៉េរិក។

សរុបមក និន្នាការការងារនៅក្នុងអនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រងរបស់កម្ពុជាសម្រាប់ឆមាសទី១ ឆ្នាំ ២០២៥ ត្រូវបានជំរុញដោយការពង្រីកសេដ្ឋកិច្ច ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) និងការកើនឡើងនូវតម្រូវការសេវាកម្មហិរញ្ញវត្ថុ។ ការប្រែប្រួលនៃប្រាក់បៀវត្សរ៍ឆ្លុះបញ្ចាំងពីភាពខុសគ្នានៃកម្រិតជំនាញ ភាពប្រកួតប្រជែងក្នុងឧស្សាហកម្ម និងតម្រូវការដែលកំពុងកើនឡើងសម្រាប់អ្នកជំនាញផ្នែកហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់កំណើនអាជីវកម្ម និងការពង្រីកទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា។

តារាងទី ២៣៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 5244 | អ្នកលក់ ឬអ្នកទីផ្សារតាមទូរស័ព្ទ | 2.83 | 4.00 | $ 329 | $ 80 |
| 2 | 3312 | មន្ត្រីឥណទាន និងប្រាក់កម្ចី | 3.02 | 3.21 | $ 411 | $ 121 |
| 3 | 3343 | លេខាធិការផ្នែករដ្ឋបាល និងប្រតិបត្តិ | 2.96 | 3.00 | $ 522 | $ 69 |
| 4 | 4229 | អ្នកធ្វើការផ្នែកផ្តល់ព័ត៌មានដល់អតិថិជន | 2.00 | 3.00 | $ 453 | $ 192 |
| 5 | 1211 | នាយកគ្រប់គ្រងហិរញ្ញវត្ថុ | 3.15 | 3.00 | $ 1,746 | $ 209 |
| 6 | 3313 | ជំនួយការគណនេយ្យករ | 3.08 | 2.87 | $ 546 | $ 100 |
| 7 | 2431 | វិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ | 3.08 | 2.67 | $ 465 | $ 116 |
| 8 | 2411 | គណនេយ្យករ (កម្រិតខ្ពស់) ឬសវនករ | 3.39 | 2.60 | $ 1,339 | $ 181 |
| 9 | 4226 | អ្នកទទួលភ្ញៀវ (ទូទៅ) | 2.60 | 2.00 | $ 291 | $ 54 |
| 10 | 3323 | បុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម | 3.25 | 2.00 | $ 411 | $ 33 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៤.៦ សេវាថែទាំសុខភាព

អនុវិស័យសេវាថែទាំសុខភាព បានទទួលនិន្នាការប្រែប្រួលក្នុងរយៈពេលពីរឆមាសចុងក្រោយ ដោយយោងតាមចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS បានធ្លាក់ចុះពី ៧០០ ក្នុងឆមាសទី២ ឆ្នាំ២០២៤ មក ៦៨២ ក្នុងឆមាសទី១ ឆ្នាំ២០២៥។ ដោយឡែក សហគ្រាស គ្រឹះស្ថាន ដែលមានបុគ្គលិកពី ៥-១៩ នាក់ មានការកើនឡើងពី ៦៥,១៤% ក្នុងឆមាសទី២ ឆ្នាំ២០២៤ ទៅ ៧០,៩៧% ក្នុងឆមាសទី១ ឆ្នាំ២០២៥ ដែលបង្ហាញអំពីកំណើននៃសេវាសុខាភិបាលឯកជនខ្នាតតូច (ដូចជាមន្ទីរពេទ្យ មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងមន្ទីរសម្ភព) និងតម្រូវការរបស់អ្នកប្រើប្រាស់លើសេវាថែទាំសុខភាព។ សហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញបានកាត់បន្ថយពី ១៨,១៦% មកត្រឹម ១២,៦៩% ដែលនេះអាចបញ្ជាក់បានថា ប្រព័ន្ធអប់រំក្នុងវិស័យសុខាភិបាលមានប្រសិទ្ធភាពក្នុងការកាត់បន្ថយបញ្ហាកង្វះជំនាញធៀបនឹងតម្រូវការទីផ្សារការងារ។ ទន្ទឹមគ្នានេះ ភាគរយចំនួនសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារលើកដំបូង មានអត្រាថយចុះយ៉ាងខ្លាំងពី ៨៥,៦០% មកត្រឹម១២,៦៩% ដែលនេះអាចបង្ហាញអំពីការព្រួយបារម្ភរបស់និយោជកចំពោះបទពិសោធន៍ការងារថ្មីរបស់បេក្ខជន។ ស្ទើមួយភាគបួននៃសហគ្រាសសរុបបានជួបប្រទះការលំបាកក្នុងការជ្រើសរើសបុគ្គលិក និងមានប្រមាណជា ៨% ជាសហគ្រាស គ្រឹះស្ថានដែលជួបនឹងបញ្ហាកង្វះជំនាញក្នុងឆមាសទី១ ឆ្នាំ២០២៥។

សម្រាប់ឆមាសទី១ ឆ្នាំ២០២៥ តម្លៃសន្ទស្សន៍ឱកាសការងារសម្រាប់កម្មករនិយោជិតមានការកើនឡើងពី ៣,០៣ ទៅ ៣,២១ ប៉ុន្តែចំនួនប្រកាសជ្រើសរើសកម្មករនិយោជិតរំពឹងទុកត្រូវបានធ្លាក់ចុះពី ៥១២កន្លែង មកត្រឹម ២០១កន្លែង។ កត្តាប្រឈមក្នុងការជ្រើសបុគ្គលិកដែលបានរាយការណ៍ពីនិយោជករួមមាន ការងារដែលតម្រូវឱ្យមានវេនយប់ ឬម៉ោងធ្វើការមិនសមស្រប, កង្វះបេក្ខជនដែលមានអាកប្បកិរិយា និងភាពអត់ធ្មត់, កង្វះខាតបេក្ខជនជាទូទៅ, កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧ. សញ្ញាបត្រ), និងកង្វះបេក្ខជនដែលមានបទពិសោធន៍ការងារមិនគ្រប់គ្រាន់តាមតម្រូវការ។

តារាងទី ២៤៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យសេវាថែទាំសុខភាព

| សេវាថែទាំសុខភាព | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 700 | 682 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 83.43% | 82.70% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 26.29% | 19.79% |
| | 5-19 | 65.14% | 70.97% |
| | 20-99 | 6.86% | 7.92% |
| | 100-199 | 0.71% | 0.59% |
| | 200-499 | 1.00% | 0.59% |
| | 500+ | 0.00% | 0.15% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 18.16% | 12.69% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 85.60% | 12.69% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 43.90% | 41.20% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 24.57% | 24.44% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 5.39% | 8.04% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 3.03 | 3.21 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 512 | 201 |
| ១. ការដោះស្រាយបញ្ហា | | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការសម្របសម្រួល | | | |
| ៣. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | | | |
| ៤. ការគ្រប់គ្រងអតិថិជន | | | |
| ៥. ការគ្រប់គ្រងពេលវេលា | | | |
| ១. ការវិភាគការគ្រប់គ្រងគុណភាព | | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ | | | |
| ៣. មូលដ្ឋានគ្រឹះកុំព្យូទ័រ | | | |
| ៤. ការគ្រប់គ្រងធនធានមនុស្ស | | | |

| | |
|---|---|
| ៥. ជំនាញរដ្ឋបាលការិយាល័យ | |
| ១. ការងារតម្រូវឱ្យមានការប្តូរវេនយប់ ឬម៉ោងធ្វើការមិនសមស្រប | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក |
| ២. កង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ | |
| ៣. កង្វះខាតបេក្ខជនជាទូទៅ | |
| ៤. កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧ. សញ្ញាបត្រ) | |
| ៥. បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្តើង), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

តារាងទី២៥ បង្ហាញពីការផ្លាស់ប្តូរសន្ទស្សន៍ការងារ និងប្រាក់ខែសម្រាប់មុខរបរផ្សេងៗក្នុងវិស័យសេវាថែទាំសុខភាព ដែលការផ្លាស់ប្តូរនេះអាចបណ្តាលមកពីបម្រែបម្រួលតម្រូវការការងារ ការប្រកួតប្រជែងក្នុងវិស័យ និងការឆ្លើយតបទៅនឹងលក្ខខណ្ឌសេដ្ឋកិច្ចនានា។ ការវិភាគទីផ្សារការងារសម្រាប់អ្នកជំនាញក្នុងវិស័យសេវាថែទាំសុខភាពក្នុងឆមាសទី១ ឆ្នាំ២០២៥ បង្ហាញពីតម្រូវការ និងផ្តល់ឱកាសការងារខ្ពស់សម្រាប់មុខតំណែងដូចជា ជំនួយការពេទ្យ នាយកគ្រប់គ្រងសេវាសុខភាព និងវិជ្ជាជីវៈខាងគិលានុប្បដ្ឋាយិកា។ ចំណែកឱកាសការងារសម្រាប់មុខរបរវិជ្ជាជីវៈខាងធ្មប និងអ្នកទទួលភ្ញៀវ (ទូទៅ) មានទាបជាងគេ ដែលបង្ហាញពីការប្រកួតប្រជែងខ្លាំងសម្រាប់មុខតំណែងនេះ។

ប្រភេទមុខរបរសំខាន់ៗដូចជា នាយកគ្រប់គ្រងសេវាសុខភាព ទទួលបានប្រាក់បៀវត្សរ៍ខ្ពស់បំផុតប្រចាំខែជាមធ្យមចំនួន ២ ៦៧៥ដុល្លារអាម៉េរិក។ ប្រាក់បៀវត្សរ៍សម្រាប់មុខរបរនៅក្នុងអនុវិស័យនេះក៏មានភាពខុសគ្នាទៅតាមតួនាទីនីមួយៗ ដូចជាវេជ្ជបណ្ឌិតជំនាញឯកទេសអាចរកចំណូលបានច្រើនជាងវេជ្ជបណ្ឌិតឯកទេសទូទៅច្រើនជាង ២ដង។ អ្នកដែលមានជំនាញឯកទេស ដូចជាវិជ្ជាជីវៈខាងគិលានុប្បដ្ឋាយិកា វិជ្ជាជីវៈខាងធ្មប អ្នកទទួលភ្ញៀវ (ទូទៅ) និងជំនួយការពេទ្យ ក៏មានលទ្ធភាពទទួលបានប្រាក់បៀវត្សរ៍ខ្ពស់ ដោយឆ្លុះបញ្ចាំងពីជំនាញ និងតម្រូវការសម្រាប់អនុវិស័យនេះ។

តារាងទី ២៥៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យសេវាថែទាំសុខភាព

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 3256 | ជំនួយការពេទ្យ | 4.44 | 3.80 | $ 357 | $ 59 |
| 2 | 1342 | នាយកគ្រប់គ្រងសេវាសុខភាព | 4.86 | 3.40 | $ 2,675 | $ 175 |
| 3 | 2221 | វិជ្ជាជីវៈខាងគិលានុប្បដ្ឋាយិកា | 3.34 | 3.30 | $ 500 | $ 75 |
| 4 | 2212 | វេជ្ជបណ្ឌិតជំនាញឯកទេស | 3.38 | 3.00 | $ 1,173 | $ 134 |
| 5 | 2211 | វេជ្ជបណ្ឌិតឯកទេសទូទៅ | 3.91 | 2.83 | $ 885 | $ 168 |
| 6 | 4226 | អ្នកទទួលភ្ញៀវ (ទូទៅ) | 2.60 | 2.75 | $ 463 | $ 107 |

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ ផ្សេងៗ |
|---|---|---|---|---|---|---|
| 7 | 2222 | វិជ្ជាជីវៈខាងឆ្មប | 3.31 | 2.17 | $ 470 | $ 88 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៤.៧ វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប

អនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប បានរួមចំណែក ៥១,៥% ក្នុងការនាំចេញសរុបរបស់កម្ពុជា ដែលសមាមាត្រទៅនឹងទំហំការនាំចេញជាទឹកប្រាក់សរុប ១៣ ៧៤២ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៤។ អនុវិស័យនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាការរួមចំណែកយ៉ាងធំក្នុងការបង្កើតការងារជូនប្រជាជន។ ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងអនុវិស័យនេះមានការធ្លាក់ចុះតិចតួចពីប្រមាណ ១ ៦៤៣ ក្នុងឆមាសទី២ ឆ្នាំ២០២៤ មកត្រឹម ១ ៥៦៦ ក្នុងឆមាសទី១ ឆ្នាំ២០២៥ និងចំនួនសហគ្រាស គ្រឹះស្ថានដែលមានម្ចាស់ភាគហ៊ុនជាជនជាតិខ្មែរមានប្រមាណ ១៥,៧៧% ដែលនេះបង្ហាញពីការពឹងផ្អែកខ្លាំងលើការវិនិយោគពីបរទេស។ ដោយឡែក ទំហំនៃសហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះមានភាពចម្រុះ ដោយភាគច្រើនជាសហគ្រាស គ្រឹះស្ថានខ្នាតមធ្យម និងធំដែលមានកម្មករ និយោជិតចន្លោះពី ២០ ទៅ ៩៩ (២៤,២៧%) ចន្លោះពី ២០០ ទៅ ៤៩៩ (២២,២២%) និង ៣២,៣៨% ជាសហគ្រាសដែលមានចំនួនកម្មករ និយោជិតរហូតដល់ ៥០០នាក់ឡើងទៅ។ លើសពីនេះ កំណើននៃចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតត្រូវបានរំពឹងទុកថាមានចំនួនច្រើនជាងឆមាសមុនរហូតដល់ប្រមាណជាង ២ម៉ឺនកន្លែង ពី ៣៣ ៧០៨កន្លែង រហូតដល់ ៥៣ ២៩១កន្លែង ជាមួយនឹងសន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត ៣,២៦។ ដោយឡែក ជិតពាក់កណ្តាលនៃសហគ្រាស គ្រឹះស្ថានបានរាយការណ៍ពីភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម ដែលមានប្រមាណ ៤២,២% នៃសហគ្រាស គ្រឹះស្ថានសរុប ដែលបណ្តាលមកពីបញ្ហាប្រឈមផ្សេងៗរួមមាន បទពិសោធន៍ការងាររបស់បេក្ខជនមិនគ្រប់គ្រាន់ទៅតាមតម្រូវការ បញ្ហាគម្លាតជំនាញ នឹងបញ្ហាកង្វះជំនាញជាដើម។ ទោះបីបញ្ហាប្រឈមទាំងនេះមិនទាន់បានដោះស្រាយទាំងស្រុង ប៉ុន្តែក្នុងឆមាសទី១ ឆ្នាំ២០២៥ ហាក់មានភាពប្រសើរឡើងនៃជំនាញរបស់កម្មករ និយោជិត ដោយបញ្ហាគម្លាតជំនាញបានធ្លាក់មកនៅត្រឹម ១៤,២០% ធៀបនឹងឆមាសទី២ ឆ្នាំ២០២៤ (៤៥,៥៦%) និងបញ្ហាកង្វះជំនាញមកត្រឹម ១៣,២៧%។

តារាងទី ២៦៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង ផលិតផលិតផលធ្វើដំណើរនិងកាបូប

| វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 1,643 | 1,566 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 18.08% | 15.77% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 1.64% | 0.32% |
| | 5-19 | 7.79% | 6.51% |
| | 20-99 | 23.13% | 24.27% |
| | 100-199 | 13.09% | 14.30% |
| | 200-499 | 20.57% | 22.22% |
| | 500+ | 33.78% | 32.38% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 45.56% | 14.20% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 45.26% | 16.18% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 80.45% | 67.18% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 41.97% | 42.20% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 15.45% | 13.27% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 3.29 | 3.26 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 33,708 | 53,291 |
| ១. ការដោះស្រាយបញ្ហា | | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការត្រួតពិនិត្យ | | | |
| ៣. ការសម្របសម្រួល | | | |
| ៤. ការគ្រប់គ្រងពេលវេលា | | | |
| ៥. ការគ្រប់គ្រងអតិថិជន | | | |
| ១. ការគ្រប់គ្រងធនធានមនុស្ស | | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ភាសាចិន | | | |
| ៣. ការវិភាគការគ្រប់គ្រងគុណភាព | | | |
| ៤. ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ | | | |
| ៥. ការត្រួតពិនិត្យប្រតិបត្តិការ | | | |
| ១. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក | |
| ២. ការប្រកួតប្រជែងខ្លាំងពីនិយោជកផ្សេងទៀត | | | |
| ៣. បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ | | | |
| ៤. កង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ | | | |
| ៥. លក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែងនេះ (ឧ. ប្រាក់ខែតិច) | | | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្ដើង), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

តារាងទី ២៧ បង្ហាញពីសន្ទស្សន៍ឱកាសការងារ និងប្រាក់ឈ្នួលតាមមុខរបរសម្រាប់អនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប។ សម្រាប់ឆមាសទី១ ឆ្នាំ២០២៥ តួនាទីដែលមានឱកាសការងារខ្ពស់គឺ អ្នកផលិតស្បែកជើង និងអ្នកធ្វើការដែលពាក់ព័ន្ធ, និងអ្នកបញ្ជាម៉ាស៊ីនផលិតស្បែកជើង និងម៉ាស៊ីនដែលពាក់ព័ន្ធ ដែលមានតម្លៃសន្ទស្សន៍ហូតដល់ ៤,០ ដូចគ្នា។ គួរឱ្យចាប់អារម្មណ៍ផងដែរ គឺការប្រែប្រួលសន្ទស្សន៍នៃមុខរបរជាអ្នកបញ្ជាម៉ាស៊ីនវេចខ្ចប់ ប្រកដាក់ដប និងដាក់ផ្លាកសញ្ញាពីឱកាសការងារទាបក្នុងឆមាសទី២ ឆ្នាំ២០២៤ មកជាមានឱកាសការងារខ្ពស់ក្នុងឆមាសទី១ ឆ្នាំ២០២៥។

ដោយឡែកប្រាក់ឈ្នួលក្នុងអនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូប ខុសគ្នាទៅតាមតួនាទី និងមុខជំនាញ ដោយបុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម និងបុគ្គលិកផ្នែកកត់ត្រាខាងស្តុកទំនិញ ទទួលបានប្រាក់ឈ្នួលច្រើនជាងគេ និងទាមទារចំណេះដឹងបច្ចេកទេសច្រើនជាង បើធៀបនឹងតួនាទីផ្សេងៗក្នុងវិស័យដដែលនេះ។ សម្រាប់អនុវិស័យនេះ ជំនាញរឹងមួយចំនួនដែលត្រូវបានសង្កេតឃើញថាមានតម្រូវការខ្ពស់ គឺការគ្រប់គ្រងធនធានមនុស្ស ការវិភាគការគ្រប់គ្រងគុណភាព ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ ការត្រួតពិនិត្យប្រតិបត្តិការ និងភាសាចិនជាដើម ដោយសារម្ចាស់ភាគហ៊ុន និងអ្នកកាន់តំណែងខ្ពស់ៗភាគច្រើនជាជនបរទេស ឬជនជាតិចិន ទើបតម្រូវឱ្យបេក្ខជនដែលចាប់អារម្មណ៍ចង់ធ្វើការក្នុងវិស័យនេះមានឱកាសខ្ពស់ក្នុងការទទួលបានការងារ និងប្រាក់ឈ្នួលខ្ពស់ក្នុងករណីមានជំនាញលើភាសាចិនបន្ថែម។

តារាងទី ២៧៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យ GFT

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 7536 | អ្នកផលិតស្បែកជើង និងអ្នកធ្វើការដែលពាក់ព័ន្ធ | 3.52 | 4.00 | $ 225 | $ 29 |
| 2 | 8156 | អ្នកបញ្ជាម៉ាស៊ីនផលិតស្បែកជើង និងម៉ាស៊ីនដែលពាក់ព័ន្ធ | 3.18 | 4.00 | $ 217 | $ 26 |
| 3 | 8183 | អ្នកបញ្ជាម៉ាស៊ីនវេចខ្ចប់ ប្រកដាក់ដប និងដាក់ផ្លាកសញ្ញា | 1.73 | 3.93 | $ 215 | $ 64 |
| 4 | 7532 | អ្នកកាត់សំលៀកបំពាក់ និងអ្នកធ្វើគំរូសំលៀកបំពាក់ដែលពាក់ព័ន្ធ | 3.09 | 3.81 | $ 264 | $ 66 |
| 5 | 8153 | អ្នកបញ្ជាម៉ាស៊ីនដេរ | 2.41 | 3.52 | $ 225 | $ 58 |
| 6 | 7533 | អ្នកធ្វើការខាងដេរ ប៉ាក់ និងពាក់ព័ន្ធផ្សេងទៀត | 2.48 | 3.03 | $ 248 | $ 54 |
| 7 | 4322 | បុគ្គលិកផ្នែកកត់ត្រាខាងផលិតកម្ម | 2.73 | 3.00 | $ 347 | $ 127 |

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 8 | 4323 | បុគ្គលិកផ្នែកកត់ត្រាខាងដឹកជញ្ជូន | 2.45 | 3.00 | $ 363 | $ 53 |
| 9 | 4321 | បុគ្គលិកផ្នែកកត់ត្រាខាងស្តុកទំនិញ | 2.86 | 1.11 | $ 446 | $ 70 |
| 10 | 3323 | បុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម | 3.25 | 1.00 | $ 509 | $ 71 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៤.៨ ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី

អនុវិស័យផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនីត្បិតតែជាអនុវិស័យដែលមានចំនួនការចុះបញ្ជីក្នុងប្រព័ន្ធ LACMS តិចជាងគេក្នុងចំណោមអនុវិស័យទាំងអស់ ប៉ុន្តែកំណើននៃការចុះបញ្ជីអាជីវកម្មក្នុងវិស័យបានកើនឡើងគួរឱ្យកត់សម្គាល់ប្រមាណជាង ៦០% ពីចំនួន១៤៦ ក្នុងឆមាសទី២ ឆ្នាំ២០២៤ មក ២៣៣ ក្នុងឆមាសទី១ ឆ្នាំ២០២៥ ដែលបញ្ជាក់ពីការកើនឡើងពីចំណាប់អារម្មណ៍របស់អ្នកវិនិយោគ។ សម្រាប់ឆមាសទី១ ឆ្នាំ២០២៥ អនុវិស័យនេះបានបង្ហាញពីភាពចម្រុះនៃទំហំសហគ្រាស គ្រឹះស្ថាន ដែល ១៦,៣១% មានចំនួនកម្មករ និយោជិតចន្លោះ ៥ ទៅ ១៩, ២៧,០៤% មានចំនួនកម្មករ និយោជិតចន្លោះ ២០ ទៅ ៩៩ និង ៥០,៦៤% ទៀតមានកម្មករ និយោជិតពី១០០នាក់ ឡើងទៅ។ យ៉ាងណាក្តី ម្ចាស់ភាគហ៊ុនភាគច្រើន ប្រមាណជាង ៧០% ក្នុងអនុវិស័យនេះជាជនជាតិបរទេស ដែលឆ្លុះបញ្ចាំងពីការពឹងផ្អែកលើការវិនិយោគពីបរទេស និងបច្ចេកវិទ្យាពីក្រៅប្រទេស ដើម្បីជំរុញការអភិវឌ្ឍអនុវិស័យនេះ។

អនុវិស័យផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី មានការកើនឡើងយ៉ាងគំហុកនៃឱកាសការងាររហូតដល់ទៅប្រមាណ ១៥០% ត្រឹមតែក្នុងរយៈពេល១ ឆមាស (ពី ២ ៤៥៤កន្លែងក្នុងឆមាសទី២ ឆ្នាំ២០២៤ ទៅ ៦ ១២៨កន្លែង ក្នុងឆមាសទី១ ឆ្នាំ២០២៥) ក្នុងនោះ ៦០,៧៨% នៃនិយោជកបានរាយការណ៍ពីការជ្រើសរើសបុគ្គលិកថ្មីឱ្យចូលបម្រើការក្នុងសហគ្រាស គ្រឹះស្ថានរបស់ពួកគេ។ សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិតក្នុងអនុវិស័យនេះគឺ ៣,០៨ ដែលបង្ហាញពីភាពលំបាករបស់គ្រឹះស្ថាន សហគ្រាស ក្នុងការជ្រើសរើសកម្មករនិយោជិតនិងបណ្តាលមកពីបញ្ហាចម្បងចំនួន៥ រួមមាន ១). បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច ២). បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការសម្រាប់ការងារនេះ ៣). កង្វះបេក្ខជនដែលមានអាកប្បកិរិយា និងភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ ៤). កត្តាប្រាក់ឈ្នួលទាប និងលក្ខខណ្ឌមិនសូវល្អផ្សេងៗសម្រាប់មុខតំណែងនេះ ៥). កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧ. សញ្ញាបត្រ)។ លើសពីនេះ ប្រាក់ឈ្នួលក្នុងវិស័យនេះមានគម្លាតគ្នាទៅតាមបទពិសោធន៍ ចំណេះជំនាញ និងតំណែង។

សហគ្រាស គ្រឹះស្ថានភាគច្រើនមាននិន្នាការទទួលយកអ្នកមានបទពិសោធន៍ការងារស្រាប់ដើម្បីមកធ្វើការក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួន ប៉ុន្តែសម្រាប់អនុវិស័យនេះ ចំនួនសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសការងារដល់អ្នកស្វែងរកការងារដំបូងមាន ៤,៧៦% ប៉ុណ្ណោះ ដែលបណ្តាលឱ្យមានភាពលំបាកសម្រាប់បេក្ខជន ដែលទើបនឹងបញ្ចប់ការសិក្សា ឬទើបស្វែងរកការងារដំបូង។ យ៉ាងណាក្តី សម្រាប់ជំនាញដែលបេក្ខជនត្រូវមានសម្រាប់អនុវិស័យនេះរួមមាន ការវិភាគ ការគ្រប់គ្រងគុណភាព ការគ្រប់គ្រងធនធានមនុស្ស មូលដ្ឋាន គ្រឹះកុំព្យូទ័រ ភាសាបរទេសដូចជាភាសាចិន និងអង់គ្លេសជាដើម។

តារាងទី ២៨៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី

| ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 146 | 233 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 36.99% | 23.18% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 8.90% | 6.01% |
| | 5-19 | 19.18% | 16.31% |
| | 20-99 | 22.60% | 27.04% |
| | 100-199 | 9.59% | 10.30% |
| | 200-499 | 15.07% | 16.31% |
| | 500+ | 24.66% | 24.03% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 13.74% | 23.56% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 68.40% | 4.76% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 69.70% | 60.78% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 22.90% | 11.75% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 13.45% | 7.14% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 2.99 | 3.08 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 2,454 | 6,128 |
| ១. ការដោះស្រាយបញ្ហា | | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការសម្របសម្រួល | | | |
| ៣. ការគ្រប់គ្រងពេលវេលា | | | |
| ៤. ការត្រួតពិនិត្យ | | | |
| ៥. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | | | |
| ១. ការវិភាគការគ្រប់គ្រងគុណភាព | | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ភាសាចិន | | | |
| ៣. ការគ្រប់គ្រងធនធានមនុស្ស | | | |
| ៤. មូលដ្ឋានគ្រឹះកុំព្យូទ័រ | | | |

| | |
|---|---|
| ៥. ភាសាអង់គ្លេស | |
| ១. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក |
| ២. បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ | |
| ៣. កង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ | |
| ៤. លក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែងនេះ (ឧ. ប្រាក់ខែតិច) | |
| ៥. កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧ. សញ្ញាបត្រ) | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្លេក), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

តារាងទី ២៩ បានបង្ហាញឱ្យឃើញថា តំណែងជាអ្នកបច្ចេកទេសដូចជា អ្នកផ្សារភ្ជាប់លោហៈ និងអ្នកផ្លុំភ្លើងផ្តាច់លោហៈ, និងអ្នកបញ្ជាម៉ាស៊ីនវេចខ្ចប់ ប្រកដាក់ដប និងដាក់ផ្លាកសញ្ញា ជាការងារទាមទារជំនាញបច្ចេកទេស និងមានតម្រូវការខ្ពស់សម្រាប់ឆមាសទី១ ឆ្នាំ២០២៥ ហើយក្រុមនេះអាចទទួលបានប្រាក់ឈ្នួលជាមធ្យមប្រមាណ ៣០០ដុល្លារអាម៉េរិកប្រចាំខែ។ ក្រៅពីនេះ ការងារដែលមានតម្រូវការខ្ពស់ផ្សេងទៀតមានដូចជា អ្នកបកប្រែអត្ថបទ អ្នកបកប្រែផ្ទាល់មាត់ និងភាសាវិទូដទៃទៀត, អ្នកមើលការខុសត្រូវការផលិតក្នុងរោងចក្រ, បុគ្គលិកទូទៅផ្នែកកត់ត្រាគណនេយ្យ និងបញ្ជី, ជំនួយការគណនេយ្យករ, និងវិស្វករឧស្សាហកម្ម និងផលិតកម្ម ដែលមុខរបរទាំងនេះអាចទទួលបានប្រាក់ឈ្នួលជាមធ្យមពីចន្លោះ ៤៥០-៦០០ ដុល្លារអាម៉េរិកក្នុងមួយខែ។ យ៉ាងណាមិញ សម្រាប់ឱកាសការងារកម្រិតមធ្យមគឺមានសម្រាប់អ្នកដែលស្វែងរកមុខតំណែងដូចជា អ្នកតម្លើងបរិក្ខារអគ្គីសនី និងអេឡិចត្រូនិច, អ្នកបច្ចេកទេសខាងវិស្វកម្មអេឡិចត្រូនិច, និងនាយកគ្រប់គ្រងការផ្គត់ផ្គង់ ការចែកចាយ និងពាក់ព័ន្ធផ្សេងទៀត។

តារាងទី ២៩៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 2643 | អ្នកបកប្រែអត្ថបទ អ្នកបកប្រែផ្ទាល់មាត់ និងភាសាវិទូដទៃទៀត | 4.50 | 4.50 | $ 500 | - |
| 2 | 3122 | អ្នកមើលការខុសត្រូវការផលិតក្នុងរោងចក្រ | 2.85 | 4.00 | $ 582 | $ 56 |
| 3 | 7212 | អ្នកផ្សារភ្ជាប់លោហៈ និងអ្នកផ្លុំភ្លើងផ្តាច់លោហៈ | - | 4.00 | $ 296 | $ 43 |
| 4 | 4311 | បុគ្គលិកទូទៅផ្នែកកត់ត្រាគណនេយ្យ និងបញ្ជី | 3.22 | 4.00 | $ 449 | $ 59 |
| 5 | 3313 | ជំនួយការគណនេយ្យករ | 3.08 | 4.00 | $ 558 | $ 55 |
| 6 | 2141 | វិស្វករឧស្សាហកម្ម និងផលិតកម្ម | 3.66 | 3.99 | $ 609 | $ 32 |

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ ផ្សេងៗ |
|---|---|---|---|---|---|---|
| 7 | 8183 | អ្នកបញ្ជាម៉ាស៊ីនវេចខ្ចប់ ប្រកដាក់ដប និងដាក់ផ្លាកសញ្ញា | 1.73 | 3.94 | $ 301 | $ 72 |
| 8 | 8212 | អ្នកតម្លើងបរិក្ខារអគ្គិសនី និងអេឡិចត្រូនិច | - | 3.00 | $ 346 | $ 24 |
| 9 | 3114 | អ្នកបច្ចេកទេសខាងវិស្វកម្មអេឡិចត្រូនិច | 4.10 | 3.00 | $ 344 | $ 47 |
| 10 | 1324 | នាយកគ្រប់គ្រងការផ្គត់ផ្គង់ ការចែកចាយ និងពាក់ព័ន្ធផ្សេងទៀត | 2.64 | 3.00 | $ 1,512 | $ 56 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៤.៩ ផលិតអាហារ និងភេសជ្ជៈ

ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងអនុវិស័យនេះ បានកើនឡើងពីចំនួន ៤០៧ នៅឆមាសទី២ ឆ្នាំ២០២៤ ដល់ ៦៦៤ នៅឆមាសទី១ ឆ្នាំ២០២៥នេះ ប៉ុន្តែទំហំសហគ្រាស គ្រឹះស្ថានភាគច្រើនជាទំហំសហគ្រាសខ្នាតតូច ដោយ ៦៥,៦៦% មានកម្មករ និយោជិត ៥-១៩នាក់ និង ១៥,៣៦% មានកម្មករ និយោជិត ១-៤នាក់ រីឯសហគ្រាស គ្រឹះស្ថានមានកម្មករ និយោជិតចាប់ពី ១០០នាក់ ឡើងទៅមានត្រឹមតែ ៨,២៩% តែប៉ុណ្ណោះ។ ការរំពឹងទុកក្នុងការជ្រើសរើសបុគ្គលិកក្នុងអនុវិស័យនេះ មានការថយចុះគួរឱ្យកត់សម្គាល់ពី ៥ ៣២៤កន្លែង ក្នុងឆមាសទី២ ឆ្នាំ២០២៤ មកនៅត្រឹម ១ ១៥១កន្លែង ក្នុងឆមាសទី១ ឆ្នាំ២០២៥ ក្នុងនោះសហគ្រាស គ្រឹះស្ថានប្រមាណ៥៥% មិនបានជ្រើសរើសបុគ្គលិកបន្ថែមឡើយ (តារាងទី៣០)។

សហគ្រាស គ្រឹះស្ថាន ៣៧,៣៦% បានរាយការណ៍ពីស្ថានភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្មក្នុងឆមាសទី២ ឆ្នាំ២០២៥ ដែលកើនឡើង ២៩% ធៀបនឹងឆមាសមុនដែលស្ថិតក្នុងអត្រា ៨.០៧%។ មូលហេតុចម្បងដែលបណ្តាលឱ្យសហគ្រាស គ្រឹះស្ថានជួបប្រទះបញ្ហាពិបាករើសបុគ្គលិករួមមាន ១). បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច ២). លក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែងនេះ (ឧ. ប្រាក់ខែតិច) ៣). បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ ៤). កង្វះខាតបេក្ខជនជាទូទៅ និង ៥). បេក្ខជនមិនសូវមានមនុស្សចាប់អារម្មណ៍នឹងការងារប្រភេទនេះ។ ដោយឡែក បញ្ហាប្រឈមមួយចំនួនសម្រាប់សហគ្រាស គ្រឹះស្ថាន រួមមានបញ្ហាខ្វះបុគ្គលិកដែលមានជំនាញស្របទៅតាមសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស ដោយបញ្ហាគម្លាតជំនាញ (១៨,៥៦%) និងកង្វះជំនាញ (១៥,៩៥%)។

## តារាងទី ៣០៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យផលិតអាហារ និងភេសជ្ជៈ

| ផលិតអាហារ និងភេសជ្ជៈ | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 407 | 664 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 76.41% | 75.75% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 19.16% | 15.36% |
| | 5-19 | 64.13% | 65.66% |
| | 20-99 | 8.11% | 10.69% |
| | 100-199 | 3.93% | 4.07% |
| | 200-499 | 2.70% | 2.41% |
| | 500+ | 1.97% | 1.81% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 54.17% | 18.56% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 89.97% | 33.20% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 43.26% | 45.65% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 8.07% | 37.36% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 10.48% | 15.95% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 2.91 | 3.29 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 5,324 | 1,151 |
| ១. ការគ្រប់គ្រងអតិថិជន | | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការដោះស្រាយបញ្ហា | | | |
| ៣. ការត្រួតពិនិត្យ | | | |
| ៤. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | | | |
| ៥. ការគ្រប់គ្រងពេលវេលា | | | |
| ១. ការវិភាគការគ្រប់គ្រងគុណភាព | | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ | | | |
| ៣. ការត្រួតពិនិត្យប្រតិបត្តិការ | | | |
| ៤. ការគ្រប់គ្រងធនធានមនុស្ស | | | |
| ៥. ភាសាអង់គ្លេស | | | |
| ១. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក | |
| ២. លក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែងនេះ (ឧ. ប្រាក់ខែតិច) | | | |
| ៣. បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ | | | |
| ៤. កង្វះខាតបេក្ខជនជាទូទៅ | | | |
| ៥. មិនសូវមាននមនុស្សចាប់អារម្មណ៍នឹងការងារប្រភេទនេះ | | | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្ទើង), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

ក្នុងធមាសទី១ ឆ្នាំ២០២៥ សន្ទស្សន៍ឱកាសការងារថ្មីត្បិតតែមិនទាន់ខ្ពស់ខ្លាំង ប៉ុន្តែមានការកើនឡើងសម្រាប់គ្រប់មុខតំណែង ធៀបទៅធមាសទី២ ឆ្នាំ២០២៤។ តំណែងដែលសង្កេតឃើញថាមានសន្ទស្សន៍ខ្ពស់ជាងគេរួមមាន អ្នកតំណាងលក់ផ្នែកពាណិជ្ជកម្ម (៣,៩៤), អ្នកបើកបររថយន្តតូច រថយន្តឈ្នួល និងរថយន្តវែន (៣,៨៨), និងអ្នកបច្ចេកទេសត្រួតពិនិត្យដំណើរការផលិត (៣,៧៥)។ មុខរបរថ្មីមួយចំនួនក៏មានតម្រូវការផងដែរ ដូចជា វិស្វករឧស្សាហកម្ម និងអ្នកត្រួតពិនិត្យដំណើរការផលិត ដែលបង្ហាញពីការកើនឡើងនៃតម្រូវការសំខាន់ៗក្នុងវិស័យ បច្ចេកវិទ្យា និងផលិតកម្ម។ យ៉ាងណាមិញ ការប្រកួតប្រជែងខ្លាំងក្នុងវិស័យការងារនាំឱ្យមានការផ្លាស់ប្តូរប្រភេទការងារខ្លះ។ ប្រភេទមុខរបរជា អ្នកដុតនំ អ្នកធ្វើនំម្សៅ និងដំណាប់ និងអ្នកជំនាញបច្ចេកទេសផ្សេងទៀត ទទួលបានប្រាក់ខែចន្លោះពី ២០០ ដល់ ៤០០ដុល្លារអាម៉េរិកក្នុងមួយខែ។

តារាងទី ៣១៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យផលិតអាហារ និងភេសជ្ជៈ

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ធមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ធមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 3322 | អ្នកតំណាងលក់ផ្នែកពាណិជ្ជកម្ម | 3.30 | 3.94 | $ 406 | $ 70 |
| 2 | 8322 | អ្នកបើកបររថយន្តតូច រថយន្តឈ្នួល និងរថយន្តវែន | 3.03 | 3.88 | $ 294 | $ 127 |
| 3 | 3139 | អ្នកបច្ចេកទេសត្រួតពិនិត្យដំណើរការផលិត | - | 3.75 | $ 546 | $ 101 |
| 4 | 1221 | នាយកគ្រប់គ្រងការលក់ និងទីផ្សារ | 3.19 | 3.67 | $ 1,409 | $ 87 |
| 5 | 7512 | អ្នកដុតនំ អ្នកធ្វើនំម្សៅ និងដំណាប់ | - | 3.57 | $ 203 | $ 65 |
| 6 | 2141 | វិស្វករឧស្សាហកម្ម និងផលិតកម្ម | - | 3.50 | $ 531 | $ 50 |
| 7 | 3323 | បុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម | 3.25 | 3.30 | $ 377 | $ 106 |
| 8 | 2431 | វិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ | 3.08 | 3.00 | $ 635 | $ 100 |
| 9 | 4321 | បុគ្គលិកផ្នែកកត់ត្រាខាងស្តុកទំនិញ | 2.86 | 3.00 | $ 392 | $ 29 |
| 10 | 7412 | យន្តការី និងអ្នកតម្លើងអគ្គីសនី | - | 3.00 | $ 441 | $ 43 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

## ២.៤.១០ ផលិតកៅស៊ូ និងប្លាស្ទិក

ចំនួនសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS នៃអនុវិស័យផលិតកៅស៊ូ និងប្លាស្ទិកមានការកើនឡើង ដែលបង្ហាញពីការរីកចម្រើននៃវិស័យកសិ-ឧស្សាហកម្មកម្ពុជា។ បែងចែកតាមទំហំសហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះ ដែលមានកម្មករ និយោជិតចន្លោះ ៥-១៩នាក់ មានប្រមាណ ៣៧,៩៨%, ២០-៩៩នាក់

មាន ២៨,៣៧% និងសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពី១០០នាក់ឡើងទៅមាន ២៨,៣៧%។ យ៉ាងណាមិញ ក្នុងឆមាសទី១ ឆ្នាំ២០២៥ សហគ្រាស គ្រឹះស្ថានហាក់មាននិន្នាការជ្រើសរើសបុគ្គលិកតិចជាងមុន (ចំនួន ៥២៩កន្លែង) បើធៀបទៅឆមាសមុន (៩១៣កន្លែង)។ ក្នុងឆមាសទី១ ឆ្នាំ២០២៥នេះ មានសហគ្រាស គ្រឹះស្ថាន ៤៨,៦២% ប៉ុណ្ណោះដែលប្រកាសជ្រើសរើសបុគ្គលិក។

លើសពីនេះ សហគ្រាស គ្រឹះស្ថាន ប្រមាណ ២៥,៩៥% បានរាយការណ៍ពីភាពលំបាកក្នុងការជ្រើសរើសបុគ្គលិក ដែលបណ្តាលមកពីកត្តាមួយចំនួនរួមមាន កង្វះបេក្ខជនមានជំនាញដែលត្រូវការ, ការប្រកួតប្រជែងខ្លាំងពីនិយោជកផ្សេងទៀត, កង្វះបេក្ខជនដែលបទពិសោធន៍ការងារគ្រប់គ្រាន់ទៅតាមតម្រូវការ ដោយអនុវិស័យនេះមាននិន្នាការជ្រើសរើសកម្មករ និយោជិតដែលមានបទពិសោធន៍ស្រាប់ទាក់ទងនឹងមុខតំណែងនីមួយៗ ក្នុងនោះសហគ្រាស ២២,៣៦% ដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូងក្នុងឆមាសទី១ ឆ្នាំ២០២៥ ដែលកាលពីឆមាសទី២ ឆ្នាំ២០២៤ ស្ថិតក្នុងអត្រា ៥០%។

តារាងទី ៣២៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យផលិតកៅស៊ូ និងប្លាស្ទិក

| ផលិតកៅស៊ូ និងប្លាស្ទិក | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 177 | 208 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 40.68% | 43.75% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 5.08% | 5.29% |
| | 5-19 | 29.94% | 37.98% |
| | 20-99 | 33.90% | 28.37% |
| | 100-199 | 13.56% | 10.10% |
| | 200-499 | 11.30% | 7.69% |
| | 500+ | 6.21% | 10.58% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 8.45% | 12.38% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 50.00% | 22.36% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 58.45% | 48.62% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 7.23% | 25.94% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 4.41% | 17.70% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 2.82 | 3.23 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 913 | 529 |
| ១. ការគ្រប់គ្រងពេលវេលា | | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការត្រួតពិនិត្យ | | | |
| ៣. ការដោះស្រាយបញ្ហា | | | |
| ៤. ការសម្របសម្រួល | | | |
| ៥. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | | | |
| ១. ការវិភាគការគ្រប់គ្រងគុណភាព | | | |

| | |
|---|---|
| ២. ការត្រួតពិនិត្យប្រតិបត្តិការ | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ |
| ៣. ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ | |
| ៤. ភាសាចិន | |
| ៥. ភាសាអង់គ្លេស | |
| ១. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក |
| ២. បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ | |
| ៣. កង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ | |
| ៤. កង្វះខាតបេក្ខជនជាទូទៅ | |
| ៥. ការប្រកួតប្រជែងខ្លាំងពីនិយោជកផ្សេងទៀត | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្លេក), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

ទោះបីជាចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុកមានការថយចុះក្តី ប៉ុន្តែសន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិតមានការកើនឡើងពី ២,៨២ ក្នុងឆមាសទី២ ឆ្នាំ២០២៤ មក ៣,២៣ ក្នុងឆមាសទី១ ឆ្នាំ២០២៥។ សម្រាប់មុខរបរនីមួយៗក្នុងអនុវិស័យនេះមានសន្ទស្សន៍ខ្ពស់ ដែលបង្ហាញពីឱកាសការងារខ្ពស់ និងភាពងាយរកការងារធ្វើសម្រាប់អ្នកស្វែងរកការងារធ្វើ។ តារាងទី៣៣ បង្ហាញពីមុខតំណែងដែលមានឱកាសការងារខ្ពស់ជាងគេរួមមាន អ្នកជំនាញផ្នែកធនធានមនុស្ស ឬជ្រើសរើសបុគ្គលិក និងនាយកគ្រប់គ្រងការផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ ជាមួយនឹងសន្ទស្សន៍ ៥,០ បន្ទាប់មក អ្នកបញ្ជាម៉ាស៊ីនផលិតផលិតផលជ័រកៅស៊ូ អ្នកបើកបររថយន្តដឹកទំនិញ និងរថយន្តដឹកទំនិញធុនធ្ងន់ ព្រមទាំងគណនេយ្យករ (កម្រិតខ្ពស់) ឬសវនករ (សន្ទស្សន៍ ៤,០) ក៏មានឱកាសការងារច្រើនផងដែរ។

សម្រាប់ប្រាក់ឈ្នួលក្នុងអនុវិស័យនេះ មានគម្លាតតិចតួចទៅតាមមុខតំណែង។ ក្នុងនោះ វិស្វករឧស្សាហកម្ម និងផលិតកម្មទទួលបានប្រាក់ឈ្នួលច្រើនជាងគេ (៥០០ដុល្លារអាម៉េរិក) នាយកគ្រប់គ្រងការផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ (៤៥០ដុល្លារអាម៉េរិក) អ្នកជំនាញផ្នែកធនធានមនុស្ស ឬជ្រើសរើសបុគ្គលិក (៤៤៥ដុល្លារអាម៉េរិក)។ ដោយឡែក កម្មករ និយោជិតជំនាញ ដូចជាជាងអគ្គិសនីទូទៅ អ្នកបញ្ជាម៉ាស៊ីនជាដើម អាចមានប្រាក់ខែមធ្យមចន្លោះពី ២០០ ទៅ ជិត ៤០០ដុល្លារអាម៉េរិក ដោយមិនបានបូកបន្ថែមអត្ថប្រយោជន៍ផ្សេងទៀត។

តារាងទី ៣៣៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យផលិតកៅស៊ូ និងប្លាស្ទិក

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 2423 | អ្នកជំនាញផ្នែកធនធានមនុស្ស ឬជ្រើសរើសបុគ្គលិក | 3.27 | 5.00 | $ 445 | $ 54 |
| 2 | 1222 | នាយកគ្រប់គ្រងការផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ | 4.40 | 5.00 | $ 450 | $ 41 |
| 3 | 8141 | អ្នកបញ្ជាម៉ាស៊ីនផលិតផលិតផលជ័រកៅស៊ូ | - | 4.00 | $ 200 | $ 41 |

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 4 | 8332 | អ្នកបើកបររថយន្តដឹកទំនិញ និងរថយន្តដឹកទំនិញធុនធ្ងន់ | - | 4.00 | $ 257 | $ 39 |
| 5 | 2411 | គណនេយ្យករ (កម្រិតខ្ពស់) ឬសវនករ | 3.39 | 4.00 | $ 516 | $ 45 |
| 6 | 2141 | វិស្វករឧស្សាហកម្ម និងផលិតកម្ម | - | 3.36 | $ 500 | $ 78 |
| 7 | 7411 | ជាងអគ្គិសនីទូទៅ | 3.09 | 3.00 | $ 364 | $ 62 |
| 8 | 3512 | អ្នកបច្ចេកទេសគាំទ្រដល់អ្នកប្រើប្រាស់នូវបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា | 4.03 | 3.00 | $ 350 | $ 41 |
| 9 | 8142 | អ្នកបញ្ជាម៉ាស៊ីនផលិតផលិតផលផ្លាស្ទិច | - | 2.94 | $ 319 | $ 30 |
| 10 | 4321 | បុគ្គលិកផ្នែកកត់ត្រាខាងស្តុកទំនិញ | 2.86 | 2.00 | $ 421 | $ 59 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

## ២.៤.១១ ផលិតផលិតផលឈើ និងក្រដាស

អនុវិស័យផលិតឈើ និងក្រដាសចូលរួមចំណែកតិចតួច ឬប្រមាណ ៣% ក្នុងការនាំចេញរបស់កម្ពុជា ក្នុងឆ្នាំ២០២៤ (ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។ ប៉ុន្តែ អនុវិស័យនេះបានបង្ហាញពីតម្លៃនាំចេញដែលមានកំណើនជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ចំនួនសហគ្រាស គ្រឹះស្ថាននៅក្នុងវិស័យនេះ ក៏មានកំណើនដូចគ្នា។ តាមរយៈតារាងទី ៣៤ សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះ មានកំណើនពី ១១៩ ក្នុងដើមឆមាសទី២ ឆ្នាំ២០២៤ ដល់ ២២៥ ក្នុងដើមឆមាសទី១ ឆ្នាំ២០២៥។ សហគ្រាស គ្រឹះស្ថានប្រមាណ ៣០% ប៉ុណ្ណោះក្នុងអនុវិស័យនេះ ដែលមានម្ចាស់ភាគហ៊ុនជាជនជាតិខ្មែរ ១០០% ដែលបង្ហាញថាអនុវិស័យនេះនៅពឹងផ្អែកលើការវិនិយោគពីបរទេស។ ដោយឡែក របាយសហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យនេះក្នុងចន្លោះឆមាសទី២ ឆ្នាំ២០២៤ ដល់ឆមាសទី១ ឆ្នាំ២០២៥ បែងចែកតាមទំហំសហគ្រាសមិនមានការផ្លាស់ប្តូរនោះទេ។

តារាងទី ៣៤ ក៏បង្ហាញដែរថា សហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យនេះនៅបន្តការជ្រើសរើសបុគ្គលិកឱ្យចូលបម្រើការ ដែលអាចបង្ហាញពីកំណើនឱកាសការងារបន្ថែមក្នុងអនុវិស័យនេះ។ សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះប្រមាណ ៤៨% បានជ្រើសរើសបុគ្គលិកយ៉ាងតិចមួយនាក់ ក្នុងឆមាសទី២ ឆ្នាំ២០២៤ ហើយអត្រានេះកើនឡើងដល់ជិត ៦០% ក្នុងឆមាសទី១ ឆ្នាំ២០២៥ បើទោះបីជាចំនួនប្រកាសជ្រើសរើសមានចំនួនតិចជាងមុនក៏ដោយ។ តែទោះជាយ៉ាងនេះក្តី ការផ្តល់ឱកាសដល់អ្នកស្វែងរកការងារលើកដំបូង ឬអ្នកទើបបញ្ចប់ការសិក្សា ហាក់មាននិន្នាការផ្លាស់ប្តូរស្របទៅនឹងនិន្នាការគម្លាតជំនាញ។ មានន័យថា សហគ្រាស គ្រឹះស្ថាន ៤៥,៩% ក្នុងអនុវិស័យនេះ

កាលពីដើមឆមាសទី២ ឆ្នាំ២០២៤ បានទទួលយកអ្នកដែលមិនមានបទពិសោធការងារចូលធ្វើការ ខណៈសហគ្រាស គ្រឹះស្ថាន ៣៣% បានរាយការណ៍ថាមានគម្លាតជំនាញ ក្នុងរយៈពេល ៦ខែ កន្លងមក។ ផ្ទុយមកវិញ នៅដើមឆមាសទី១ ឆ្នាំ២០២៥ សហគ្រាស គ្រឹះស្ថាន ប្រមាណ ៧% ប៉ុណ្ណោះដែលបានផ្តល់ឱកាសការងារដល់អ្នកទើបស្វែងរកការងារលើកដំបូងក្នុងរយៈពេល ៦ខែកន្លងមក ខណៈដែលអត្រាសហគ្រាស គ្រឹះស្ថានរាយការណ៍ថាមានគម្លាតជំនាញមានត្រឹម ២៦,៧%។ ម៉្យាងវិញទៀត ភាគរយនៃសហគ្រាស គ្រឹះស្ថានដែលមានកង្វះជំនាញ ឬស្វែងរកកម្មករនិយោជិតដែលមានលក្ខណៈសម្បត្តិតាមការចង់បានមិនបាន ធៀបនឹងសហគ្រាស គ្រឹះស្ថានសរុបដែលជ្រើសរើសបុគ្គលិក ក៏មានការថយចុះ ក្នុងរយៈពេលដូចគ្នាផងដែរ (ពី ៩,៥% មក ៧,២%)។

ទន្ទឹមនេះ តារាងទី៣៤ បង្ហាញថាសហគ្រាស គ្រឹះស្ថានដល់ទៅប្រមាណ ២០% បានរាយការណ៍ថាមានការលំបាកក្នុងការស្វែងរកបុគ្គលិក ដែលកើនពី ១១% នៃសហគ្រាស គ្រឹះស្ថានដែលបានរាយការណ៍កាលពីឆមាសទី២ ឆ្នាំ២០២៤។ ការណ៍នេះអាចបង្ហាញអំពីស្ថានភាពដែលសហគ្រាស គ្រឹះស្ថានត្រូវពិចារណាលើផលវិបាកនៃទំនាក់ទំនងរវាងការទទួលយកបុគ្គលិកជាអ្នកស្វែងរកការងារលើកដំបូង/អ្នកទើបបញ្ចប់ការសិក្សា ភាពងាយស្រួលក្នុងជ្រើសរើសបុគ្គលិក និងគម្លាតជំនាញក្នុងសហគ្រាស គ្រឹះស្ថាន។ មូលហេតុចម្បងៗដែលនាំឱ្យសហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះមានការលំបាកក្នុងការស្វែងរកបុគ្គលិករួមមាន ១). កង្វះបេក្ខជនដែលមានអាកប្បកិរិយាភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ, ២). កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧ. សញ្ញាបត្រ), ៣). បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ, ៤). កង្វះខាតបេក្ខជនជាទូទៅ និង ៥). បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច។

អនុវិស័យផលិតឈើ និងក្រដាស ជាអនុវិស័យដែលមានឱកាសការងារធម្មតាជាមធ្យម ដោយមានតម្លៃសន្ទស្សន៍ការលំបាកស្វែងរកបុគ្គលិក ឬសន្ទស្សន៍ឱកាសការងារត្រឹម ៣,២១ សម្រាប់ឆមាសទី២ ឆ្នាំ២០២៤ និង ៣,១៣ សម្រាប់ឆមាសទី១ ឆ្នាំ២០២៥។ តែទោះជាយ៉ាងនេះក្តី ក្នុងការចាប់យកឱកាសការងារនៅក្នុងអនុវិស័យនេះ ជំនាញបច្ចេកទេសដែលអ្នកស្វែងរកការងារគួរមានគឺផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងទំនាក់ទំនងដែលរួមបញ្ចូលជំនាញភាសាចិន ការគ្រប់គ្រងធនធានមនុស្ស និងជំនាញគណនេយ្យ និងហិរញ្ញវត្ថុ និងផ្នែកផលិតកម្មរួមបញ្ចូលជំនាញវិភាគ ការគ្រប់គ្រងគុណភាព និងការត្រួតពិនិត្យប្រតិបត្តិការ។ ដោយឡែក ជំនាញទន់ដែលត្រូវការដែលនាំឱ្យការងារកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលនៅក្នុងអនុវិស័យនេះរួមមាន ការត្រួតពិនិត្យ ការដោះស្រាយបញ្ហា ការគ្រប់គ្រងពេលវេលា ការគ្រប់គ្រងអតិថិជន និងជំនាញទំនាក់ទំនងផ្ទាល់មាត់។

## តារាងទី ៣៤៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យផលិតផលិតផលឈើ និងក្រដាស

| ផលិតផលិតផលឈើ និងក្រដាស | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 119 | 225 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 31.09% | 33.78% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 4.20% | 4.44% |
| | 5-19 | 26.89% | 31.56% |
| | 20-99 | 34.45% | 32.00% |
| | 100-199 | 12.61% | 13.33% |
| | 200-499 | 8.40% | 7.11% |
| | 500+ | 13.45% | 11.56% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 32.97% | 24.69% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 45.90% | 7.19% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 47.78% | 59.68% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 10.74% | 20.07% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 9.58% | 7.19% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 3.21 | 3.13 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 3,052 | 247 |
| ១. ការត្រួតពិនិត្យ | | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការដោះស្រាយបញ្ហា | | | |
| ៣. ការគ្រប់គ្រងពេលវេលា | | | |
| ៤. ការគ្រប់គ្រងអតិថិជន | | | |
| ៥. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | | | |
| ១. ភាសាចិន | | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការវិភាគការគ្រប់គ្រងគុណភាព | | | |
| ៣. ការត្រួតពិនិត្យប្រតិបត្តិការ | | | |
| ៤. ការគ្រប់គ្រងធនធានមនុស្ស | | | |
| ៥. ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ | | | |
| ១. កង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ | | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក | |
| ២. កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧ. សញ្ញាបត្រ) | | | |
| ៣. បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ | | | |
| ៤. កង្វះខាតបេក្ខជនជាទូទៅ | | | |
| ៥. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | | | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្ទើង), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

តារាងទី ៣៥ បង្ហាញអំពីសន្ទស្សន៍ឱកាសការងារសម្រាប់អនុវិស័យផលិតឈើ និងក្រដាស ក្នុងឆមាសទី២ ឆ្នាំ២០២៤ និងក្នុងឆមាសទី១ ឆ្នាំ២០២៥ នៃមុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនជាងគេចំនួនប្រាំពីរ។ តារាងនេះបង្ហាញថា មុខរបរដែលមានឱកាសការងារខ្ពស់រួមមាន អ្នកបកប្រែអត្ថបទ អ្នកបកប្រែផ្ទាល់មាត់ និងភាសាវិទូដទៃទៀត, អ្នករចនាក្រាហ្វិច និងម៉ាលជីមេឌៀ, អ្នកជំនាញផ្នែកធនធានមនុស្ស ឬជ្រើសរើសបុគ្គលិក, និងលេខាធិការផ្នែករដ្ឋបាល និងប្រតិបត្តិ ដោយមុខរបរទាំងនេះមានតម្លៃសន្ទស្សន៍ដល់ទៅ ៤,០។ ផ្ទុយមកវិញ បុគ្គលិកការិយាល័យទូទៅ គឺជាមុខរបរដែលមានការប្រកាសជ្រើសរើសច្រើន ប៉ុន្តែភាពប្រកួតប្រជែងនៅក្នុងការទទួលបានការងារនេះ ក៏ហាក់មានកម្រិតខ្ពស់ដូចគ្នាដោយតម្លៃសន្ទស្សន៍មានត្រឹម ២,៥០ ប៉ុណ្ណោះ ដែលបង្ហាញពីឱកាសការងារទាប។ សម្រាប់កម្មករផលិតកម្ម និងអ្នករៀបដាក់ទំនិញតាមធ្នើក្នុងឃ្លាំង មានឱកាសការងារធម្មតាដែលស្ថិតក្នុងចន្លោះ ២,៨ ទៅ ៣,២។

តារាងទី ៣៥៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យផលិតផលិតផលឈើ និងក្រដាស

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 2643 | អ្នកបកប្រែអត្ថបទ អ្នកបកប្រែផ្ទាល់មាត់ និងភាសាវិទូដទៃទៀត | - | 4.00 | $ 500 | |
| 2 | 2166 | អ្នករចនាក្រាហ្វិច និងម៉ាលជីមេឌៀ | 2.83 | 4.00 | $ 660 | $ 50 |
| 3 | 2423 | អ្នកជំនាញផ្នែកធនធានមនុស្ស ឬជ្រើសរើសបុគ្គលិក | 3.27 | 4.00 | $ 604 | $ 57 |
| 4 | 3343 | លេខាធិការផ្នែករដ្ឋបាល និងប្រតិបត្តិ | 2.96 | 4.00 | $ 466 | $ 219 |
| 5 | 9334 | អ្នករៀបដាក់ទំនិញតាមធ្នើក្នុងឃ្លាំង | 3.14 | 3.00 | $ 231 | $ 24 |
| 6 | 9329 | កម្មករផលិតកម្មដែលមិនបានធ្វើចំណាត់ថ្នាក់ | 3.54 | 2.84 | $ 215 | $ 37 |
| 7 | 4110 | បុគ្គលិកការិយាល័យទូទៅ | 2.83 | 2.50 | $ 394 | $ 191 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។
ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

### ២.៤.១២ កម្មន្តសាលផ្សេងៗ

អនុវិស័យកម្មន្តសាលផ្សេងៗ ដែលរួមមានកម្មន្តសាលទាំងឡាយណាក្រៅពី វាយនភណ្ឌ កាត់ដេរ ស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប, ការផលិតផលិតផលកៅស៊ូ និងប្លាស្ទិក, ការផលិតផលិតផលឈើ និងក្រដាស, និងការផលិតអាហារ និងភេសជ្ជៈ ត្រូវបានចាត់ចូលនៅក្នុងអនុវិស័យនេះសម្រាប់របាយការណ៍នេះ។ តារាងទី ៣៦ បង្ហាញថាចំនួនសហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យនេះមានការថយចុះពី ១ ៥៣៦ ក្នុងដើមឆមាសទី២ ឆ្នាំ២០២៤ មកត្រឹម ១ ៤០១ ក្នុងដើមឆមាសទី២ ឆ្នាំ២០២៥ ខណៈដែលចំនួនសហគ្រាស គ្រឹះស្ថាននៅក្នុងអនុ-

វិស័យដូចជា ផលិតអាហារ និងភេសជ្ជៈ និងផលិតផលកៅស៊ូ និងប្លាស្ទិកមានការកើនឡើងគួរឱ្យកត់សម្គាល់ (តារាងទី ៣០ និង៣២)។ តារាងទី ៣៦ ក៏បង្ហាញដែរថា សហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះប្រមាណ ៥៧% មានម្ចាស់ភាគហ៊ុនជាជនជាតិខ្មែរ ១០០% ដែលអាចបង្ហាញអំពីភាពចម្រុះនៃភាគហ៊ុនខ្មែរ និងបរទេស ដោយយោងតាមភាពចម្រុះនៃកម្មន្តសាលដែលស្ថិតក្នុងអនុវិស័យនេះ។ សហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យនេះមួយចំនួន ឬ ១៣,២២% ក្នុងឆមាសទី២ ឆ្នាំ២០២៤ និង ១៦,៤២% ក្នុងឆមាសទី១ ឆ្នាំ២០២៤ ជាសហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតក្រោម ៥នាក់ និងសហគ្រាស គ្រឹះស្ថានមួយភាគធំ ឬ ៥០,២៨% ក្នុងឆមាសទី២ ឆ្នាំ២០២៤ និង ៤៧,២៥% ក្នុងឆមាសទី១ ឆ្នាំ២០២៥ ជាសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចន្លោះ ៥ ទៅ ១៩នាក់។

ក្នុងឆមាសទី២ ឆ្នាំ២០២៤ ៦៥,២៣% នៃសហគ្រាស គ្រឹះស្ថានបានទទួលយកអ្នកដែលទើបស្វែងរកការងារលើកដំបូងឱ្យចូលធ្វើការ ប៉ុន្តែអត្រានេះបានធ្លាក់ចុះនៅដើមឆមាសទី១ ឆ្នាំ២០២៥ មកត្រឹម ៣១,១៣%។ គួរកត់សម្គាល់ផងដែរថា ភាគរយនៃសហគ្រាស គ្រឹះស្ថានដែលមានបញ្ហាគម្លាតជំនាញក៏មាននិន្នាការថយចុះក្នុងរយៈពេលដូចគ្នា ពី ២៨,៩២% ទៅ ២០,៨១% (តារាងទី ៣៦)។ សហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យនេះក៏បន្តការជ្រើសរើសបុគ្គលិកក្នុងរយៈពេល ៦ខែ ខាងមុខ ដោយសហគ្រាស គ្រឹះស្ថាន ៧៣,៨៤% កំពុងស្វែងរកបុគ្គលិកក្នុងឆមាសទី១ ឆ្នាំ២០២៥ ឬស្មើនឹងតម្រូវការកម្មករនិយោជិតចំនួន ៤ ៧៧០នាក់ (កើនពី ៥១,៣៤% ក្នុងឆមាសទី២ ឆ្នាំ២០២៤ ឬស្មើនឹងកម្មករនិយោជិតចំនួន ១ ៣៨៦នាក់)។ ខុសពីអនុវិស័យផលិតឈើ និងក្រដាស បញ្ហាកង្វះជំនាញសម្រាប់អនុវិស័យនេះបានកើនឡើង (១៣,១២% នៃសហគ្រាស គ្រឹះស្ថានដែលជ្រើសរើសបុគ្គលិកក្នុងឆមាសទី១ ឆ្នាំ២០២៥ កើនពី ៤,៧២% ក្នុងឆមាសទី២ ឆ្នាំ២០២៤)។ ចំណែកមូលហេតុចម្បងនៃផលលំបាកក្នុងការជ្រើសរើសបុគ្គលិក រួមមាន ១). លក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែង (ឧ. ប្រាក់ខែតិច), ២). បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច, ៣). កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់, ៤). មិនសូវមានមនុស្សចាប់អារម្មណ៍នឹងការងារប្រភេទនេះ និង ៥). ការប្រកួតប្រជែងខ្លាំងពីនិយោជកផ្សេងទៀត។

តម្លៃសន្ទស្សន៍ឱកាសការងារក្នុងអនុវិស័យនេះស្ថិតក្នុងរង្វង់ធម្មតា ដែលថយពី ៣,២២ ក្នុងឆមាសទី២ ឆ្នាំ២០២៤ មកត្រឹម ៣,១៥ ក្នុងឆមាសទី១ ឆ្នាំ២០២៥។ ជំនាញបច្ចេកទេសដែលបេក្ខជនគួរមាន រួមមាន ការត្រួតពិនិត្យប្រតិបត្តិការ, ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ, មូលដ្ឋានគ្រឹះកុំព្យូទ័រ, ការគ្រប់គ្រងធនធានមនុស្ស និងភាសាអង់គ្លេស ហើយជំនាញទន់ដែលបេក្ខជនគួរមាន រួមមាន ការដោះស្រាយបញ្ហា, ជំនាញទំនាក់ទំនងផ្ទាល់មាត់, ការគ្រប់គ្រងអតិថិជន, ជំនាញទំនាក់ទំនងជាលាយលក្ខណ៍អក្សរ និងការត្រួតពិនិត្យ។

## តារាងទី ៣៦៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យកម្មន្តសាលផ្សេងៗ

| កម្មន្តសាលផ្សេងៗ | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 1,536 | 1,401 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 57.29% | 57.17% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 13.22% | 16.42% |
| | 5-19 | 50.26% | 47.25% |
| | 20-99 | 18.10% | 18.99% |
| | 100-199 | 6.32% | 6.42% |
| | 200-499 | 6.32% | 6.57% |
| | 500+ | 5.79% | 4.35% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | | 28.92% | 20.81% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | | 65.23% | 31.13% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | | 51.34% | 73.84% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 20.95% | 32.57% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | | 4.72% | 13.12% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | | 3.22 | 3.15 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | | 1,386 | 4,770 |
| ១. ការដោះស្រាយបញ្ហា | | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ជំនាញទំនាក់ទំនងផ្ទាល់មាត់ | | | |
| ៣. ការគ្រប់គ្រងអតិថិជន | | | |
| ៤. ជំនាញទំនាក់ទំនងជាលាយលក្ខណ៍អក្សរ | | | |
| ៥. ការត្រួតពិនិត្យ | | | |
| ១. ការត្រួតពិនិត្យប្រតិបត្តិការ | | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ | | | |
| ៣. មូលដ្ឋានគ្រឹះកុំព្យូទ័រ | | | |
| ៤. ការគ្រប់គ្រងធនធានមនុស្ស | | | |
| ៥. ភាសាអង់គ្លេស | | | |
| ១. លក្ខខណ្ឌមិនសូវល្អសម្រាប់មុខតំណែងនេះ (ឧ. ប្រាក់ខែតិច) | | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក | |
| ២. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | | | |
| ៣. កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧ. សញ្ញាបត្រ) | | | |
| ៤. មិនសូវមានមនុស្សចាប់អារម្មណ៍នឹងការងារប្រភេទនេះ | | | |
| ៥. ការប្រកួតប្រជែងខ្លាំងពីនិយោជកផ្សេងទៀត | | | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្ទើង), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

តារាងទី ៣៧ បង្ហាញអំពីមុខរបរដែលមានចំនួនជ្រើសរើសបុគ្គលិកច្រើនជាងគេក្នុងអនុវិស័យកម្មន្តសាលផ្សេងៗ ព្រមទាំងតម្លៃសន្ទស្សន៍ឱកាសការងារនៃមុខរបរនីមួយៗ។ មុខរបរចំនួន ៣ គឺ អ្នកធ្វើកែវ អ្នកកាត់កែវ អ្នកក្រឡឹងកែវ និងអ្នកធ្វើបង្អើយការ, បុគ្គលិកការិយាល័យទូទៅ, និងបុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម ជាមុខរបរដែលមានឱកាសការងារខ្ពស់ដោយសារនិយោជកមានការលំបាកក្នុងការជ្រើសរើស ឬតម្លៃសន្ទស្សន៍ស្មើនឹង ៤ ខណៈដែលមុខរបរចំនួន ៧ ផ្សេងទៀតមានតម្លៃសន្ទស្សន៍ឱកាសការងារធម្មតា។ ផ្ទុយពីអនុវិស័យផលិតឈើ និងក្រដាស សហគ្រាស គ្រឹះស្ថានច្រើនជាងនៅក្នុងអនុវិស័យនេះ មានការលំបាកក្នុងស្វែងរកបុគ្គលិកការិយាល័យទូទៅ។

តារាងទី ៣៧៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យកម្មន្តសាលផ្សេងៗ

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 7315 | អ្នកធ្វើកែវ អ្នកកាត់កែវ អ្នកក្រឡឹងកែវ និងអ្នកធ្វើបង្អើយការ | - | 4.00 | $ 300 | - |
| 2 | 4110 | បុគ្គលិកការិយាល័យទូទៅ | 2.83 | 4.00 | $ 378 | $ 186 |
| 3 | 3323 | បុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម | 3.25 | 4.00 | $ 490 | $ 240 |
| 4 | 7411 | ជាងអគ្គីសនីទូទៅ | 3.09 | 3.00 | $ 344 | $ 67 |
| 5 | 3322 | អ្នកតំណាងលក់ផ្នែកពាណិជ្ជកម្ម | 3.30 | 3.00 | $ 322 | $ 32 |
| 6 | 3139 | អ្នកបច្ចេកទេសត្រួតពិនិត្យដំណើរការផលិត | - | 3.00 | $ 395 | $ 36 |
| 7 | 2431 | វិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ | 3.08 | 3.00 | $ 579 | $ 105 |
| 8 | 4321 | បុគ្គលិកផ្នែកកត់ត្រាខាងស្តុកទំនិញ | 2.86 | 3.00 | $ 354 | $ 100 |
| 9 | 3313 | ជំនួយការគណនេយ្យករ | 3.08 | 3.00 | $ 431 | $ 154 |
| 10 | 8182 | អ្នកបញ្ជាម៉ាស៊ីនប្រើចំហាយទឹក និងឆ្នាំងទាញយកចំហាយទឹក | 4.44 | 3.00 | $ 329 | $ 27 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

## ២.៤.១៣ ដឹកជញ្ជូន និងស្តុកទំនិញ

អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញបានបង្ហាញអំពីកំណើននៃចំនួនសហគ្រាស គ្រឹះស្ថានពី ១ ១០២ ក្នុងដើមឆមាសទី២ ឆ្នាំ២០២៤ ដល់ ១ ៣៦១ ក្នុងដើមឆមាសទី១ ឆ្នាំ២០២៥ ដូចមានបង្ហាញក្នុងតារាងទី ៣៨។ សហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យនេះ ៧១% ជាសហគ្រាស គ្រឹះស្ថានដែលមានម្ចាស់ជាជនជាតិខ្មែរ។ ជាមួយគ្នានេះ អនុវិស័យនេះ មានប្រមាណ ៨៩% ជាសហគ្រាស គ្រឹះស្ថានមីក្រូ និងតូចដែលមានកម្មករនិយោជិតតិចជាង ២០នាក់។ សហគ្រាស គ្រឹះស្ថាននៅក្នុងអនុវិស័យនេះប្រមាណ ៦០% ទាំងកាលពីដើមឆមាសទី២ ឆ្នាំ២០២៤ និង

ដើមឆមាសទី១ ឆ្នាំ២០២៥ កំពុងជ្រើសរើសបុគ្គលិកបន្ថែម ប៉ុន្តែចំនួនជ្រើសរើសក្នុងដើមឆមាសទី១ ឆ្នាំ២០២៥ នេះ មានត្រឹម ៩៨៥នាក់ ប៉ុណ្ណោះ ដែលតិចជាងចំនួនកាលពីដើមឆមាសទី២ ឆ្នាំ២០២៤ (៧ ៦២០នាក់)។ ការជ្រើសរើសបុគ្គលិកដែលជាអ្នកស្វែងរកការងារដំបូងឬមិនទាន់មានបទពិសោធន៍ការងារក្នុងរយៈពេល ៦ខែកន្លងមក យើងឃើញថាសហគ្រាស គ្រឹះស្ថាន ៧៦,៦៤% បានទទួលយកអ្នកស្វែងរកការងារលើកដំបូងក្នុងឆមាសទី១ ឆ្នាំ២០២៤ និងថយមកត្រឹម ១៧,៤៤% ប៉ុណ្ណោះ ក្នុងឆមាសទី១ ឆ្នាំ២០២៥ ចំពោះបញ្ហាគម្លាតជំនាញ មានតែប្រមាណ ២០% នៃសហគ្រាស គ្រឹះស្ថានដែលមានបញ្ហាប្រឈមនេះ។

ទន្ទឹមនេះ សហគ្រាស គ្រឹះស្ថានកាន់តែច្រើនឡើងមាននិន្នាការជ្រើសរើសយកអ្នកដែលមានបទពិសោធន៍ការងារឱ្យចូលបម្រើការ។ សហគ្រាស គ្រឹះស្ថានច្រើនជាងមុន (៣៥,៩៣% ក្នុងឆមាសទី១ ឆ្នាំ២០២៥ ធៀបនឹង ២៥,៨៣% ក្នុងឆមាសទី២ ឆ្នាំ២០២៤) មានការលំបាកក្នុងការជ្រើសរើសបុគ្គលិក និងសហគ្រាស គ្រឹះស្ថាន ច្រើនជាងមុន (០,៩០% ក្នុងឆមាសទី១ ឆ្នាំ២០២៥ ធៀប ១១,០៦% ក្នុងឆមាសទី២ ឆ្នាំ២០២៤) មានបញ្ហាកង្វះជំនាញ។ ទោះជាយ៉ាងនេះក្តី អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញ ក៏មានតម្លៃសន្ទស្សន៍ឱកាសការងារធម្មតាជាមធ្យម (៣,២២ ក្នុងឆមាសទី១ ឆ្នាំ២០២៥)។ មូលហេតុនៃភាពលំបាកស្វែងរកបុគ្គលិករួមមាន៖ ១). បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ, ២). បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច, ៣). មិនសូវមានមនុស្សចាប់អារម្មណ៍នឹងការងារប្រភេទនេះ, ៤). កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧ. សញ្ញាបត្រ) និង៥). កង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ។

តារាងទី ៣៨ បង្ហាញពីជំនាញដែលកំពុងមានតម្រូវការរួមមាន ការគ្រប់គ្រងធនធានមនុស្ស, ការវិភាគការគ្រប់គ្រងគុណភាព, ភាសាអង់គ្លេស, ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ និងការត្រួតពិនិត្យប្រតិបត្តិការ។ ដោយឡែកជំនាញទន់ចម្បងៗទាំង ៥ ដែលសហគ្រាស គ្រឹះស្ថានក្នុងអនុវិស័យនេះត្រូវការបំផុត គឺការដោះស្រាយបញ្ហា, ការគ្រប់គ្រងអតិថិជន, ការត្រួតពិនិត្យ, ការគ្រប់គ្រងពេលវេលា និងការត្រិះរិះពិចារណា។

តារាងទី ៣៨៖ ព័ត៌មានសង្ខេបសម្រាប់អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញ

| ដឹកជញ្ជូន និងស្តុកទំនិញ | | ឆមាសទី២ ឆ្នាំ២០២៤ | ឆមាសទី១ ឆ្នាំ២០២៥ |
|---|---|---|---|
| ចំនួនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងប្រព័ន្ធ LACMS | | 1,102 | 1,361 |
| ភាគរយដែលសហគ្រាស គ្រឹះស្ថានជាជនជាតិខ្មែរ | | 70.87% | 71.24% |
| ទំហំសហគ្រាស គ្រឹះស្ថាន | 1-4 | 20.96% | 22.58% |
| | 5-19 | 65.97% | 66.24% |
| | 20-99 | 10.07% | 8.94% |
| | 100-199 | 1.27% | 1.19% |
| | 200-499 | 1.09% | 0.82% |
| | 500+ | 0.64% | 0.22% |

| | | |
|---|---|---|
| ភាគរយសហគ្រាស គ្រឹះស្ថានដែលជួបបញ្ហាគម្លាតជំនាញ | 17.74% | 24.26% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលផ្តល់ឱកាសដល់អ្នកស្វែងរកការងារដំបូង | 76.64% | 17.44% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលមានប្រកាសជ្រើសរើសបុគ្គលិកយ៉ាងតិច ១នាក់ | 60.82% | 58.21% |
| ភាគរយសហគ្រាស គ្រឹះស្ថានដែលពិបាកជ្រើសរើសបុគ្គលិក (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | 25.83% | 35.93% |
| ភាគរយសហគ្រាស គ្រឹះស្ថានជួបនូវកង្វះជំនាញ (ធៀបនឹងសហគ្រាស គ្រឹះស្ថានដែលប្រកាសជ្រើសរើស) | 0.90% | 11.06% |
| សន្ទស្សន៍ឱកាសការងារសម្រាប់កម្មករ និយោជិត | 3.19 | 3.22 |
| ចំនួនប្រកាសជ្រើសរើសកម្មករ និយោជិតដែលរំពឹងទុក | 7,620 | 985 |
| ១. ការដោះស្រាយបញ្ហា | ជំនាញទន់ទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការគ្រប់គ្រងអតិថិជន | | |
| ៣. ការត្រួតពិនិត្យ | | |
| ៤. ការគ្រប់គ្រងពេលវេលា | | |
| ៥. ការត្រិះរិះពិចារណា | | |
| ១. ការគ្រប់គ្រងធនធានមនុស្ស | ជំនាញបច្ចេកទេស/ជំនាញរឹងទាំង៥ ដែលមានតម្រូវការខ្ពស់ | |
| ២. ការវិភាគការគ្រប់គ្រងគុណភាព | | |
| ៣. ភាសាអង់គ្លេស | | |
| ៤. ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ | | |
| ៥. ការត្រួតពិនិត្យប្រតិបត្តិការ | | |
| ១. បទពិសោធន៍ការងារមិនគ្រប់គ្រាន់ទៅតាមតម្រូវការ | មូលហេតុទាំង៥ ដែលនិយោជកពិបាកជ្រើសរើសបុគ្គលិក | |
| ២. បេក្ខជនមានជំនាញដែលត្រូវការមានចំនួនតិច | | |
| ៣. មិនសូវមានមនុស្សចាប់អារម្មណ៍នឹងការងារប្រភេទនេះ | | |
| ៤. កង្វះខាតបេក្ខជនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ (ឧ. សញ្ញាបត្រ) | | |
| ៥. កង្វះបេក្ខជនដែលមានអាកប្បកិរិយា ភាពមោះមុតឬបុគ្គលិកលក្ខណៈដែលត្រូវការ | | |

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវផ្អែកលើទិន្នន័យរដ្ឋបាលរបស់ MLVT (ពណ៌ទឹកក្រូចស្ដើង), ទិន្នន័យអង្កេត (ពណ៌ទឹកសមុទ្រ), និងការគណនារបស់អ្នកស្រាវជ្រាវ (ពណ៌ស្វាយ)។

តារាងទី ៣៩ បង្ហាញអំពីមុខរបរចំនួន ១០ ដែលកំពុងត្រូវការកម្លាំងពលកម្ម។ តារាងនេះបង្ហាញថាភាគច្រើនមុខរបរទាំងនេះមានតម្លៃសន្ទស្សន៍ឱកាសការងារធម្មតា (ចន្លោះ ៣,០០ ដល់ ៣,០៣) ដែលក្នុងនោះមានមុខរបរបុគ្គលិកការិយាល័យទូទៅ, អ្នកមើលការខុសត្រូវផ្នែកសម្អាត និងការថែរក្សាក្នុងសហគ្រាស, យន្តការី និងជាងជួសជុលម៉ាស៊ីនក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម, លេខាធិការផ្នែករដ្ឋបាល និងប្រតិបត្តិ, និងវិជ្ជាជីវៈខាងទំនាក់ទំនងសាធារណៈ។ ដោយឡែក មុខរបរជាអ្នកបើករថយន្តដឹកទំនិញ និងរថយន្តដឹកទំនិញធុនធ្ងន់, និងអ្នកបើករថយន្តតូច រថយន្តឈ្នួល និងរថយន្តវ៉ែន ហាក់មានឱកាសការងារទាបដោយសារតែតម្រូវការកម្រិតគុណវុឌ្ឍិទាប និងចំនួនបេក្ខជនច្រើន។ មុខរបរដែលអាចមានឱកាសការងារខ្ពស់រួមមាន វិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ (តម្លៃសន្ទ

ស្សន៍ ៣,៣៣), គណនេយ្យករ (កម្រិតខ្ពស់) ឬសវនករ (តម្លៃសន្ទស្សន៍ ៣,៦៣) និងភ្នាក់ងារប្រមូលទំនិញចេញ និងដឹកជញ្ជូនចេញ និងបញ្ជូនបន្ត (តម្លៃសន្ទស្សន៍ ៣,៩៧)។

តារាងទី ៣៩៖ មុខរបរដែលមានចំនួនប្រកាសជ្រើសរើសច្រើនសម្រាប់អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញ

| ល.រ | ISCO | មុខរបរ | សន្ទស្សន៍ ឆមាសទី២ ឆ្នាំ២០២៤ | សន្ទស្សន៍ ឆមាសទី១ ឆ្នាំ២០២៥ | ប្រាក់ខែ | អត្ថប្រយោជន៍ផ្សេងៗ |
|---|---|---|---|---|---|---|
| 1 | 3331 | ភ្នាក់ងារប្រមូលទំនិញចេញ និងដឹកជញ្ជូនចេញ និងបញ្ជូនបន្ត | 3.29 | 3.97 | $ 675 | $ 93 |
| 2 | 2411 | គណនេយ្យករ (កម្រិតខ្ពស់) ឬសវនករ | 3.39 | 3.63 | $ 864 | $ 32 |
| 3 | 2431 | វិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ | 3.08 | 3.33 | $ 941 | $ 334 |
| 4 | 4110 | បុគ្គលិកការិយាល័យទូទៅ | 2.83 | 3.03 | $ 465 | $ 137 |
| 5 | 5151 | អ្នកមើលការខុសត្រូវផ្នែកសម្អាត និងការថែរក្សាក្នុងសហគ្រាស | 2.08 | 3.00 | $ 225 | $ 230 |
| 6 | 7233 | យន្តការី និងជាងជួសជុលម៉ាស៊ីនក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម | - | 3.00 | $ 795 | $ 400 |
| 7 | 3343 | លេខាធិការផ្នែករដ្ឋបាល និងប្រតិបត្តិ | 2.96 | 3.00 | $ 724 | $ 56 |
| 8 | 2432 | វិជ្ជាជីវៈខាងទំនាក់ទំនងសាធារណៈ | 3.20 | 3.00 | $ 474 | $ 100 |
| 9 | 8332 | អ្នកបើកបររថយន្តដឹកទំនិញ និងរថយន្តដឹកទំនិញធុនធ្ងន់ | 3.34 | 2.71 | $ 380 | $ 50 |
| 10 | 8322 | អ្នកបើកបររថយន្តតូច រថយន្តឈ្នួល និងរថយន្តវែន | 3.03 | 2.40 | $ 270 | $ 167 |

*ចំណាំ៖ តម្លៃសន្ទស្សន៍ < ២,៨ បញ្ជាក់ពីឱកាសការងារទាប; តម្លៃសន្ទស្សន៍ចន្លោះពី ២,៨ ដល់ ៣,២ បញ្ជាក់ពីឱកាសការងារមធ្យម; តម្លៃសន្ទស្សន៍ > ៣,២ បញ្ជាក់ពីឱកាសការងារខ្ពស់។

ប្រភព៖ ការគណនារបស់អ្នកស្រាវជ្រាវ។

## ២.៥ មុខរបរដែលមានតម្រូវការខ្ពស់

មុខរបរដែលមានតម្រូវការទីផ្សារការងារខ្ពស់ ត្រូវបានដកស្រង់ចេញពីមុខរបរសរុបចំនួន ២៥៦ ដែលមាននៅក្នុងអនុវិស័យទាំង១៣ ខាងលើ។ ការបែងចែកមុខរបរទៅតាមកម្រិតជំនាញ និងមុខតំណែងនេះ អាចជួយឱ្យការជ្រើសរើសមុខរបរដែលមានសក្តានុពល និងឱកាសការងារល្អ អាចកំណត់ទិសដៅ និងផែនការអាជីពរបស់ខ្លួនបានកាន់តែច្បាស់លាស់ ដោយផ្តោតលើការអភិវឌ្ឍជំនាញ និងបទពិសោធដែលសមស្របទៅតាមសក្តានុពល និងចំណាប់អារម្មណ៍របស់ខ្លួន។ ការស្វែងយល់ពីឱកាសការងារ និងមុខរបរដែលមានតម្រូវការខ្ពស់ត្រូវបានបែងចែកជាកម្រិតជំនាញ មុខតំណែង កម្រិតនៃការសិក្សា និងបទពិសោធការងារ ដូចក្នុងតារាងទី ៤០។

តារាងទី ៤០៖ មុខរបរដែលមានតម្រូវការខ្ពស់តាមកម្រិតជំនាញ

| | | | | | |
|---|---|---|---|---|---|
| **អ្នកគ្រប់គ្រង៖**<br>ជាកម្រិតអ្នកដឹកនាំស្ថាប័ន ដែលទាមទារកម្រិតអប់រំចាប់ពីបរិញ្ញាបត្រឡើងទៅ និងមានបទពិសោធយ៉ាងតិច១០ឆ្នាំ | នាយកគ្រប់គ្រងធនធានមនុស្ស<br> | នាយកគ្រប់គ្រងសេវាពាណិជ្ជកម្ម<br> | នាយកគ្រប់គ្រងការផ្គត់ផ្គង់ ការចែកចាយ<br> | នាយកគ្រប់គ្រងការរៀបចំផែនការ និងគោលនយោបាយ<br> | នាយកគ្រប់គ្រងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា<br> |
| **អ្នកជំនាញជាន់ខ្ពស់ និងអ្នកឯកទេស៖**<br>ជាកម្រិតអ្នកជំនាញជាន់ខ្ពស់ និងអ្នកឯក-ទេស ដែលទាមទារកម្រិតអប់រំចាប់ពីបរិញ្ញាបត្រឡើងទៅ និងមានបទពិសោធយ៉ាងតិច ៥ឆ្នាំ | អ្នកជំនាញខាងចំណីអាហារ<br> | គ្រូបង្រៀនភាសា<br> | វិស្វករឧស្សាហកម្ម និងផលិតកម្ម<br> | អ្នករចនាម៉ូត<br> | វិស្វករសំណង់ស៊ីវិល<br> |
| | អ្នកបង្កើតកម្មវិធី និងប្រព័ន្ធកុំព្យូទ័រ<br> | អ្នកបកប្រែ<br> | អ្នករចនាក្រាហ្វិច<br> | ស្ថាបត្យករ<br> | គ្រូបណ្ដុះបណ្ដាលបច្ចេកវិទ្យា ព័ត៌មានវិទ្យា<br> |
| **អ្នកបច្ចេកទេស និងអ្នកជំនាញរង៖**<br>ជាកម្រិតអ្នកបច្ចេកទេស និងអ្នកជំនាញរង ដែលទាមទារកម្រិតអប់រំចាប់ពីបរិញ្ញាបត្រឡើងទៅ និងមានបទពិសោធយ៉ាងតិច ១ឆ្នាំ | មន្ត្រីឥណទាន<br> | អ្នកមើលការខុសត្រូវការិយាល័យ<br> | អ្នករៀបចំកម្មវិធីប្រជុំ និងព្រឹត្តិការណ៍<br> | ភ្នាក់ងារប្រមូលទំនិញចេញ និងដឹកជញ្ជូន<br> | អ្នកបច្ចេកទេសគ្រឿងម៉ាស៊ីន<br> |
| | អ្នកមើលការខុសត្រូវក្នុងរោងចក្រ<br> | អ្នកបច្ចេកទេសគមនាគមន៍ និងព័ត៌មានវិទ្យា<br> | ជំនួយការគណនេយ្យករ<br> | អ្នកបច្ចេកទេសខាងវេជ្ជសាស្ត្រ<br> | អ្នកតំណាងលក់<br> |

| | | | | | |
|---|---|---|---|---|---|
| **បុគ្គលិកគាំទ្រ និងលេខាធិការ៖** ជាកម្រិតផ្នែកបុគ្គលិកគាំទ្រ និងស្មៀន ដែលទាមទារកម្រិតអប់រំបរិញ្ញាបត្ររងឡើងទៅ | បុគ្គលិកផ្នែកធនធានមនុស្ស  | បុគ្គលិកផ្នែកផលិតកម្ម  | បុគ្គលិកផ្នែកគណនេយ្យ និងបញ្ជី  | បុគ្គលិកខាងការរៀបចំការធ្វើដំណើរ  | បុគ្គលិកការិយាល័យទូទៅ  |
| **បុគ្គលិកផ្នែកលក់ និងសេវាកម្ម៖** ជាកម្រិតបុគ្គលិកបម្រើសេវាកម្ម ដែលទាមទារកម្រិតអប់រំចាប់ពីថ្នាក់ទី៩ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១(C1) ឡើង | បេឡាករ  | ជំនួយការគ្រូបង្រៀន  | អ្នកថែទាំក្មេង  | គ្រូបង្រៀនបើកបរ  | អ្នកពន្លត់អគ្គិភ័យ  |
| **កម្មករជំនាញសិប្បកម្ម និងការកែច្នៃដោយដៃ៖** ជាកម្រិតកម្មករ ឬសិប្បករ ដែលទាមទារកម្រិតអប់រំចាប់ពីថ្នាក់ទី៩ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1)ឡើងទៅ | អ្នកធ្វើស្បែកជើង  | អ្នកបាញ់ថ្នាំពណ៌  | ជាងផ្សារដែក *  | ជាងជួសជុលម៉ាស៊ីន *  | យន្តការី និងអ្នកតម្លើងអគ្គីសនី *  |
| | ជាងអេឡិចត្រូនិក *  | ជាងសំណង់ *  | អ្នកដុតនំ *  | ជាងកាត់ដេរសម្លៀកបំពាក់ *  | អ្នកតម្លើងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា *  |
| **កម្មករខាងបញ្ជាម៉ាស៊ីន និង ដំឡើងគ្រឿងចក្រ៖** ជាកម្រិតកម្មករ ដែលទាមទារជំនាញវិជ្ជាជីវៈ | អ្នកបញ្ជាឡានស្ទូច  | អ្នកបញ្ជាម៉ាស៊ីនដេរ *  | អ្នកបញ្ជាម៉ាស៊ីនវេចខ្ចប់  | អ្នកបញ្ជាម៉ាស៊ីនផលិតស្បែកជើង  | អ្នកតម្លើងបរិក្ខារអគ្គីសនី និងអេឡិចត្រូនិក *  |

*កំណត់សម្គាល់៖ ជំនាញដែលមានក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ (1.5M)។

ប្រភព៖ ការជ្រើសរើសរបស់អ្នកស្រាវជ្រាវ។

តារាងទី ៤១ បង្ហាញពីមុខរបរចំនួន ២៥ ដែលមានកំណើនតម្រូវការលឿនតាមរយៈការវិភាគ និងស្រាវជ្រាវសម្រាប់អ្នកស្វែងរកការងារធ្វើ និងជាជំនួយសម្រាប់ការជ្រើសរើសមុខរបរ។ តារាងនេះផ្តល់ព័ត៌មានដ៏មានតម្លៃដែលបង្ហាញពីនិន្នាការអាជីព និងតម្រូវការនៃកម្លាំងពលកម្មដែលកំពុងកើនឡើង។ ទិន្នន័យនេះ បង្ហាញពីនិន្នាការទីផ្សារការងារបច្ចុប្បន្ន ហើយក៏ជាព័ត៌មានសម្រាប់និយោជក អ្នកអប់រំ និងយុវជន ក្នុងការយល់ដឹងអំពីសក្តានុពលនៃទិដ្ឋភាពការងារ។ ទន្ទឹមគ្នានេះ ការសង្កេត និងវិភាគក៏បានបង្ហាញឱ្យឃើញថាប្រភេទមុខរបរដែលមានការថយចុះក្នុងគ្រប់វិស័យទាំង ២៥ មុខរបរ ដែលមាននៅក្នុងតារាងទី ៤២។

តារាងទី ៤១៖ មុខរបរមានកំណើនលឿនក្នុងឆមាសទី១ ឆ្នាំ២០២៥

| ល.រ | ឈ្មោះមុខរបរ | | ពិពណ៌នាអំពីការងារ និងលក្ខខណ្ឌតម្រូវ | ប្រាក់ខែ (ដុល្លារអាម៉េរិក) |
|---|---|---|---|---|
| ១ |  | អ្នកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ | -គ្រប់គ្រង ត្រួតពិនិត្យរចនាសម្ព័ន្ធ និងសេវាកម្ម ICT<br>-កម្រិតបរិញ្ញាបត្រផ្នែកកុំព្យូទ័រឡើងទៅ | 700 – 1000 |
| ២ |  | នាយកគ្រប់គ្រងការផ្គត់ផ្គង់ ការចែកចាយ និងពាក់ព័ន្ធផ្សេងទៀត | -រៀបចំបង្កើតផែនការយុទ្ធសាស្ត្រទីផ្សារ<br>-បរិញ្ញាបត្រផ្នែកគ្រប់គ្រង និងមានបទពិសោធគ្រប់គ្រងផ្នែកលក់ | 500 – 1000 |
| ៣ |  | នាយកគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យា គមនាគមន៍ និងព័តមានវិទ្យា | -គ្រប់គ្រងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា<br>-បរិញ្ញាបត្រផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា | 500 – 900 |
| ៤ |  | ភ្នាក់ងារប្រមូលទំនិញចេញ និងដឹកជញ្ជូនចេញ និងបញ្ជូនបន្ត | - រៀបចំការដឹកជញ្ជូន និងឯកសារពន្ធគយ<br>-ថ្នាក់ទី១២ឡើងទៅ និងមានបទពិសោធការងារដឹកជញ្ជូន | 420 – 570 |
| ៥ |  | អ្នកបញ្ជាម៉ាស៊ីនវេចខ្ចប់ ប្រកដាក់ដប និងដាក់ផ្លាកសញ្ញា | -ប្រតិបត្តិការ និងត្រួតពិនិត្យម៉ាស៊ីន<br>-ថ្នាក់ទី១២ឡើងទៅ និងធ្លាប់ទទួលវគ្គបណ្តុះបណ្តាលការងារ | 208 – 220 |
| ៦ |  | អ្នកបញ្ជាម៉ាស៊ីនដេរ | -ដំណើរការម៉ាស៊ីនដេរ និងប្រមូលផ្តុំសំលៀកបំពាក់<br>-ថ្នាក់ទី១២ឡើងទៅ និងមានបទពិសោធកាត់ដេរ | 208 – 230 |
| ៧ |  | អ្នកបញ្ជាម៉ាស៊ីនធ្វើស្បែកជើង និងម៉ាស៊ីនដែលពាក់ព័ន្ធ | -ដំណើរការម៉ាស៊ីន<br>-ថ្នាក់ទី១២ឡើងទៅ និងធ្លាប់ទទួលវគ្គបណ្តុះបណ្តាលការងារ | 208 – 250 |
| ៨ |  | បុគ្គលិកផ្នែកកត់ត្រាខាងដឹកជញ្ជូន | -រៀបចំឯកសារដឹកជញ្ជូន តាមដាន និងសម្របសម្រួល<br>-ថ្នាក់ទី១២ឡើងទៅ និងបទពិសោធដឹកជញ្ជូន | 290 – 300 |

| ល.រ | ឈ្មោះមុខរបរ | ពិពណ៌នាអំពីការងារ និងលក្ខខណ្ឌតម្រូវ | ប្រាក់ខែ (ដុល្លារអាម៉េរិក) |
|---|---|---|---|
| ៩ |  បុគ្គលិកផ្នែកកត់ត្រាខាងផលិតកម្ម | -តាមដានកាលវិភាគផលិតកម្ម ត្រួតពិនិត្យសារពើភ័ណ្ឌ និងរៀបចំរបាយការណ៍<br>-កម្រិតបរិញ្ញាបត្រឡើងទៅ | 220 – 260 |
| ១០ |  មន្ត្រីឥណទាន និងប្រាក់កម្ចី | -វាយតម្លៃពាក្យស្នើសុំកម្ចី<br>-កម្រិតបរិញ្ញាបត្ររងឡើងទៅ | 280 – 350 |
| ១១ |  គ្រូបង្រៀនភាសាផ្សេងទៀត | -រៀបចំមេរៀន និងបង្រៀន<br>-កម្រិតបរិញ្ញាបត្រផ្នែកភាសា | 210 – 400 |
| ១២ |  អ្នកបកប្រែអត្ថបទ អ្នកបកប្រែផ្ទាល់មាត់ និងភាសាវិទូដទៃទៀត | -បកប្រែឯកសារផ្សេងៗ<br>-កម្រិតបរិញ្ញាបត្រផ្នែកភាសា និងបទពិសោធបកប្រែ | 420 – 500 |
| ១៣ |  ជំនួយការគ្រូបង្រៀន | -ជួយគ្រូបង្រៀនក្នុងថ្នាក់ និងផ្តល់ជំនួយដល់សិស្ស<br>-ថ្នាក់ទី១២ឡើងទៅ និងមានបទពិសោធធ្វើការជាមួយកុមារ | 200 – 300 |
| ១៤ |  យន្តការី និងជាងជួសជុលម៉ាស៊ីនក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម | -ដំឡើង ថែទាំ និងជួសជុលប្រព័ន្ធអគ្គិសនី<br>-វិញ្ញាបនបត្រផ្នែកអគ្គិសនី | 255 – 350 |
| ១៥ |  ជាងអគ្គិសនីទូទៅ | -ថែទាំ និងជួសជុលប្រព័ន្ធអគ្គិសនី<br>-វិញ្ញាបនបត្រផ្នែកអគ្គិសនី | 225 – 275 |
| ១៦ |  អ្នកជំនាញផ្នែកធនធានមនុស្ស ឬជ្រើសរើសបុគ្គលិក | -បង្កើត និងអនុវត្តយុទ្ធសាស្ត្រធនធានមនុស្ស<br>-បរិញ្ញាបត្រផ្នែកធនធានមនុស្ស | 300 – 500 |
| ១៧ |  អ្នកកាត់សំលៀកបំពាក់ និងតុកាត់ | -បង្កើត គំរូសំលៀកបំពាក់<br>-ថ្នាក់ទី៩ឡើង និងមានបទពិសោធបណ្តុះបណ្តាល | 210 – 250 |
| ១៨ |  អ្នកមើលការខុសត្រូវការផលិតក្នុងរោងចក្រ | -តាមដានកាលវិភាគ និងដំណើរការផលិតកម្ម<br>-ថ្នាក់ទី៩ឡើង និងមានបទពិសោធរៀបចំផែនការផលិតកម្ម | 300 – 500 |
| ១៩ |  អ្នកបញ្ជាម៉ាស៊ីនផលិតផលិតផលជ័រកៅស៊ូ | -គ្រប់គ្រងដំណើរការ និងត្រួតពិនិត្យម៉ាស៊ីន<br>-ថ្នាក់ទី១២ឡើង និងមានបទពិសោធបណ្តុះបណ្តាល | 200 – 250 |

| ល.រ | | ឈ្មោះមុខរបរ | ពិពណ៌នាអំពីការងារ និងលក្ខខណ្ឌតម្រូវ | ប្រាក់ខែ (ដុល្លារអាម៉េរិក) |
|---|---|---|---|---|
| ២០ |  | អ្នកមើលការខុសត្រូវការិយាល័យ | -គ្រប់គ្រងបុគ្គលិក និងការងាររដ្ឋបាល<br>-ថ្នាក់ទី១២ឡើងទៅ និងមានបទពិសោធការិយាល័យ | 320 – 520 |
| ២១ |  | អ្នករចនាក្រាហ្វិច និងម៉ាលជីមេឌៀ | -បង្កើតការរចនារូបភាព ម៉ាលជីមេឌៀ និងគេហទំព័រ<br>-បរិញ្ញាបត្រផ្នែករចនាក្រាហ្វិច ឬផ្នែកដែលពាក់ព័ន្ធ | 300 – 500 |
| ២២ |  | អ្នកបង្កើតកម្មវិធី និងប្រព័ន្ធកុំព្យូទ័រ | -ដំឡើង ថែទាំ និងដោះស្រាយបញ្ហាប្រព័ន្ធកុំព្យូទ័រ<br>-កម្រិតបរិញ្ញាបត្រផ្នែកកុំព្យូទ័រឡើងទៅ | 375 – 600 |
| ២៣ |  | អ្នកដុតនំ អ្នកធ្វើនំម្សៅ និងដំណាប់ | -មានចំណេះដឹងនៃបច្ចេកទេសរៀបចំអាហារ ភាពច្នៃប្រឌិត<br>-វិញ្ញាបនបត្រធ្វើនំ ឬការបណ្ដុះបណ្ដាលនៅកន្លែងធ្វើការ | 180 – 250 |
| ២៤ |  | គ្រូបង្រៀននៅសាកលវិទ្យាល័យ និងឧត្តមសិក្សា | -រៀបចំចងក្រងឯកសារបង្រៀន និងស្រាវជ្រាវ<br>-បរិញ្ញាបត្រឡើងទៅ និងគរុកោសល្យបង្រៀន | 350 – 500 |
| ២៥ |  | អ្នកបញ្ជាឡានស្ទូច | -បញ្ជាឡានស្ទូច និងឧបករណ៍លើកផ្សេងទៀត<br>-ថ្នាក់ទី៩ឡើងទៅ និងមានបទពិសោធបញ្ជាឡានស្ទូច | 220 – 350 |

ប្រភព៖ ការជ្រើសរើសរបស់អ្នកស្រាវជ្រាវ។

## តារាងទី ៤២៖ មុខរបរដែលថយចុះក្នុងឆមាសទី១ ឆ្នាំ២០២៥

| ល.រ | | ឈ្មោះមុខរបរ | ពិពណ៌នាអំពីការងារ និងលក្ខខណ្ឌតម្រូវ | ប្រាក់ខែ (ដុល្លារអាម៉េរិក) |
|---|---|---|---|---|
| ១ |  | នាយកគ្រប់គ្រងហិរញ្ញវត្ថុ | -គ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុរបស់ស្ថាប័ន<br>-កម្រិតបរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ | 500 – 1000 |
| ២ |  | នាយកគ្រប់គ្រងសេវាសុខភាព | -គ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរពេទ្យ<br>-សញ្ញាបត្រវេជ្ជបណ្ឌិត និង មានបទពិសោធក្នុងការគ្រប់គ្រង | 500 – 1000 |
| ៣ |  | នាយកគ្រប់គ្រងការលក់ និងទីផ្សារ | -បង្កើត និងអនុវត្តយុទ្ធសាស្ត្រលក់ និងទីផ្សារ<br>-កម្រិតបរិញ្ញាបត្រផ្នែកទីផ្សារ ឬអាជីវកម្ម និងបទពិសោធពាក់ព័ន្ធ | 500 – 800 |

| ល.រ | ឈ្មោះមុខរបរ | | ពិពណ៌នាអំពីការងារ<br>និងលក្ខខណ្ឌតម្រូវ | ប្រាក់ខែ<br>(ដុល្លារអាម៉េរិក) |
|---|---|---|---|---|
| ៤ |  | នាយកគ្រប់គ្រងការផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ | -បង្កើត និងអនុវត្តយុទ្ធនាការផ្សព្វផ្សាយ និងទំនាក់ទំនង<br>-សញ្ញាបត្របរិញ្ញាបត្រផ្នែកទីផ្សារ ទំនាក់ទំនងសាធារណៈ ឬវិស័យពាក់ព័ន្ធ និងបទពិសោធពាក់ព័ន្ធ | 500 – 800 |
| ៥ |  | វេជ្ជបណ្ឌិតឯកទេសទូទៅ | -ពិនិត្យ និងព្យាបាលជំងឺទូទៅ<br>-សញ្ញាបត្រវេជ្ជបណ្ឌិត | 370 – 750 |
| ៦ |  | អ្នកវិភាគហិរញ្ញវត្ថុ | -វិភាគទិន្នន័យហិរញ្ញវត្ថុ និងផ្តល់អនុសាសន៍វិនិយោគ<br>-សញ្ញាបត្របរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងវិញ្ញាបនបត្រពាក់ព័ន្ធ | 400 – 600 |
| ៧ |  | នាយកគ្រប់គ្រងភោជនីយដ្ឋាន | -គ្រប់គ្រងការងារប្រចាំថ្ងៃក្នុងភោជនីយដ្ឋាន<br>-វគ្គបណ្តុះបណ្តាល ផ្នែកគ្រប់គ្រងភោជនីយដ្ឋាន | 320 – 580 |
| ៨ |  | ឈ្មួញ និងឈ្មួញកណ្តាលខាងមូលប័ត្រ និងហិរញ្ញវត្ថុ | -សម្របសម្រួលការទិញ និងលក់មូលបត្រហិរញ្ញវត្ថុ<br>-បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ ឬអាជ្ញាប័ណ្ណ/វិញ្ញាបនប័ត្រដែលពាក់ព័ន្ធ | 350 – 450 |
| ៩ |  | ជំនួយការគណនេយ្យករ | -ជួយគណនេយ្យករក្នុងការកត់ត្រា និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ<br>-សញ្ញាបត្រមធ្យមសិក្សា និងការបណ្តុះបណ្តាលផ្នែកគណនេយ្យ | 220 – 350 |
| ១០ |  | បុគ្គលិកទូទៅផ្នែកកត់ត្រាគណនេយ្យ និងបញ្ជី | -រក្សាកំណត់ត្រាហិរញ្ញវត្ថុ និងរៀបចំរបាយការណ៍<br>-ថ្នាក់ទី១២ឡើងទៅ ធ្លាប់ទទួលវគ្គបណ្តុះបណ្តាលផ្នែកគណនេយ្យ | 270 – 350 |
| ១១ |  | វិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ | -បង្កើត និងអនុវត្តយុទ្ធនាការទីផ្សារឌីជីថល<br>-ថ្នាក់ទី១២ឡើងទៅ និងបទពិសោធផ្នែកលក់ | 270 – 350 |
| ១២ |  | អ្នកបើកបររថយន្តធុនតូច និងធុនធំ | -ដឹកជញ្ជូនទំនិញ និងសម្ភារៈ<br>-ប័ណ្ណបើកបរដែលមានសុពលភាព | 180 – 240 |
| ១៣ |  | បុគ្គលិក ឬជំនួយការផ្នែកធនធានមនុស្ស | -ជួយការជ្រើសរើសបុគ្គលិក ការរៀបចំឯកសារពាក់ព័ន្ធ<br>-ថ្នាក់ទី១២ឡើងទៅ និងការបណ្តុះបណ្តាលផ្នែកធនធានមនុស្ស | 220 – 350 |
| ១៤ |  | បុគ្គលិកការិយាល័យទូទៅ | - បំពេញការងាររដ្ឋបាលទូទៅ ដូចជាការដាក់ឯកសារ ការបញ្ចូលទិន្នន័យ និងការឆ្លើយទូរស័ព្ទ<br>-ថ្នាក់ទី១២ឡើងទៅ និងបទពិសោធការងាររដ្ឋបាល | 220 – 350 |

| លរ | | ឈ្មោះមុខរបរ | ពិពណ៌នាអំពីការងារ និងលក្ខខណ្ឌតម្រូវ | ប្រាក់ខែ (ដុល្លារអាម៉េរិក) |
|---|---|---|---|---|
| ១៥ |  | គ្រូបង្រៀនតន្ត្រីផ្សេងទៀត | - បង្រៀនទ្រឹស្តីតន្ត្រី ឧបករណ៍ភ្លេង ឬបច្ចេកទេសសម្លេង<br>-បរិញ្ញាបត្រផ្នែកអប់រំតន្ត្រី ឬវិញ្ញាបនបត្របង្រៀនតន្ត្រី | 200 – 300 |
| ១៦ |  | អ្នកទទួលភ្ញៀវក្នុងសណ្ឋាគារ | -ទទួលភ្ញៀវ និងផ្តល់សេវាកម្មអតិថិជន<br>-ថ្នាក់ទី១២ឡើងទៅ និងបទពិសោធក្នុងការផ្តល់សេវាកម្មអតិថិជន | 150 – 250 |
| ១៧ |  | វិជ្ជាជីវៈខាងឆ្មប | -ផ្តល់ការថែទាំដល់ស្ត្រីមានផ្ទៃពោះ ការសម្រាលកូន<br>-បរិញ្ញាបត្រ ឬអនុបណ្ឌិតផ្នែកឆ្មប និងវិញ្ញាបនបត្រឆ្មបដែលបានចុះបញ្ជី | 300 – 470 |
| ១៨ |  | បុគ្គលិកផ្នែកកត់ត្រាខាងស្តុកទំនិញ | -គ្រប់គ្រងស្តុកទំនិញ ទទួល និងចែកចាយសម្ភារៈ<br>-ថ្នាក់ទី១២ឡើងទៅ និងបទពិសោធក្នុងការគ្រប់គ្រងស្តុកទំនិញ | 220 – 400 |
| ១៩ |  | អ្នកបញ្ជាម៉ាស៊ីនផលិតផលិតផលប្លាស្ទិក | -បញ្ជា និងត្រួតពិនិត្យម៉ាស៊ីនផលិតផលិតផលប្លាស្ទិក<br>-វគ្គបណ្តុះបណ្តាល និងបទពិសោធក្នុងការប្រើប្រាស់ម៉ាស៊ីនផលិតផលិតផលប្លាស្ទិក | 220 – 250 |
| ២០ |  | គ្រូបង្រៀននៅថ្នាក់មធ្យមសិក្សា | -បង្រៀនមុខវិជ្ជានៅថ្នាក់មធ្យមសិក្សា<br>-បរិញ្ញាបត្រផ្នែកអប់រំ និងវិញ្ញាបនបត្របង្រៀន | 250 – 400 |
| ២១ |  | អ្នកអប់រំកុមារតូចៗ | -បង្រៀន និងថែទាំកុមារតូចៗ នៅក្នុងសាលាមត្តេយ្យ<br>-បរិញ្ញាបត្ររងផ្នែកអប់រំកុមារ ឬវិញ្ញាបនបត្រពាក់ព័ន្ធ | 200 – 400 |
| ២២ |  | អ្នកក្រឡុកស្រា | -ផ្តល់សេវាកម្មរៀបចំ និងបម្រើភេសជ្ជៈ<br>-វគ្គបណ្តុះបណ្តាល | 125 – 200 |
| ២៣ |  | ជំនួយការមេចុងភៅ | -ជួយមេចុងភៅក្នុងធ្វើម្ហូបអាហារ និងថែរក្សាអនាម័យ<br>-បទពិសោធក្នុងការចម្អិនអាហារ ចំណេះដឹងអំពីបច្ចេកទេសចម្អិនអាហារ | 150 – 300 |
| ២៤ |  | ជាងដំឡើងបំពង់ទុយោទឹក បំពង់ទុយោឧស្ម័ន និងបំពង់ទុយោខ្យល់ | -ដំឡើង ថែទាំ និងជួសជុលប្រព័ន្ធទឹក និងលូ<br>-ថ្នាក់ទី១២ឡើង និង បណ្តុះបណ្តាលវិជ្ជាជីវៈ ឬកម្មសិក្សាផ្នែកបំពង់ទុយោ | 210 – 300 |
| ២៥ |  | បេឡាធិការនៅធនាគារ | -ទទួលប្រាក់បញ្ញើ ដកប្រាក់ ផ្ទេរប្រាក់ និងផ្តល់សេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀតដល់អតិថិជន<br>-ថ្នាក់ទី១២ឡើងទៅ និងជំនាញទំនាក់ទំនងល្អ | 250 – 350 |

ប្រភព៖ ការជ្រើសរើសរបស់អ្នកស្រាវជ្រាវ។

## ជំពូកទី ៣ សេចក្ដីសន្និដ្ឋាន

របាយការណ៍នេះសិក្សាពីទស្សនវិស័យការងារកម្ពុជាសម្រាប់ឆមាសទី១ ឆ្នាំ២០២៥ ដោយផ្តោតលើការវិភាគទីផ្សារការងារ និន្នាការការងារ និងឱកាសការងារក្នុងវិស័យផ្សេងៗ។ ការសិក្សានេះប្រើប្រាស់ទិន្នន័យពីការសម្ភាសតំណាងសហគ្រាស និងគ្រឹះស្ថានចំនួន ៦៣៨ ដែលគ្របដណ្ដប់លើវិស័យសេដ្ឋកិច្ចសំខាន់ៗចំនួន ១៣ និងរាជធានីខេត្តចំនួន ១០ នៅប្រទេសកម្ពុជា។ ការសិក្សានេះមានគោលបំណងផ្តល់ព័ត៌មានសម្រាប់អ្នកស្វែងរកការងារ និងអ្នកជំនាញធនធានមនុស្ស ដើម្បីជួយពួកគេក្នុងការសម្រេចចិត្ត និងការរៀបចំយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍអាជីព។

